ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការចងចាំរបស់ជាតិ
- សុន្ទរកថា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៧៨ ខែតុលា ឆ្នាំ២០១៤

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៧៨ ខែតុលា ឆ្នាំ២០១៤


## មាតិកា


◆ ការចងចាំរបស់ជាតិ ....................................................................១

◆ ពិធីសម្ពោធបួងរបស់វិទ្យាស្ថានស៊ីករីត ..........................................១៧

◆ សុន្ទរកថា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ..........................២០

### ផ្នែកឯកសារ

◆ ធ្វើការច្រើន ទទួលផលច្រើន តែចំណាយទុនតិច.............................២២

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ បាត់បង់បងប្អូនដោយសារការចូលរួមបដិវត្តន៍.................................២៩

◆ តាញ៉ែន អតីតគណៈស្រុកអន្លង់វែង និងស្រុកសេរីសោភ័ណ..............៣១

◆ ចាប់ពីរបបខ្មែរក្រហម ដល់ខុបទ្ធ័រហេតុ ហាំ បាលី .........................៣៣

### ផ្នែកច្បាប់

◆ សវនាការបឋមបន្ថែមស្តីពីសំណុំរឿង០០២ ...................................៣៩

### វេទិកាពិភាក្សាសាធារណៈ

◆ ការឆ្លើយតបទៅអត្ថបទ រ៉េនឌុល ដឺហ្វាលកូ....................................៤៥

### ទំព័រស្រាវជ្រាវរកក្រុមគ្រួសារ

◆ ទូច ឈុំ និងការតស៊ូ.....................................................................៤៨

◆ សាងអ៊ីនឹងទទួលផលនោះ ...........................................................៥១

◆ អ្នករួចរស់ជីវិតពីរបបខ្មែរក្រហម.....................................................៥២

◆ រកឃើញមិត្តភក្តិនៅក្នុងចម្លើយសារភាព........................................៦១




លោកស្រី ហ្សាហា ហាឌីដ ស្ថាបត្យករ និងជាប្រធានក្រុមហ៊ុន ហ្សាហា ហាឌីដ ថ្លែងនៅក្នុងពិធីសម្ពោធបួងអគារស៊ីករីត នៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ*** *: ហង់ ជួន ណារ៉ុន, អេង កុកថាយ, លឹម ជ័យទ័ត្ត, ម៉ៃឃើល កាណាវ៉ាស់, សុភ័ក្ត្រ ភាណា, អ៊ុច ស៊ុនឡាយ, ស៊ិន សុធីតា* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** *: ទាវ សារៈមុនិន្ទ* ***អ្នកបកប្រែ*** *: សុភ័ក្ត្រ ភាណា និង សាយ សូលីដា* ***និពន្ធនាយកទូទៅ*** *: ឆាំង យុ* ***ជំនួយការនិពន្ធនាយក*** *: សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ*** *: សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** *: ឆេង វើង និង សន ល័ក្ខ* Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ការចងចាំរបស់ជាតិ

## គ្រឹះស្ថានឧត្តមសិក្សា និងបូជនីយដ្ឋានប្រល័យពូជសាសន៍ដំបូងគេបង្អស់នៅកម្ពុជា

### *រចនាប្លង់ដោយក្រុមហ៊ុនស្ថាបត្យកម្ម ហ្សាហា ហាឌីដ*

ប្លង់រចនារបស់វិទ្យាស្ថានស្លឹករឹត ដែលជាវិទ្យាស្ថាន និងបូជនីយដ្ឋានប្រល័យពូជសាសន៍ថ្មីមួយ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា បានចេញជារូបរាងឡើងហើយ ។ វិទ្យាស្ថាននេះរួមមានសារមន្ទីរ មជ្ឈមណ្ឌលស្រាវជ្រាវ សាលារៀនកម្រិតថ្នាក់ឧត្តមសិក្សា បណ្ណសារដ្ឋានតម្កល់ឯកសារ និងបណ្ណាល័យស្រាវជ្រាវ ។

ទស្សនវិស័យរបស់លោក ឆាំង យុ ដែលជាសកម្មជនសិទ្ធិមនុស្សដ៏ឆ្នើម និងជាអ្នកស៊ើបអង្កេតមួយរូបស្តីអំពីអំពើព្រៃផ្សៃរបស់របបខ្មែរក្រហម វិទ្យាស្ថានស្លឹករឹតត្រូវបានបង្កើតឡើង ដោយរូបលោកផ្ទាល់ ដោយផ្តោតទៅលើការឆ្លុះបញ្ចាំងពីអតីតកាល ការធ្វើឲ្យជាសះស្បើយ និងការបង្រួបបង្រួមជាតិ ។ ចំណែកឯកិច្ចការស្រាវជ្រាវ និងការអប់រំរបស់វិទ្យាស្ថានស្លឹករឹតបង្កើតឡើងក្នុងគោលបំណងរំឭកដល់ជីវិតមនុស្សដែលបានបាត់បង់កាលពីអតីតកាលដោយស្ថាបនាអនាគតឲ្យប្រសើរឡើង ។

នាអំឡុងចុងទសវត្សរ៍៧០ លោក ឆាំង យុ ដែលកាលនោះមានអាយុ១៥ឆ្នាំ បានក្លាយជាអ្នកទោសក្រោមរបបខ្មែរក្រហម ចំណែកឯសមាជិកគ្រួសាររបស់លោកផ្សេងទៀតក្លាយជាជនរងគ្រោះនៃរបបនេះ ។ តាមរយៈមជ្ឈមណ្ឌលឯកសារស្រាវជ្រាវរបស់លោក លោក ឆាំង យុ បានចំណាយពេលជាងមួយទសវត្សរ៍ដើម្បីប្រមែប្រមូលឯកសារ និងប្រវត្តិនានាទាក់ទងនឹងអំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ឬត្រូវបានស្គាល់ជាទូទៅថា របបខ្មែរក្រហម ។

វិទ្យាស្ថានស្លឹករឹតត្រូវបានរចនាប្លង់ដោយស្ថាបត្យករលំដាប់ពិភពលោក ហ្សាហា ហាឌីដ ហើយវិទ្យាស្ថាននេះនឹងក្លាយជាឃ្លាំងផ្ទុកឯកសារជាងមួយលានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងបណ្ណសារដ្ឋាន ហើយក្នុងនាមជាស្ថាប័ន ដែលមានឯកសារតម្កល់ច្រើនជាងគេបង្អស់នៅអាស៊ីអាគ្នេយ៍ទាក់ទងនឹងរបបប្រល័យពូជសាសន៍ វិទ្យាស្ថានស្លឹករឹត នឹងក្លាយជាមជ្ឈមណ្ឌលសាកលមួយសម្រាប់ការអប់រំ ស្រាវជ្រាវដើម្បីបង្កើត ចងក្រងឯកសារ និងដើម្បីបុព្វហេតុទប់ស្កាត់របបប្រល័យពូជសាសន៍ ។

ទោះបីជាវិទ្យាស្ថាននេះស្រាវជ្រាវរឿងរ៉ាវទាក់ទងនឹងរបបឃោរឃៅក្តី កិច្ចការស្រាវជ្រាវរបស់លោក ឆាំង យុ បានជំរុញទឹកចិត្តលោកអស់រយៈពេលជាច្រើនឆ្នាំឲ្យមានការត្រិះរិះពិចារណាក្នុងការបង្កើតសំណង់អគារដ៏អស្ចារ្យមួយដែលជួយលើកកម្ពស់ឲ្យមានការឆ្លុះបញ្ចាំងរឿងរ៉ាវពីអតីតកាល និងការបង្រួបបង្រួមជាតិព្រមទាំងជំរុញឲ្យមានការបណ្តុះគំនិត និងការបង្កើតថ្មី ។ លោកបានមានប្រសាសន៍ថា «ប្រទេសកម្ពុជានឹងមិនអាចគេចវេះពីប្រវត្តិសាស្ត្ររបស់ខ្លួនបានទេ ប៉ុន្តែ ប្រទេសនេះមិនត្រូវក្លាយខ្លួនជាទាសករនៃប្រវត្តិសាស្ត្រទៀតដែរ ។ សង្គមក្រោយជម្លោះចាំបាច់ត្រូវធ្វើដំណើរទៅមុខ» ។

ការសញ្ជឹងគិតក្នុងការបង្កើតថ្មីនេះតម្រូវឲ្យមានទិសដៅមួយដែលបំបែកនូវបែបផែនមួយ ទាក់ទងនឹងរបបប្រល័យពូជសាសន៍ និងស្ថាបត្យកម្មបែបបូជនីយដ្ឋាន ។ លោក ឆាំង យុ បានមានប្រសាសន៍ទៀតថា «នៅក្នុងបុព្វបទប្រល័យពូជសាសន៍ និងការសម្លាប់ទ្រង់ទ្រាយធំ ស្ថាបត្យកម្មបែបបូជនីយដ្ឋានមានទំនោរទៅរកការឆ្លុះបញ្ចាំងតែរឿងរ៉ាវណាដែលព្រៃផ្សៃ និងមិនល្អនៃប្រវត្តិសាស្ត្រដែលស្ថាបត្យកម្មនោះបង្ហាញ ។ ក្នុងន័យនេះ កេរដំណែលស្ថាបត្យកម្ម ហាក់បីដូចជាមានភាពងងឹត ឈឺចាប់ និងតម្រង់ផ្លូវទៅរកអតីតកាលតែប៉ុណ្ណោះ» ។

លោកបានបន្ថែមទៀតថា «យើងមានគំនិតយ៉ាងមោះមុតក្នុងការបង្កើតវិទ្យាស្ថានមួយនាពេលអនាគតខាងមុខដែលយើង

គ្រោង និងបង្កើតដោយបង្វែរទិសដៅពីការគិតតែរឿងឈឺចាប់ និងរឿងរ៉ាវទុក្ខសោកនៃតួនាទីរបស់បូជនីយដ្ឋាន ។ នេះមិនមែនរិះគន់ ឬមានគំនិតទុទិដ្ឋិនិយមអំពីតួនាទីរបស់បូជនីយដ្ឋានទាំងឡាយនាពេលបច្ចុប្បន្ននេះទេ តែការលើកឡើងនេះគឺដើម្បីបញ្ជាក់ថា ដោយសារតែប្រទេសកម្ពុជាជាប្រទេសមានវប្បធម៌ដ៏រុងរឿងនៅលើពិភពលោក និងទំនៀមទម្លាប់ សាសនាដ៏សម្បូរបែប យើងត្រូវផ្លាស់ប្តូរវិធីផ្សេងទៅរកទិសដៅដែលមានលក្ខណៈវិជ្ជមានប្រសើរជាងមុន ។ បូជនីយដ្ឋានដែលប្រសើរបំផុត មិនមែនជាអ្វីមួយដែលយើងទស្សនាតែម្តង ក្អែកសម្លឹងមើលហើយឈប់គិតនោះទេ ។ បូជនីយដ្ឋានដែលល្អគឺអាចរំឭកស្មារតីអ្នកទស្សនាឲ្យមានការឆ្លុះបញ្ចាំងនឹងអតីតកាល និងការរំឭកដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ និងរំឭកដល់អ្នកដែលរស់រានមានជីវិត ព្រមទាំងទីកន្លែងនានាដែលអាចទាក់ទងមនុស្សគ្រប់ជំនាន់ទាំងអស់នៅក្នុងសហគមន៍» ។

លោក ឆាំង យុ បានធ្វើការពន្យល់ថា «វិទ្យាស្ថានស្លឹករឹតមិនមែនផ្តោតលើតែអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែវិទ្យាស្ថាននេះមានបំណងបង្កើតជាស្ថាប័នជាតិមួយដែលផ្តល់នូវពន្លឺ ជាកន្លែងមួយដែលមនុស្សជំនាន់ក្រោយរៀនមេរៀនពីអតីតកាលនៃអំពើឃោរឃៅ ហើយជាមួយគ្នានោះដែរ ជាកន្លែងមួយដែលស្វែងរកវិធីព្យាបាលឲ្យជាសះស្បើយ និងធ្វើដំណើរទៅមុខ ។ ការតាំងចិត្ត ការប្តេជ្ញាចិត្ត និងជំនឿសម្រាប់អនាគតរបស់យើងនេះហើយដែលជំរុញទឹកចិត្តយើងឲ្យបង្កើតវិទ្យាស្ថានស្លឹករឹតនេះ» ។

វិទ្យាស្ថានស្លឹករឹតនឹងចងភ្ជាប់មូលដ្ឋានគ្រឹះនៃការអប់រំ និងកម្មវិធីផ្សព្វផ្សាយដ៏រឹងមាំជាមួយនឹងកិច្ចការដែលវិទ្យាស្ថានកំពុងធ្វើសព្វថ្ងៃសម្រាប់យុត្តិធម៌សង្គម និងវិមានរំឭកវិញ្ញាណក្ខន្ធរបស់សារមន្ទីរបូជនីយដ្ឋាន ។

ប្លង់របស់វិទ្យាស្ថានស្លឹករឹតត្រូវបានរចនាឡើងដោយមានសំណង់អគារឈើចំនួនប្រាំដែលលំនាំចេញពីកំពូលប្រាំនៃប្រាសាទអង្គរវត្ត ក្នុងនោះ ជាន់ផ្ទាល់ដីរបស់អគារទាំងប្រាំមានលក្ខណៈដាច់ពីគ្នា ប៉ុន្តែអគារទាំងនេះត្បាញបញ្ចូលគ្នា និងភ្ជាប់គ្នានៅជាន់ខាងលើដោយភ្ជាប់អគារនីមួយៗ អ្នកទស្សនា និស្សិត និងបុគ្គលិកបញ្ចូលគ្នានៅលើជាន់តែមួយ ។ ទីលាននៅលើជាន់ផ្ទាល់ដីទាំងមូលមានបណ្តោយ៨០ម៉ែត្រ និង ទទឹង៣០ម៉ែត្រ ចំណែកឯជាន់លំហលើដំបូលខាងលើមានបណ្តោយ៨៨ម៉ែត្រ និងទទឹង៣៨ម៉ែត្រ ហើយសំណង់វិទ្យាស្ថានស្លឹករឹតនេះមានកម្ពស់ចាប់ពី៣ទៅ៨ជាន់ ។

អគារនីមួយៗក្នុងចំណោមអគារទាំងប្រាំ មានមុខងារផ្សេងៗពីគ្នា រួមមាន វិទ្យាស្ថានស្លឹករឹត បណ្ណាល័យតម្កល់សមុច្ច័យដ៏ធំជាងគេបង្អស់នៅអាស៊ីភាគអាគ្នេយ៍សម្រាប់ឯកសារទាក់ទងនឹងរបបប្រល័យពូជសាសន៍ និងសាលាកម្រិតថ្នាក់ឧត្តមសិក្សាដែលផ្តោតជាសំខាន់ទៅលើការសិក្សាពីអំពើប្រល័យពូជសាសន៍ ជម្លោះនានា និងសិទ្ធិមនុស្ស ។ អគារផ្សេងទៀតគឺជាបណ្ណសារដ្ឋាន និងមជ្ឈមណ្ឌលស្រាវជ្រាវបង្កើតឡើងក្នុងគោលបំណងផ្តល់ឥទ្ធិពលដល់ការសម្រេចគោលនយោបាយជាតិ និងការផ្តល់យោបល់ដែលមានប្រយោជន៍នៅក្នុងតំបន់ ។ ក្នុងនោះដែរ ក៏មានមជ្ឈមណ្ឌលសារព័ត៌មាន និងសាលប្រជុំធំដែលបើកសម្រាប់វិទ្យាស្ថានទាំងមូល និងសម្រាប់សហគមន៍អាចចូលរួម ។

ស្ថាបត្យកម្មសម័យបុរាណនៃប្រាសាទអង្គរវត្ត និងប្រាសាទដទៃទៀតក្នុងសម័យអង្គរ ត្រូវបានសង់ឡើងដោយរួមបញ្ចូល និងភ្ជាប់គ្នាទៅវិញទៅមកនូវសមាសភាពជាច្រើនសណ្ឋានក្នុងវឌ្ឍនភាពនៃសំណង់ដែលភ្ជាប់គ្នាពីមួយទៅមួយ ។

នៅពេលដែលអគារទាំងប្រាំរបស់វិទ្យាស្ថានស្លឹករឹតកាន់តែឡើងខ្ពស់ទៅ ហើយភ្ជាប់គ្នា ទាំងអស់នោះ នឹងផ្តល់នូវអត្ថន័យមួយនៃសមាសភាពភ្ជាប់គ្នា និងទាក់ទងគ្នាទៅវិញទៅមកនៅលើលំហ បង្កើតឲ្យមានទីលានលំហជាច្រើនកន្លែងទាំងខាងក្នុង និងខាងក្រៅភ្ជាប់គ្នាទៅវិញមក ដែលអាចនាំអ្នកទស្សនាឆ្លងកាត់ទីកន្លែងផ្សេងៗពីគ្នាសម្រាប់ធ្វើការស្មិងស្មាធិ៍ រៀនសូត្រ ទំនាក់ទំនងពីអគារមួយទៅអគារមួយ និងការពិភាក្សា ។

ប្លង់រចនានេះភ្ជាប់សារមន្ទីរ បណ្ណាល័យ សាលារៀន និងវិទ្យាស្ថានស្លឹករឹតជាច្រើនជាន់ផ្សេងៗពីគ្នា ដែលអនុញ្ញាតឲ្យមនុស្សនៅក្នុងអគារនីមួយៗអាចធ្វើការទំនាក់ទំនង សហការគ្នា ដើម្បីបង្កើនការយល់ដឹង និងផ្លាស់ប្តូរបទពិសោធផ្សេងៗ ។ ក៏ប៉ុន្តែ ក្នុងករណីចាំបាច់ មុខងាររបស់ផ្នែកនីមួយៗអាចបង្កើតកម្មវិធីដោយឯករាជ្យដោយមិនមានការឡូកឡំពីផ្នែកផ្សេងបានឡើយ ។

ដោយសង់អំពីឈើមានគុណភាពខ្ពស់ (មកពីប្រទេសលោកខាងលិច ហើយដោយមិនប្រើប្រាស់ព្រៃឈើនៅកម្ពុជា) និងមាន

ស្ថិរភាពយូរអង្វែងរហូតដល់ទៅ១០០ឆ្នាំ ដែលសម្ភារសំណង់ចម្បងសម្រាប់អគារនេះ ស្រមោលផ្នែកខាងក្រៅ និងរបាំងផ្នែកខាងក្នុងផ្តល់នូវលក្ខណៈធម្មជាតិ ប្រកបដោយភាពរាក់ទាក់ និងរក្សានូវប្រពៃណីដើម ។ សណ្ឋានសមាសភាពសំណង់ជាច្រើនត្រូវបានរចនា និងបង្កើតឡើង ហេតុដូច្នេះ សំណង់ទាំងនោះអាចភ្ជាប់គ្នាតាមរយៈការប្រើប្រាស់ឈើត្រង់ និងឈើកោងទោលក្នុងលក្ខណៈសន្សំសំចៃជាមួយបច្ចេកវិទ្យាទំនើប ។

វិទ្យាស្ថានស៊ីកវិតមានទីតាំងនៅក្នុងបរិវេណវិទ្យាល័យបឹងត្របែក ផ្នែកខាងត្បូងនៃទីក្រុងភ្នំពេញ ។ សំណង់អគាររបស់វិទ្យាល័យនេះ (បច្ចុប្បន្នអគារនេះឈប់ប្រើប្រាស់ហើយក្រោយពីសិស្សត្រូវបានប្តូរទៅរៀននៅអគារផ្សេងក្បែរនោះ) ធ្លាប់បានប្រើប្រាស់ជាមន្ទីរលត់ដំ និងកែប្រែកាលពីរបបខ្មែរក្រហម ដូចអគារសាលារៀនផ្សេងៗទៀតទូទាំងប្រទេសដែរ ដែលធ្វើឲ្យទីតាំងនេះមានលក្ខណៈស័ក្តិសមយ៉ាងខ្លាំងសម្រាប់វិទ្យាស្ថានស៊ីកវិតនេះត្រង់ន័យថា សង់នៅលើអតីតកាលដើម្បីអប់រំអនាគត ។

ដើម្បីឲ្យស្របនឹងអាកាសធាតុត្រូពិករបស់ប្រទេសកម្ពុជា ប្រកតួបនៅជាន់ខាងក្រោមនៃវិទ្យាស្ថាននេះទទួលម្លប់ពីអគារទាំងមូល ចំណែកឯស្លាបព្រិលនៅជាន់ខាងលើទទួលពន្លឺថ្ងៃច្រើន ។ ដោយទទួលឥទ្ធិពលពីទន្លេមេគង្គ និងទន្លេសាប សំណង់របស់វិទ្យាស្ថានស៊ីកវិត នឹងសង់ឡើងខ្ពស់ផុតពីដីយ៉ាងហោចណាស់២ម៉ែត្រ ដើម្បីការពារទឹកជំនន់ដែលអាចកើតមាន ។

អ្នកទស្សនាអាចចូលទៅអគារតាមផ្លូវដែលសង់ឡើងក្បែរអាងទឹកដែលអាចមើលឆ្លុះតាមរយៈអាងទឹក និងអាចមើលឃើញសំណង់អគារនេះតាមការឆ្លុះពីអាងទឹក និងពន្លឺជ្រៅទៅក្នុងលំហខាងក្នុងទឹក ។ ដូចគ្នានឹងអាងទឹករបស់ប្រាសាទបុរាណខ្មែរមួយចំនួនរួមមាន ប្រាសាទអង្គរវត្ត និងស្រះស្រង់ អាងទឹកទាំងនេះ និងអាងទឹកនៅជាន់ខាងលើនៃសំណង់អគារនេះ នឹងអាចស្រូបទឹកភ្លៀងបាន និងមានសារសំខាន់ក្នុងការរក្សានូវដំណើរការគ្រប់គ្រងចរន្តទឹកដើម្បីកាត់បន្ថយឲ្យនៅចំនួនអតិបរមានៃប្រព័ន្ធលូបង្ហូរទឹក និងបរិស្ថានក្បែរនោះ ។

នៅពេលដើរកាត់បន្ទប់កណ្តាលរួមធំចូលទៅដល់កណ្តាលអគារ អ្នកទស្សនាត្រូវបានស្វាគមន៍ដោយពិព័រណ៍វត្ថុសិល្បៈផ្សេងៗដែលប្រមែប្រមូលដោយវិទ្យាស្ថានស៊ីកវិត ។ ចេញពីទីកន្លែងពិព័រណ៍នេះ អ្នកទស្សនានឹងត្រូវនាំទៅកាន់សារមន្ទីរ ដែលទីនោះមានការតាំងពិព័រណ៍ផ្សេងៗជាច្រើន និងបន្ទាប់មក អ្នកទស្សនាអាចធ្វើដំណើរទៅកាន់សាលារៀន និងសាលប្រជុំរួមធំបែបសហសម័យ ។ សាលប្រជុំរួមធំ មានទីតាំងនៅលើជាន់ផ្ទាល់ដី ចំណែកឯថ្នាក់រៀន និងបន្ទប់របស់សាស្ត្រាចារ្យមានទីតាំងនៅបរិវេណខាងក្រៅ និងបន្តទៅជាន់ខាងលើ ។

នៅខាងលើបន្ទប់កណ្តាលរួមធំ គឺជាទីតាំងរបស់បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារ ដែលមានការិយាល័យសម្រាប់អ្នកស្រាវជ្រាវ ចំណែកឯការិយាល័យរដ្ឋបាលរបស់វិទ្យាស្ថានស៊ីកវិតមានទីតាំងនៅជាន់លើបង្អស់ ។ ស្ពានមួយត្រូវបានភ្ជាប់ពីបន្ទប់កណ្តាលរួមទៅកាន់សាលារៀន និងបណ្ណាល័យ ។

ប្លង់រចនារបស់វិទ្យាស្ថានស៊ីកវិត នឹងបង្កើតមុខងារសម្រាប់ការពារបរិស្ថានរបស់អគារទាំងមូល រួមមាន វិធីសាស្ត្រក្នុងការកាត់បន្ថយថាមពល និងការប្រើប្រាស់ទឹក ព្រមទាំងការបង្កើតប្រភពថាមពលដែលអាចប្រើប្រាស់ឡើងវិញ ។

រូបរាងអគាររបស់វិទ្យាស្ថាន តម្រូវឲ្យមានការប្រើប្រាស់ប្រព័ន្ធស្រូបពន្លឺថ្ងៃឲ្យមានកម្រិតទាប ហើយម្លប់នៅផ្នែកខាងក្រៅ និងផ្លាស់ប្តូរតាមកម្ពស់អគារដើម្បីកាត់បន្ថយប្រព័ន្ធស្រូបពន្លឺថ្ងៃ ខណៈពេលដែលយើងរក្សានូវការទទួលពន្លឺថ្ងៃឲ្យបានគ្រប់គ្រាន់ ។ ទីតាំងដែលត្រូវប្រើប្រព័ន្ធការពារកម្តៅថ្ងៃគឺដើម្បីការពារបណ្ណសារ និងទីតាំងពិព័រណ៍ នឹងកាត់បន្ថយនូវការប្រើប្រាស់ថាមពល និងមានការប្រើប្រាស់ប្រព័ន្ធទាញយកទឹកពីក្នុងខ្យល់ដើម្បីយកមកប្រើប្រាស់នៅក្នុងអគារ ហើយទឹកដែលប្រើប្រាស់រួច និងត្រូវឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យនៅនឹងកន្លែងផ្ទាល់តាមរយៈប្រព័ន្ធរ៉ែអាក់ទើជីវសាស្ត្រ ឬប្រព័ន្ធចម្រោះទឹកកខ្វក់ដោយប្រើប្រាស់ដើមឈើធម្មជាតិដើម្បីចម្រោះ ។

ដំបូលរាបស្មើរបស់វិទ្យាស្ថាននេះត្រូវបានបិទជិត និងត្រូវប្រើប្រាស់ជាទីតាំងសម្រាប់បម្លែងថាមពលដែលមានប្រសិទ្ធភាពយ៉ាងខ្លាំងសម្រាប់អាកាសធាតុទីក្រុងភ្នំពេញ ដូចជា បន្ទប់សម្រាប់ទទួលថាមពលពីព្រះអាទិត្យ និងប្រព័ន្ធព្រះអាទិត្យសម្រាប់បម្លែងទឹកក្តៅ ។ ឧបករណ៍ផ្លាស់ប្តូរកម្តៅ ប្រព័ន្ធខ្យល់ និងដើមឈើក៏

មានទីតាំងនៅលើដីបូលនេះដែរ ដែលផ្តល់ផលប្រយោជន៍ដល់វិទ្យាស្ថាននេះ សម្រាប់ធ្វើពិធីសន្និសីទ កម្មវិធីអប់រំវប្បធម៌ និងកម្មវិធីសម្រាប់សហគមន៍ផ្សេងៗ ។

វិទ្យាស្ថានស្លឹករឹតក៏រួមបញ្ចូលទាំងវាលបូជនីយដ្ឋានរំឭកវិញ្ញាណក្ខន្ធមួយ ដែលមានទំហំ៦៨ពាន់ម៉ែត្រការ៉េ សម្រាប់សហគមន៍ទាំងមូលក្នុងរាជធានីភ្នំពេញ ដោយក្នុងនោះ រួមមាន វាលសម្រាប់លេងកីឡា សួនបន្លែ និង ចម្ការផ្លែឈើ វាលស្មៅ និងព្រៃឈើដែលនៅទីនោះ និងដាក់តាំងរូបសំណាកខ្មែរសម័យទំនើបដែលភាគច្រើនតំណាងឲ្យស្ត្រីដែលជាអ្នកកសាងប្រទេសឡើងវិញ ក្រោយសង្គ្រាម ។ សួនច្បារស្ថិតនៅត្រង់ជម្រាលចុះពីអគារដើម្បីផ្តល់នូវការការពារកុំឲ្យមានទឹកជំនន់ ។ ផ្នែកចុងខាងត្បូងនៃសួនច្បារ គឺជាទីវាលមួយដើម្បីស្តុកទឹកនារដូវភ្លៀងដើម្បីកាត់បន្ថយទឹកជំនន់នៅក្នុងទីក្រុង ។ នៅក្នុងសួនមានផ្លូវដើរជាច្រើនភ្ជាប់គ្នាទៅវិញទៅមក ដែលកាលពីមុនផ្លូវទាំងនេះមិនជាប់គ្នាទេ ។ ការភ្ជាប់ផ្លូវនេះគឺ ដើម្បីអនុញ្ញាតឲ្យប្រជាជនដែលរស់នៅក្បែរនេះអាចដើរចូលទៅដល់ផ្នែកខាងក្នុងនៃវិទ្យាស្ថានស្លឹករឹតបាន ។ ហ្សាហា ហាឌីដ បានមានប្រសាសន៍ថា «យើងមានក្តីសង្ឃឹមថា វិទ្យាស្ថានស្លឹករឹត និងសួនបូជនីយដ្ឋានរំឭកវិញ្ញាណក្ខន្ធនេះ និងមានឥទ្ធិពលនាំឲ្យមានការផ្លាស់ប្តូរបានយ៉ាងពិតប្រាកដ ដោយនាំជីវិតថ្មី និងអនាគតដ៏ភ្លឺស្វាងទៅកាន់តំបន់ធ្លាប់តែជាកន្លែងពោរពេញទៅដោយសោកនាដកម្មកាលពីអតីតកាល ។ ទីតាំងសម្រាប់សហគមន៍នេះ មិនគ្រាន់តែជាទីវាលមួយដែលបង្ហាញអំពីការឆ្លុះបញ្ចាំងពីអតីតកាល ការទាក់ទងគ្នាទៅវិញទៅមក និងការប្រាស្រ័យទាក់ទងគ្នានោះទេ តែក៏ជាកន្លែងមួយដែលបង្កប់នូវការសន្ទនាមួយចំពោះប្រជាជនកម្ពុជា» ។

អគាររបស់វិទ្យាស្ថានស្លឹករឹតត្រូវបានអនុម័តយល់ព្រមឲ្យសាងសង់ ហើយគ្រោងនឹងសាងសង់នៅលើទីតាំងវិទ្យាល័យបឹងត្របែកនេះនៅឆ្នាំក្រោយ ។

សម្រាប់ព័ត៌មានផ្សេងៗទាក់ទងនឹងវិទ្យាស្ថានស្លឹករឹត សូមទស្សនាគេហទំព័រ *www.cambodiasri.org*

## ប្រវត្តិសង្ខេប



លោក ឆាំង យុ គឺជាស្ថាបនិកមួយរូបរបស់វិទ្យាស្ថានស្លឹករឹត និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលត្រូវបានបង្កើតឡើងដោយសាកលវិទ្យាល័យយ៉េល ។ ឈ្មោះរបស់វិទ្យាស្ថាន “ស្លឹករឹត” មានន័យថា “អំណាចនៃស្លឹករុក្ខជាតិ” ។ អ្នកដឹកនាំសាសនា និងអ្នកស្រាវជ្រាវខ្មែរជាន់ខ្ពស់កាលពីជំនាន់ដើមបានប្រើប្រាស់ស្លឹករឹតនេះរាប់សតវត្សរ៍មកហើយ ដើម្បីកត់ត្រាព្រឹត្តិការណ៍

ប្រវត្តិសាស្ត្រសំខាន់ៗ ផ្សព្វផ្សាយចំណេះដឹង និងថែរក្សាវប្បធម៌ក្នុងអំឡុងយុគសម័យវឹកវរ និងហានិភ័យផ្សេងៗ ។ ស្លឹករឹត គឺជាស្លឹកទ្រាំង ។ ទ្រាំង **(Corypha umbraculifera)** គឺជាឈ្មោះតចសារព្រឹក្សមួយប្រភេទកម្ពស់ ៤ ទៅ ១០ម៉ែត្រ ។ ដើមមានវិជ្ជមាត្រពី ៥០ ទៅ ៦០សង់ទីម៉ែត្រ ដុះក្នុងព្រៃក្រាស់ល្មមក្នុងឧបទ្វីបឥណ្ឌូចិន ។ ស្លឹកទ្រាំងវែងជាងស្លឹកចតសារព្រឹក្សឯទៀតៗ ។ ធាងរបស់វាមានប្រវែងដល់ទៅ១៧ម៉ែត្រ ។ ស្លឹកនេះ ប្រើការពីដំនាន់ដើម សម្រាប់ចារសាស្ត្រា ហៅថា ស្លឹករឹត ដោយភិក្ខុសង្ឃ ។

ទ្រាំង គឺជាឈ្មោះស្រុកមួយក្នុងកម្ពុជរដ្ឋ, ឥឡូវចូលរួមក្នុងខេត្តតាកែវ ស្រុកទ្រាំងមាន២ គឺ ទ្រាំងត្រើយឯដើង, ទ្រាំងត្រើយត្បូងៗ សព្វថ្ងៃនេះជាអាណាខេត្តកូស័ងស៊ីន រាប់បញ្ចូលក្នុងខេត្តមាត់ជ្រូក (ចូដុក) ។

ស្លឹករឹត មានសេចក្តីពន្យល់ក្នុងវចនានុក្រម សម្តេចសង្ឃជួន ណាត នៅក្នុងពាក្យ “ទ្រាំង” ថា៖

ទ្រាំង (ន.) ឈ្មោះតចសារព្រឹក្សមួយប្រភេទ (សន្តានជ្រៃ) មានធាងវែងៗ មានស្លឹកប្រើការបានច្រើនយ៉ាងគឺ ប្រើការចារសាស្ត្រាហៅថា **ស្លឹករឹត,** ប្រើការដោយយកទ្រនុងស្លឹកវាច្រៀកធ្វើជាកន្ទាស់ដោតខ្ទាស់ស្លឹកខ្ចីៗ សៗ គ្របបន្តិចលើគ្នាឲ្យបានជាបន្ទះវែងៗ ធំៗ សម្រាប់ប្រក់ ឬបាំងហៅថា *ភ្លល់* (មិនជាប់យូរប៉ុន្មានទេ), ទោះត្បាញជាការុងឬសំពៀតជាដើមក៏ហៅថា *ភ្លល់* បានដែរ, បើចម្រៀកតូចត្បាញធ្វើជាក្តោងទូក ហៅថា ទទត់, ទ្រនុងដែលសកយកស្លឹកចេញហៅថា *ទ្រនុងរឹត* ឬ *ឆ្អឹងរឹត*, ធាងទុំដែលគេកាប់យកមកពុះហើយច្រាស់ ឬឈូសធ្វើជាវត្ថុផ្សេងៗ មានដំបង, ដាម, ព័ន្ធមូល (គ្រឿងតម្បាញ) ជាដើម ហៅថា ទ្រាំងដែរ ៖ ដំបងទ្រាំង, ដាមទ្រាំង, ព័ន្ធមូលទ្រាំង ។ ព.ទ.បុ. ទ្រាំងកំដរខ្មោច គេយកធាងទ្រាំងដែលគេធ្វើជាដាម ឬ ជាព័ន្ធមូលនោះមកចងភ្ជាប់ ឬខ្ទាស់នឹងការំជណ្តើរផ្ទះ ដោយជឿតាមទម្លាប់ថា ខ្មោចបិសាចខ្លាចទ្រាំង គេការពារមិនឲ្យខ្មោចបិសាចឡើងតាមជណ្តើរចូលក្នុងផ្ទះបាន ។ មនុស្សដែលខ្ជិលណាស់ ឬដែលល្ងង់ទុយមុយពេក ពេលយប់ដេកលក់មិនសូវដែលប្រែខ្លួន បានត្រឹមតែមកដេកកំដរកុំឲ្យតែខ្លាចខ្មោចបិសាចលងប៉ុណ្ណោះ, គេនិយាយថា ដូចគេយកទ្រាំងមកកំដរខ្មោច ។ ដើមទ្រាំងនេះច្រើនដុះពីគ្រាប់វាក្នុងព្រៃធំៗ ក្នុងប្រទេសកម្ពុជា មានខែត្រក្រចេះ និងខែត្រកំពង់ធំច្រើនជាងខែត្រឯទៀត, ជាតចសារព្រឹក្សមានប្រយោជន៍ច្រើន, គេអាចដាំតាមព្រាំវត្តអារាមក៏បាន មិនសូវរើសដីប៉ុន្មានទេ, រស់នៅបានយូរឆ្នាំ វែងឆ្ងាយជាងអាយុមនុស្សអ្នកមានអាយុវែង, ប៉ុន្តែលុះដល់កំណត់កាល ក៏បញ្ចេញផ្លែផ្កាជាធ្លាយ ដូចផ្លែចាក, លុះផ្លែទុំហើយ តចសារព្រឹក្សនេះក៏ងាប់, រាប់ថាជារុក្ខជាតិបញ្ចេញផ្កាផ្លែសម្លាប់ដើម, សមដូចព្រះពុទ្ធភាសិតថា តចសារជាតិមានឫស្សី, បបុស, ត្រែង, ទ្រាំង ជាដើមបញ្ចេញផ្កាផ្លែសម្លាប់ដើមវាយ៉ាងណា, លាភៈសក្ការៈពុំជា សម្លាប់មនុស្សលោភ លាមកតក់ម៉ក់អាក្រក់ក្រៃ ក៏មានឧបមេយ្យដូច្នេះដែរ

វិទ្យាស្ថានស្លឹករឹតនឹងសង់នៅក្នុងបរិវេណអគារសិក្សាមួយដែលមិនបានធ្វើការជួសជុលជាយូរមកហើយ ។

វិទ្យាស្ថានស្លឹករឹតត្រូវបានទទួលស្គាល់ជាផ្លូវការជាសាកលវិទ្យាល័យ ក្នុងនាមជាវិទ្យាស្ថានឧត្តមសិក្សាសាធារណៈមួយនៅប្រទេសកម្ពុជា ។ ការសាងសង់វិទ្យាស្ថានស្លឹករឹតត្រូវបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រទេសជាច្រើនដែលមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។

វិទ្យាស្ថានស្លឹករឹតសូមថ្លែងអំណរគុណដល់និស្សិតបុរាណវិទ្យា និងនិស្សិតស្ថាបត្យកម្ម រួមទាំងលោកសាស្ត្រាចារ្យ គង់ កុសល និងលោកសាស្ត្រាចារ្យ ឆាយ កាណូ នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សម្រាប់ការគាំទ្រទាំងឡាយដែលនាំឲ្យគម្រោងនេះចេញជារូបរាងឡើង ។

គេហទំព័ររបស់វិទ្យាស្ថានស្លឹករឹត *www.cambodiasri.org* ត្រូវបានរចនាដោយក្រុមហ៊ុន *Beaconfire* មានមូលដ្ឋាននៅទីក្រុង *Washington DC* ដែលបានជួយអង្គការ និងសហគ្រិនជាច្រើនរចនាគេហទំព័រ និងយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល ។ ការរចនាគេហទំព័រនេះត្រូវបានផ្តល់ការគាំទ្រដោយក្រសួងសហប្រតិបត្តិការ និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ តាមរយៈសេវាពលរដ្ឋសន្តិភាព នៃ *Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH* និង ទីភ្នាក់ងារសហរដ្ឋអាមេរិកអភិវឌ្ឍន៍អន្តរជាតិ *(USAID)* ។

**ឆាំង យុ**













# ពិធីសម្ពោធរចនាប្លង់របស់វិទ្យាស្ថានស្លឹករឹត

## វិចិត្រសាលរបស់ក្រុមហ៊ុន ហ្សាហា ហាឌីដ ទីក្រុងឡុងដ៍

សូមគោរពភ្ញៀវកិត្តិយសទាំងអស់ដែលបានចូលរួមក្នុងកម្មវិធីនេះ នៅពេលនេះ ។ តំណាងឲ្យវិទ្យាស្ថានស្លឹករឹត និងក្នុងនាមជាស្ថាបនិករបស់វិទ្យាស្ថាននេះ ខ្ញុំសូមសម្តែងនូវសេចក្តីរីករាយ និងពេញចិត្តឥតឧបមាសម្រាប់វត្តមានរបស់អស់លោក លោកស្រី ដែលបានចំណាយពេលដ៏មានតម្លៃចូលរួមកម្មវិធីដ៏មានសារសំខាន់មួយនេះ ដើម្បីធ្វើការបង្ហាញនូវគម្រោងប្លង់រចនារបស់វិទ្យាស្ថានស្លឹករឹត ដែលរចនាដោយលោកស្រី ហ្សាហា ហាឌីដ និងក្រុមការងារស្ថាបត្យកររបស់លោកស្រី ។

ឈ្មោះរបស់វិទ្យាស្ថានថ្មីនេះឆ្លុះបញ្ចាំងអំពីគោលដៅចម្បងរបស់យើង និងសម្រាប់ជាកេរដំណែលរបស់កម្ពុជាទាំងមូល ។ ស្លឹករឹត គឺជាស្លឹករុក្ខជាតិស្ងួតម្យ៉ាងដែលអ្នកដឹកនាំសាសនា និងអ្នកស្រាវជ្រាវខ្មែរជាន់ខ្ពស់កាលពីជំនាន់ដើមបានប្រើប្រាស់រាប់សតវត្សរ៍មកហើយដើម្បីកត់ត្រាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ផ្សព្វផ្សាយចំណេះដឹង និងថែរក្សាវប្បធម៌ក្នុងអំឡុងយុគសម័យវិករវរ និងហានិភ័យផ្សេងៗ ។ ពាក្យ "ស្លឹករឹត" មានន័យជាសំឡេងថា ជា "អំណាចនៃស្លឹករុក្ខជាតិ" ដោយចាប់យកនូវសោភណ្ឌភាពដ៏ស្រស់បំព្រងជាយានៃចំណេះដឹង និងភាពរឹងមាំក្នុងការធ្វើឲ្យមានការរីកចម្រើនទៅមុខនៃយុត្តិធម៌សង្គម និងសេចក្តីថ្លៃថ្នូរបស់មនុស្ស ។

វិទ្យាស្ថានស្លឹករឹត ដែលរួមមាន សារមន្ទីរ មជ្ឈមណ្ឌលស្រាវជ្រាវ ព្រមទាំងសាលារៀន និងតំណាងឲ្យអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។ ដោយបន្តកិច្ចការងារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើសព្វថ្ងៃ វិទ្យាស្ថានស្លឹករឹតនឹងសម្លឹងទៅរកគំនិតច្នៃប្រឌិត និងកម្មវិធីនានាដែលអាចប្រើប្រាស់បាននាថ្ងៃអនាគតដើម្បីលើកកម្ពស់ការយល់ដឹងនៃប្រវត្តិសាស្ត្រខ្មែរក្រហម និងសង្គមកម្ពុជាទាំងមូល ។ លើសពីនេះទៀត ដោយមានចក្ខុវិស័យសម្លឹងទៅមុខ វិទ្យាស្ថានស្លឹករឹតនឹងគាំទ្រ និងទទួលយកនូវយោបល់ និងគំនិតតម្រង់ទិសថ្មីៗ ដែលជួយតម្រែតម្រង់ការយល់ឃើញរបស់យើងទាក់ទងនឹងទស្សនៈនៃភាពយុត្តិធម៌ និងដើម្បីលើកតម្កើងកិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការតស៊ូជាលក្ខណៈសកលលោកដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍និងអំពើឃោរឃៅទ្រង់ទ្រាយធំនានា ។

គំនិតតម្រង់ទិសមួយដែលពាក់ព័ន្ធយ៉ាងខ្លាំងនឹងព្រឹត្តិការណ៍នៅល្ងាចនេះគឺទាក់ទងទៅនឹងបូជនីយដ្ឋានបែបស្ថាបត្យកម្ម ។ បូជនីយដ្ឋានបែបស្ថាបត្យកម្មគឺជាគំនិតដ៏ថ្មីសន្លាងមួយ ។ យើងអាចឃើញបូជនីយដ្ឋាននៅគ្រប់ទីកន្លែងទូទាំងពិភពលោក ទាំងបូជនីយដ្ឋានបែបទំនើប និងបែបបុរាណ ដែលអាចផ្តល់ឱកាសដល់សង្គមមួយឲ្យមានការចងចាំ ឆ្លុះបញ្ចាំង និងរៀនអំពីប្រវត្តិសាស្ត្រ ។ នៅក្នុងបុព្វបទនៃអំពើប្រល័យពូជសាសន៍ និងអំពើកាប់សម្លាប់ទ្រង់ទ្រាយធំ បូជនីយដ្ឋានស្ថាបត្យកម្មមានទំនោរទៅរកការឆ្លុះបញ្ចាំងពីភាពអាក្រក់ និងភាពអកុសលនៃសម័យកាលប្រវត្តិសាស្ត្រណាមួយដែលស្ថាបត្យកម្មនោះតំណាងឲ្យ ។ នៅក្នុងន័យនេះ កេរដំណែលរបស់ស្ថាបត្យកម្មគឺស្ថិតក្នុងសភាពងងឹត ស្រងូតស្រងាត់ និងតម្រង់ទៅរកអតីតកាល ។

អ្នកទស្សនាទាំងឡាយតែងតែបន្សល់ទុកចំពោះបូជនីយដ្ឋានប្រភេទនេះនូវការយល់ដឹងយ៉ាងជ្រៅជ្រះអំពីការទទួលរងទុក្ខ និងភាពឈឺចាប់ដែលមិនអាចបរិយាយបានរបស់មនុស្សជាតិ ហើយការទទួលស្គាល់នូវភាពឈឺចាប់ ក៏កាន់តែមានកម្រិតខ្ពស់ឡើងសម្រាប់តម្រូវការដើម្បីទាមទារឲ្យមានការបន្សល់ទុកច្រើនជាងនេះ ។ ដោយគ្មានអ្វីដែលជាការមន្ទិលសង្ស័យ អារម្មណ៍ និងអាកប្បកិរិយាបែបនេះ អាចជាឧបសគ្គមួយចំពោះកិច្ចខិតខំតស៊ូរបស់យើងក្នុងការប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ និងការកាប់សម្លាប់ទ្រង់ទ្រាយធំ ។ មនុស្សជាតិមិនអាចរំពឹងថា នឹងទទួលបាននូវភាពត្រឹមត្រូវក្នុងកម្រិតខ្ពស់នោះបានទេ លុះត្រាតែបុគ្គលនីមួយៗមានទំនោរទៅរកភាពអាក្រក់ដ៏ជាក់ច្បាស់ក្នុងកម្រិតទាប ។ ក៏ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអស់នេះ មិនមែនសំដៅទៅលើ

អតីតកាលតែមួយមុខនោះទេ ការពុះពារតស៊ូនេះ គឺសម្រាប់បច្ចុប្បន្នកាល និងអនាគតកាលដោយផ្តល់ផលប្រយោជន៍គ្រប់ផ្នែកទាំងអស់នៅក្នុងប្រទេសកម្ពុជា និងទូទាំងសកលលោក ។ ស្ថាបត្យកម្មបែបបូជនីយដ្ឋាន ផ្តល់ឲ្យយើងនូវអំណាច មិនត្រឹមតែដើម្បីធ្វើឲ្យមានអន្តរកម្មជាមួយពេលវេលា និងទីកន្លែងប៉ុណ្ណោះទេ តែដើម្បីធ្វើអន្តរកម្មជាមួយក្តីស្រមើស្រមៃរបស់យើងដែរ ។ ដោយចក្ខុម្ខាងសម្លឹងទៅរកអតីតកាល ស្ថាបត្យកម្មបែបបូជនីយដ្ឋាន អាចធ្វើការអប់រំ និងរំឮកអំពីអតីតកាល និងចក្ខុម្ខាងទៀតសម្លឹងទៅរកបច្ចុប្បន្នកាល និងអនាគតកាល ស្ថាបត្យកម្មបែបបូជនីយដ្ឋានក៏នឹងអាចបណ្តុះគំនិត និងបង្កើតអ្វីដែលថ្មីៗដែរ ។

ជាដៃគូយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនស្ថាបត្យកម្ម ហ្សាហាហាឌីដ ដែលមានកេរ្តិ៍ឈ្មោះល្បីសុះសាយទូទាំងសាកលលោក វិទ្យាស្ថានស្លឹករឹតមានមោទកភាព និងរក្សាទស្សនវិស័យទាំងនេះនៅក្នុងការរចនាប្លង់របស់វិទ្យាស្ថានយើង ។

ពាក្យពេចន៍ និងគំនិតអាចបង្កើត និងកែទម្រង់រដ្ឋទាំងឡាយបានហើយការជួបផ្សំគ្នាដោយភាពប៉ិនប្រសប់នៃភាសា និងសិល្បៈអាចធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងទម្រង់ការងារក្នុងលក្ខណៈទ្រង់ទ្រាយធំក្នុងការកសាងសង្គមក្រោយជម្លោះឡើងវិញ ។ តាំងពីឆ្នាំ១៩៧៩មក នៅពេលដែលរបបខ្មែរក្រហមដួលរលំ កម្ពុជាត្រូវបានឲ្យឈ្មោះថាជា »វាលពិឃាត« និងជាទឹកដីនៃអំពើប្រល័យពូជសាសន៍ សង្គ្រាម និងខ្មែរក្រហម ។ កម្ពុជានឹងមិនអាចគេចពីប្រវត្តិសាស្ត្ររបស់ខ្លួនបានទេ ក៏ប៉ុន្តែ កម្ពុជាក៏មិនត្រូវជាទាសករនៃអតីតកាលនោះរហូតដែរ ។ សង្គមក្រោយជម្លោះត្រូវតែធ្វើដំណើរនិងអភិវឌ្ឍន៍ទៅមុខ ។ តាមរយៈសិល្បៈ តន្ត្រី និងការបង្ហាញពីវប្បធម៌ដ៏ទូលំទូលាយ សង្គមក្រោយជម្លោះនឹងអាចកែប្រែ និង ផ្លាស់ប្តូរនិយមន័យជាលក្ខណៈបុគ្គល សហគមន៍ និងអត្តសញ្ញាណជាតិពីផ្នត់គំនិតដែលគិតអំពីជនរងគ្រោះ និងជនដែលដល់ទៅជាមនុស្សជាតិដែលមានទស្សនវិស័យ និងធ្វើការដើម្បីភាពប្រសើរឡើងនៅថ្ងៃស្អែក ។

ពិភពលោករបស់យើងមិនមែនជាតថភាពដែលពិបាកនឹងធ្វើការផ្លាស់ប្តូរនោះទេ ប៉ុន្តែជាតថភាពដែលឋិតក្នុងដំណាក់កាលផ្លាស់ប្តូរ ដែលបន្តកើតមានជានិច្ច ។ សង្គមក្រោយជម្លោះមិនត្រូវកប់ចោលអតីតកាលរបស់ខ្លួននោះទេ តែផ្ទុយមកវិញ សង្គមទាំងនោះ ក៏មិនត្រូវបន្តរស់នៅក្នុងអតីតកាលនោះរហូតដែរ ។ នៅពេលដែលភាពភ័យខ្លាច អំពើឃោរឃៅ អំពើជិះជាន់ និងអំពើអាក្រក់ត្រូវតែកប់ចោលនោះ ដែលធ្វើបែបនេះ ក្មេងជំនាន់ក្រោយនៃសតវត្សរ៍ទី២១នេះដឹង និងយល់អំពីជម្រៅនៃអំពើអាក្រក់ មេត្តាធម៌ ក្តីសង្ឃឹម ការអភ័យទោស និងភាពក្លាហានក៏នឹងចង្អុលបង្ហាញនូវទស្សនវិស័យទូទៅរបស់យើងដែរ ។ ហេតុដូច្នេះ សង្គមក្រោយជម្លោះត្រូវរកឲ្យឃើញនូវមូលហេតុសំខាន់ៗមួយ នៅក្នុងអំពើជ្រុលហួសហេតុទាំងនោះ ប្រសិនបើសង្គមនោះចង់ធ្វើដំណើរទៅមុខទៀតនោះ ។

ហ៊ុមព័ទ្ធជុំវិញដោយភាពជ្រុលហួសហេតុដែលអាចកើតមានរបស់មនុស្សជាតិ វាមានភាពងាយស្រួលណាស់សម្រាប់សង្គមក្រោយជម្លោះក្នុងការប្រទាញប្រទង់គ្នាទៅវិញទៅមកដូចទៅនឹងការយោលទៅយោលមករបស់ទ្រនិចនាឡិកាប៉ោលដែររវាងការដាក់ទោសទណ្ឌ និងការលើកលែងទោស រវាងសោកណ្ឌភាព និងភាពភ័យខ្លាច និងរវាងឋានលើ និងឋានក្រោមនៃជីវិតរបស់មនុស្សលោក ។ ការទម្លាយវដ្តនៃអំពើហិង្សាដែលមានលក្ខណៈជាប្រវត្តិសាស្ត្រតម្រូវឲ្យមាន មិនត្រឹមតែក្តីស្រលាញ់ ក្តីសង្ឃឹម និងការអភ័យទោសប៉ុណ្ណោះទេ តែក៏ត្រូវឲ្យមានការកត់ត្រារឿងរ៉ាវពីអតីតកាលប្រកបដោយតុល្យភាពដែរ ។ ដូចគ្នានេះដែរ ខណៈពេលដែលអតីតកាលក្លាយជាមគ្គុទ្ទេសក៍នាំផ្លូវរបស់យើង យើងត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្នុងការទប់ស្កាត់អតីតកាលនោះដើម្បីកុំឲ្យអតីតកាលក្លាយជាចៅហ្វាយនាយដែលអាចដឹកមុខយើងបាន ។

ស្ថាបត្យកម្មបែបបូជនីយដ្ឋាន ផ្តល់ឲ្យយើងនូវមធ្យោបាយមួយដែលអាចធ្វើឲ្យយើងសម្លឹងមើលនូវលក្ខខណ្ឌ និងភាពសក្តានុពលរបស់យើង ។ នៅក្នុងន័យនេះ សិល្បៈអាចផ្តល់ឲ្យយើងនូវហេតុផលសំខាន់ៗមួយដែលអាចធ្វើឲ្យយើងផ្សារភ្ជាប់អតីតកាលរបស់យើងនឹងបច្ចុប្បន្នកាល និងអនាគតកាល និងក្តីស្រមៃដោយតថភាព ។

វិទ្យាស្ថានស្លឹករឹតចាត់ទុកហេតុផលរួមនេះ ជាគោលបំណងមួយមិនអាចខ្វះបាននៃការកែប្រែរបស់សង្គមក្រោយជម្លោះ ហើយវិទ្យាស្ថានស្លឹករឹតសូមស្វាគមន៍នូវការគាំទ្ររបស់អស់លោកអ្នកក្នុងកិច្ចខិតខំប្រឹងប្រែងដ៏ធំមួយនេះ ។ **ឆាំង យុ**










ស្លឹករឹត



# សុន្ទរកថា
# រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា
# ស្តីពីការសម្ពោធការរៀបចំរចនាបថអគារវិទ្យាស្ថានស្ល៊ីករីត
# សាលតាំងពិព័រណ៍ ហ្សាហា ហាឌីដ ទីក្រុងឡុងដ៍
# ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤

សួស្តី លោកស្រី ហ្សាហា ហាឌីដ ភ្ញៀវកិត្តិយស លោក លោកស្រី អ្នកនាង កញ្ញា ជាទីគោរព ។ តំណាងឲ្យរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមសម្តែងសេចក្តីពេញចិត្តចំពោះវត្តមានរបស់ភ្ញៀវកិត្តិយស ដែលមានវត្តមាននៅក្នុងកម្មវិធីសម្ពោធការរៀបចំរចនាបថអគារវិទ្យាស្ថានស្ល៊ីករីត ដែលមានភាពអស្ចារ្យ និងបណ្តុះគំនិតថ្មីនេះ ។ ខ្ញុំមានគម្រោងចូលរួមក្នុងកម្មវិធីដ៏សំខាន់នេះ ប៉ុន្តែដោយសារតែខ្ញុំមានកាតព្វកិច្ចបន្ទាន់នៅក្នុងប្រទេសកម្ពុជា ធ្វើឲ្យខ្ញុំមិនអាចចូលរួមដោយផ្ទាល់បាន ។



ឯកឧត្តម ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ដូចលោក លោកស្រី បានជ្រាបហើយថា ប្រទេសកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍន៍តូចមួយ ដែលទើបតែងើបចេញពីការគ្រប់គ្រងរបស់អាណានិគមដ៏យូរលង់ និងកេរដំណែលដ៏ឃោរឃៅនៃរបបខ្មែរក្រហម ។ ទោះបីជាសេដ្ឋកិច្ចរបស់យើងមានភាពរីកចម្រើន ប៉ុន្តែប្រជាជនកម្ពុជាជាច្រើននៅតែបន្តរស់នៅក្នុងភាពក្រីក្រ ។ រាជរដ្ឋាភិបាលមានចំណូលមិនគ្រប់គ្រាន់សម្រាប់ឆ្លើយតបនឹងតម្រូវការចំពោះមុខជាច្រើន ដែលចាំបាច់ត្រូវតែដោះស្រាយ ។ តម្រូវការមួយក្នុងចំណោមនោះគឺ អប់រំយុវវ័យជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រ និងមេរៀនពីរបបខ្មែរក្រហម និងកេរដំណែលដ៏ខ្មៅងងឹតនេះ ។ យើងចាំបាច់ ត្រូវតែពង្រីកការអប់រំនេះឲ្យធំទូលាយ និងរួមបញ្ចូលទាំងវប្បធម៌ និងប្រវត្តិសិល្បៈដ៏រុងរឿងរបស់ប្រទេសកម្ពុជា ។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា មានឱកាសដែលបានសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបង្កើតកម្មវិធីអប់រំអំពីអំពើប្រល័យពូជសាសន៍ដ៏មានប្រសិទ្ធភាពនៅក្នុងសាលារៀនទូទាំងប្រទេសកម្ពុជា និងនៅតាមតំបន់ដាច់ស្រយាល ។

ការសម្ពោធការរៀបចំរចនាបថអគារវិទ្យាស្ថានស្ល៊ីករីត ដែលជាគម្រោងសំខាន់ថ្មីនេះ តំណាងឲ្យកិច្ចសហប្រតិបត្តិការដំណាក់កាលទី២ និងជាបន្តបន្ទាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ។ ខ្ញុំមានសេចក្តីសោមនស្សរីករាយនឹងជម្រាបជូនថា រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការយ៉ាង



ប្លង់អគារវិទ្យាស្ថានស្លឹករឹត ត្រូវបានដាក់សម្ពោធ នៅការិយាល័យក្រុមហ៊ុន ហ្សាហា ហាឌីដ ក្នុងទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤

ជិតស្និទ្ធជាមួយនឹងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលផ្តល់ដីដ៏ធំមួយកន្លែងនៅទីប្រជុំជននៃទីក្រុងភ្នំពេញ សម្រាប់សាងសង់វិទ្យាស្ថានស្លឹករឹត ។ ដីដ៏មានតម្លៃមួយកន្លែងនោះ មានទំហំល្មមសម្រាប់ការរៀបចំ និងបង្កើតបរិយាកាសដ៏ស្រស់ស្អាតនៅជុំវិញអគារ ។ អគារដ៏ពិសេស និងទីធ្លាដ៏ស្អាតនេះ នឹងដើរតួជាកន្លែងរំឭកដល់ជនរងគ្រោះ ដែលនៅរស់រានមានជីវិត និងអ្នកដែលបានបាត់បង់ជីវិតដោយអំពើប្រល័យពូជសាសន៍ ។

រាជរដ្ឋាភិបាលកម្ពុជា នឹងសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធានាថា វិទ្យាស្ថានស្លឹករឹត នឹងទទួលបានការទទួលស្គាល់ជាអន្តរជាតិថា ជាវិទ្យាស្ថានអប់រំអំពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស នាំមុខគេនៅសតវត្សរ៍ទី២១ ។ នេះមិនមែនជាសកម្មភាពធម្មតាទេ ប៉ុន្តែជាសកម្មភាពដ៏សំខាន់ដើម្បីរំឭកដល់ជនរងគ្រោះនៃរបបខ្មែរក្រហមដ៏សាហាវឃោរឃៅ ។ យើងសូមស្វាគមន៍ និងអរគុណចំពោះការគាំទ្រ និងអរគុណដល់សហគមន៍អន្តរជាតិ ដែលធ្វើការជាមួយគ្នា ដើម្បីសម្រេចបានគោលដៅនេះ ។ យើងរំពឹងថា វិទ្យាស្ថានស្លឹករឹត នឹងសហការជាមួយប្រទេសផ្សេងទៀតនៅតំបន់អាស៊ាន ដើម្បីផ្សព្វផ្សាយ និងស្វែងរកវិធីសាស្ត្រដើម្បីបញ្ចប់ការរំលោភសិទ្ធិមនុស្សដោយក្រុមហិង្សា និងក្រុមជ្រុលនិយម ទាំងនៅក្នុង និងក្រៅជួររដ្ឋាភិបាល ។ ឧក្រិដ្ឋកម្មសង្គ្រាមដ៏ឃោរឃៅ ការរំលោភសេពសន្ថវៈទៅលើស្ត្រី និងកុមារ ការសម្លាប់ និងការធ្វើទារុណកម្មលើជនស្លូតត្រង់កំពុងតែកើតឡើងជាបន្តបន្ទាប់នៅប្រទេសមួយចំនួនដូចជា ភូមា ស៊ីរី អ៊ីរ៉ាក់ សាធារណរដ្ឋអាហ្វ្រិកកណ្តាល ស៊ូដង់ខាងត្បូង លីប៊ី នីសេរីយ៉ា សូម៉ាលី អ៊ុយក្រែន កាហ្សា និងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ។ មនុស្សមានភាពឆ្លាតវៃជាងគេដែលអាចបង្កើតលោក ដូច្នេះ មិនមានហេតុផលណាមួយដែលធ្វើឲ្យមនុស្សធ្វើសកម្មភាពបំផ្លាញខ្លួនឯងដែលបំផ្លាញដល់មនុស្សជាតិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សនោះទេ ។

យើងសង្ឃឹមថា ជាមួយនឹងការបង្កើតវិទ្យាស្ថានស្លឹករឹត ប្រទេសកម្ពុជានឹងដើរតួនាទីជាអ្នកដឹកនាំមនុស្សនៅក្នុងពិភពលោក តាមរយៈការបង្ហាញពីការលំបាក មេរៀនដ៏ឈឺចាប់ និងសារសំខាន់ក្នុងការចងក្រងឯកសារ និងផ្សព្វផ្សាយដែលប្រកបដោយវិជ្ជាជីវៈ និងភាពសមរម្យ ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ យើងស្នើសុំ និងទទួលស្គាល់ការគាំទ្រជាសមូហភាព និងអំពើល្អរបស់អ្នកទាំងអស់គ្នា ។ សូមអរគុណ ។

**បណ្ឌិត ហង់ ជួន ណារ៉ុន**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**និងជាសាស្ត្រាចារ្យច្បាប់អន្តរជាតិ**
**ព្រះរាជាណាចក្រកម្ពុជា**

# ធ្វើការច្រើន ទទួលផលច្រើន តែចំណាយទុនតិច

***ដកស្រង់ចេញពីឯកសារទស្សនាវដ្តី D២១៣៨៨***

នេះជាពាក្យស្លោកថ្មី ដែលមិត្តយុវជន យុវនារីបដិវត្តន៍យើង នៅក្នុងកងទ័ព នៅតាមគ្រប់មន្ទីរ ក្រសួង ការដ្ឋានកសិដ្ឋាន តាមគ្រប់រោងចក្រ និងតាមគ្រប់សហករណ៍ ត្រូវយកចិត្តទុកដាក់អនុវត្តជាក់ស្តែង ក្នុងការងារប្រចាំថ្ងៃ ក៏ដូចក្នុងការរស់នៅ ឲ្យបានទៀងទាត់ហ្មត់ចត់ ដើម្បីវាយសម្រុកការពារប្រទេស និងកសាងប្រទេសឲ្យចម្រើនលូតលាស់ មហាលោតផ្លោះ មហាអស្ចារ្យ ។

សូមរំឭកថា នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដែលកងទ័ពបដិវត្តន៍កម្ពុជា និងប្រជាជនកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវមហាភ្លឺស្វាងនៃបក្សកុម្មុយនីស្តដ៏រុងរឿង បានរំដោះមាតុភូមិកម្ពុជាទាំងស្រុង និងជាស្ថាពរ ។ ព្រមជាមួយគ្នានេះ យើងក៏បានសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ប្រកបដោយជោគជ័យទាំងស្រុងដែរ ។ យើងក៏បានធ្វើបដិវត្តន៍សង្គមនិយមបានមួយជំហានធំហើយដែរ ។ ឧទាហរណ៍ដូចជា រដ្ឋក្តាប់សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងពាណិជ្ជកម្មនៅក្នុងតំបន់រំដោះទាំងស្រុង ការចាត់តាំងសហករណ៍ផលិតកម្មកម្រិតទាប កម្រិតខ្ពស់ ដើម្បីវាយកម្ចាត់របបកម្មសិទ្ធិឯកជន នៅទូទាំងតំបន់រំដោះប្រភេទទី១ និងនៅក្នុងតំបន់រំដោះប្រភេទទី២ មួយផ្នែក



កងភ្ជួរ កំពុងភ្ជួរស្រែនៅក្នុងរបបខ្មែរក្រហម

ធំទៀត ។ល ។ ដូច្នេះ បច្ចុប្បន្ននេះ យើងបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាជាបន្តទៀត ។ នេះជាកិត្តិយសរុងរឿងថ្លៃថ្លាណាស់របស់យុវជន យុវនារីបដិវត្តន៍យើងជំនាន់នេះ ដែលបានធ្វើសង្គ្រាមរំដោះជាតិ រំដោះប្រជាជន ដោយដៃផ្ទាល់ ហើយបានទាន់ការកសាងប្រទេសជាតិ ពោលគឺកសាងសង្គមនិយម នៅកម្ពុជាដោយផ្ទាល់ដៃទៀត ។ តែយើងត្រូវឃើញថា នេះក៏ជាភារកិច្ចដ៏ធ្ងន់ធ្ងររបស់យុវជន យុវនារីបដិវត្តន៍យើងជំនាន់នេះដែរ ព្រោះយើងត្រូវបន្តវាយកម្ទេចរបបគ្រប់គ្រងចាស់ ដែលជារបបជិះជាន់របស់ចក្រពត្តិ សក្តិភូមិ នាយទុន ដែលមានមូលដ្ឋានរឹងប៉ឹង ហើយចាក់ឫសជ្រៅទៅក្នុងសង្គមជាតិកម្ពុជាជាង២០០០ឆ្នាំមកហើយ ។

យើងត្រូវវាយកម្ទេចវា ទាំងវណ្ណៈ ទាំងរបបនយោបាយ ទាំងមូលដ្ឋានសេដ្ឋកិច្ច ទាំងមនោគមន៍វិជ្ជា ទាំងលោកទស្សនៈ ទាំងទស្សនៈគោលជំហរ សតិអារម្មណ៍ ឲ្យវិនាសសាបសូន្យអស់ពីក្នុងសង្គមជាតិយើងទាំងមូល ពីក្នុងជួរបដិវត្តន៍ទាំងមូល ពីក្នុងជួរប្រជាជនទាំងមូល ពីក្នុងជួរកងទ័ពទាំងមូល ពីក្នុងជួរយុវជន យុវនារីបដិវត្តន៍ទាំងមូល ព្រមទាំងពីក្នុងខ្លួនយើងម្នាក់ៗផង ។ ព្រមជាមួយនេះ យើងត្រូវកសាងសង្គមនិយមកម្ពុជា ដែលជារបបគ្រប់គ្រងថ្មីសន្លាងមួយពុំធ្លាប់ដែលមានទេ នៅក្នុងសង្គមកម្ពុជាយើង តាំងពីដើមមក ។ ឃើញភារកិច្ចរុងរឿងឧត្តុង្គឧត្តម តែធ្ងន់ធ្ងរណាស់ចំពោះយើងយ៉ាងនេះ យុវជន យុវនារីបដិវត្តន៍យើង ចាំបាច់ត្រូវបន្តធ្វើការតស៊ូយូរអង្វែង ទ្រាំទ្រលំបាកវេទនាសព្វបែបយ៉ាង ដោយឥតលក្ខខណ្ឌតទៅទៀត ត្រូវលះបង់ខ្ពស់ និងដោយឥតលក្ខខណ្ឌជាបន្តទៀត ត្រូវប្រយុទ្ធតឹងតែងស្វិតស្វាញតទៅទៀត ទើបយើងសម្រេចបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជា ដោយជោគជ័យធំៗថ្មីទៀតបាន ។

យើងចង់កសាងសង្គមនិយមនៅកម្ពុជា ឲ្យបានជោគជ័យទាំងស្រុង ដោយជំហានមហាលោតផ្លោះ មហាអស្ចារ្យ ដោយឈរលើគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទុកដាក់ខ្លួន ជាសំខាន់បំផុត ។ ដើម្បីធ្វើយ៉ាងនេះទៅបាន ទន្ទឹមនឹងការពង្រឹងគោលជំហរបដិវត្តន៍ទាំងប៉ុន្មានខាងលើនេះ យុវជន យុវនារីបដិវត្តន៍យើង នៅចាំបាច់ត្រូវយកចិត្តទុកដាក់ បំផុសចលនាសន្សំសំចៃបដិវត្តន៍ឲ្យខ្ពស់បំផុតនៅតាមគ្រប់មន្ទីរ គ្រប់ក្រសួង គ្រប់ការដ្ឋាន គ្រប់កសិដ្ឋាន គ្រប់សហករណ៍ គ្រប់រោងចក្រ និងនៅក្នុងជួរកងទ័ពយើងទាំងមូល ព្រោះការសន្សំសំចៃនេះ ជាកត្តាមួយសំខាន់ណាស់ ក្នុងការកសាងប្រទេស កសាងសង្គមនិយមនៅកម្ពុជាយើង ។ យើងត្រូវឃើញថា ប្រទេសកម្ពុជា ជាប្រទេសតូច មានប្រជាជនតិច ហើយជាប្រទេសក្រីក្រទៀត ។ ដើម្បីកសាងប្រទេស កសាងសង្គមនិយម ដោយជំហានមហាលោតផ្លោះ មហាអស្ចារ្យ ហើយដោយពឹងផ្អែកលើកម្លាំងប្រជាជនខ្លួន និងលើធនធាននៃប្រទេសជាតិខ្លួន ជាសំខាន់បំផុត យើងត្រូវប្រឹងរត់មែនទែនទើបសម្រេចជោគជ័យ ។ បើយើងដើរឬរត់ត្រឹមល្បឿនធម្មតាទៅមិនរួចទេ ។ ប្រឹងរត់នេះ គឺម្យ៉ាង ខាងវាយសម្រុកកសាង វាយសម្រុកធ្វើការផលិតសព្វបែបយ៉ាង ។ តែរត់ម្យ៉ាងទៀត គឺត្រូវយកចិត្តទុកដាក់សន្សំសំចៃបដិវត្តន៍ខ្ពស់បំផុតទៀត ព្រោះបើយើងខំកសាង ខំតែធ្វើមួយមុខ ហើយបានផលមកចាយវាយប្រើប្រាស់ខ្ជះខ្ជាយ ឬទុកដាក់ខូចខាត បាត់បង់ ចោលអសារឥតការរាយប៉ាយគ្រប់ទីគ្រប់កន្លែង នោះទោះបីជាយើងពូកែកសាងយ៉ាងណា ខិតខំវាយសម្រុកធ្វើទាំងយប់ទាំងថ្ងៃយ៉ាងណា ក៏យើងពុំអាចកសាងសង្គមនិយម កសាងប្រទេសបានល្អដែរ ឬយ៉ាងហោចណាស់ក៏យើងពុំអាចកសាងបានលឿនដែរ ។ ដូច្នេះ បញ្ហាសន្សំសំចៃ ជាកត្តាកំណត់មួយដែរ ក្នុងការកសាងសង្គមនិយមនៅកម្ពុជាយើង ។

## តើយើងត្រូវសន្សំសំចៃអ្វីខ្លះ?

និយាយរួម យើងត្រូវសន្សំសំចៃ សព្វគ្រប់បែបយ៉ាងទាំងអស់ សន្សំសំចៃស្រូវអង្ករ អំបិល ប្រហុក ផ្អក ត្រីសាច់ បន្លែបង្ការ សន្សំសំចៃសម្លៀកបំពាក់ និងរបស់របរប្រើប្រាស់ផ្សេងៗ សន្សំសំចៃទឹកភ្លើង សន្សំសំចៃប្រេងឥន្ធនៈ សន្សំសំចៃតាំងពីចេសមួយសរសៃ ដែកគោលមួយ ក្តារមួយបន្ទះ ខសមួយចម្រៀកឡើងទៅ ។ ព្រមជាមួយគ្នានេះ យើងត្រូវសន្សំសំចៃពេលវេលា សន្សំសំចៃកម្លាំងពលកម្ម ឲ្យខ្ពស់ជាប់ជានិច្ចដែរ ។ ពោលគឺ ត្រូវចេះប្រើប្រាស់ពេលវេលាដែលយើងមានឲ្យមានប្រយោជន៍ឲ្យច្រើនដល់ការផលិតកសាងប្រទេស និងការពារប្រទេសជានិច្ច ។ ទោះមួយថ្ងៃក្តី មួយម៉ោងក្តី មួយនាទីក្តី ឬមួយវិនាទីក្តី កុំទុកឲ្យវាកន្លងផុតទៅអសារឥតការ ដោយរវល់ទៅគិតគូរស្មុគស្មាញជុំវិញរឿងបុគ្គលសួនតួ ស្មុគស្មាញជុំវិញអ្វីដែលមិនចម្រើន ឬមិនមែនជាភារកិច្ចបដិវត្តន៍វាយ

សម្រុកការពារប្រទេស កសាងប្រទេស ។ល ។ សន្សំសំចៃកម្លាំងពលកម្ម ដោយចេះចាត់ចែងប្រើ ប្រាស់កម្លាំងដែលមាន ឲ្យសមស្របតាមទំហំការងារ និងដោយមានប្រសិទ្ធភាពបំផុត ។ ពោលគឺប្រើប្រាស់កម្លាំងតិចល្មម មធ្យោបាយ និងសម្ភារតិចល្មម តែធ្វើការបានច្រើន ហើយទទួលផលបានច្រើន ។

សរុបមក ក្នុងការបំពេញភារកិច្ចបដិវត្តន៍ តូច ធំ ធ្ងន់ ស្រាលសព្វបែបយ៉ាង ក៏ដូចក្នុងការរស់នៅស៊ីចុក ស្លៀកពាក់ប្រចាំថ្ងៃ យុវជន យុវនារីបដិវត្តន៍យើង ត្រូវចងចាំកុំភ្លេចនូវពាក្យស្លោករបស់បក្សដែលបានលើកឡើងថា **“ធ្វើការច្រើន ទទួលផលច្រើន តែចំណាយទុនតិច”** ឲ្យបានម៉ឺងម៉ាត់ហ្មត់ចត់គ្រប់ពេលវេលា និងនៅគ្រប់ទីកន្លែង ។ បើយើងបំផុសចលនាសន្សំសំចៃបដិវត្តន៍បានល្អ និងខ្ពស់បំផុត នៅគ្រប់ទីកន្លែងសមស្របតាមពាក្យស្លោករបស់បក្សខាងលើនេះហើយ នោះយើងប្រាកដជាកសាងប្រទេសយើង និងកសាងសង្គមនិយមនៅកម្ពុជាបានជោគជ័យដាច់ខាត ហើយដោយជំហានមហាលោតផ្លោះ មហាអស្ចារ្យ ពុំខានឡើយ ។ ទោះបីប្រទេសយើងតូច ហើយជាប្រទេសក្រីក្រ ដោយប្រៀបធៀបនឹងមហាអំណាចចក្រពត្តិក៏ដោយ ព្រោះយើងមានទុនល្អជាមូលដ្ឋានហើយ ។ ទុនសំខាន់ជាងគេគឺយើងមានទុនខាងបដិវត្តន៍ ដែលជាកត្តាកំណត់ និងជាកម្លាំងជំរុញខ្លាំងក្លាបំផុត ឈានមុខសម្ភារ និងបច្ចេកទេសសព្វបែបយ៉ាងទាំងអស់ទៀត ។

បើពិនិត្យមើលចលនាបដិវត្តន៍យើង ក្នុងមួយរយៈកន្លងមកចាប់ពីក្រោយពេលរំដោះទូទាំងប្រទេស នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ឃើញថា មានគុណសម្បត្តិជាច្រើន ។ ប្រជាជនកម្មករ កសិករ យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍យើងគ្រប់ប្រភេទ បានបន្តលើកជ្រោងគ្រវីទង់ វាយសម្រុកការពារប្រទេស កសាងប្រទេសយ៉ាងខ្លាំងក្លាបំផុតជាប់មិនដាច់ ទាំងយប់ទាំងថ្ងៃ បន្តលះបង់ដោយឥតលក្ខខណ្ឌ បន្តទ្រាំទ្រការលំបាកវេទនាសព្វបែបយ៉ាង វាយសម្រុកសម្រេចភារកិច្ចបដិវត្តន៍ ដណ្តើមបានជ័យជម្នះធំៗថ្មីទៀតជាបន្តបន្ទាប់ ។ ប៉ុន្តែទន្ទឹមនឹងគុណសម្បត្តិធំៗទាំងនេះ យើងក៏សង្កេតឃើញមានការខ្វះខាតជាទូទៅនៅគ្រប់ទីកន្លែង ចំពោះបញ្ហាសន្សំសំចៃនេះ ។ ក្រោយរំដោះទូទាំងប្រទេស សម្ភារសព្វបែបយ៉ាងដែលជាជ័យភណ្ឌបដិវត្តន៍ មានច្រើនណាស់ ទាំងនៅទីក្រុងភ្នំពេញ ក៏ដូចជានៅតាមទីរួមខេត្តនានា ដែលខ្មាំងនៅកាន់កាប់បណ្តោះអាសន្នមុនថ្ងៃ១៧ មេសា ។ យើងមានតាំងពីរោងចក្រ ម៉ាស៊ីន ឡាន ម៉ូតូ កង់ ក្រណាត់ ថ្នាំសង្កូវ រហូតដល់របស់របរប្រើប្រាស់សព្វបែបយ៉ាងផ្សេងទៀត ។ ខាងសម្ភារយោធា យើងមានតាំងពីយន្តហោះ រថក្រោះ កប៉ាល់ កាណូត កាំភ្លើងធំ កាំភ្លើងយន្ត រហូតដល់កាំភ្លើងដៃវែង ខ្លី និងគ្រាប់រំសេវសព្វបែបយ៉ាង ។ របស់របរដែលជាជ័យភណ្ឌបដិវត្តន៍ទាំងនេះ បើយើងចេះប្រមូលទុកដាក់ថែទាំ គត់មត់ល្អ ហើយចេះចាត់ចែងប្រើប្រាស់ឲ្យសមស្រប ទៅតាមការចាំបាច់ ក្នុងកិច្ចការការពារប្រទេស និងកសាងប្រទេស ឲ្យមានប្រសិទ្ធភាពបំផុតនោះ យើងអាចប្រើបានក្នុងរយៈ១០ឆ្នាំយ៉ាងធូរ ។ តែកន្លងមក តាំងពីពេលទើបរំដោះភ្លាម រហូតមកទល់បច្ចុប្បន្ននេះ ឃើញថា យើងមានការខ្វះខាតច្រើនណាស់ មានការខ្ជះខ្ជាយជាទូទៅ និងគ្រប់ទីកន្លែង ដោយសម្អាងតែមានច្រើន ឃើញសម្ភារច្រើន ។ យើងពុំបានគិតគូរដល់ទម្ងន់នៃភារកិច្ចការពារប្រទេស និងកសាងប្រទេស ជាយុទ្ធសាស្ត្រយូរអង្វែងទៅមុខទៀតទេ ។ ម្យ៉ាង យើងខ្ជះខ្ជាយ ក្នុងការប្រើប្រាស់ស៊ីចុក តែម្យ៉ាងទៀត យើងខ្ជះខ្ជាយ ដោយពុំបានយកចិត្តទុកដាក់ប្រមែប្រមូល ថែទាំទុកដាក់ឲ្យបានគត់មត់ល្អ សម្រាប់ប្រើប្រាស់យូរអង្វែង ជាសមូហភាព ក្នុងក្របខ័ណ្ឌសមូហភាព ។ ម្ល៉ោះហើយ សម្ភារទាំងអស់នេះ ត្រូវបាត់បង់ ឬបាក់បែកខូចខាតអន្តរាយចោលគ្រប់ទីកន្លែងអស់ជាងពាក់កណ្តាល ។ នេះជាការគួរឲ្យសោកស្តាយពន់ពេក ។

ចំណុចខ្វះខាតមួយទៀត គឺនៅត្រង់ដែលមិត្តយើងជាទូទៅមិនទាន់ចេះស្រឡាញ់ មិនទាន់ចេះស្តាយទ្រព្យសម្បត្តិរួម ។ ចំណុចល្អ បច្ចុប្បន្ននេះ គឺទាំងក្នុងជួរបដិវត្តន៍ ទាំងក្នុងជួរកងទ័ព ទាំងក្នុងជួរប្រជាជនយើង យើងរស់នៅ ធ្វើការងារជាសមូហភាពអស់ហើយ ។ កម្មសិទ្ធិលើសម្ភារសព្វបែបយ៉ាងទាំងអស់ និងលើមធ្យោបាយផលិតកម្មទាំងអស់ ជាកម្មសិទ្ធិសមូហភាពអស់ហើយ ឬមួយជាកម្មសិទ្ធិរួមរបស់រដ្ឋ ឬមួយជាកម្មសិទ្ធិរួមរបស់សហករណ៍ ។ ដូច្នេះ យើងម្នាក់ៗ គ្មានអីជាកម្មសិទ្ធិផ្ទាល់ខ្លួន ឯកជនឡើយ ប៉ុន្តែ ចំណុចខ្វះខាតសំខាន់ គឺដល់មធ្យោបាយផលិតកម្ម និងសម្ភារប្រើប្រាស់ស៊ីចុកផ្សេងៗ វាទៅជាកម្មសិទ្ធិសមូហភាពទាំងអស់ ដូច្នេះទៅ វាប្រមូលផ្តុំដូច្នេះឃើញច្រើន ។ ក្នុងការរស់នៅក្តី ក្នុងការធ្វើការងារក្តី

បុគ្គលម្នាក់ៗមិនសូវលំបាកគិតគូរ ព្រួយរក ព្រួយធ្វើ ឬដើរខ្ចីបុលគេដូចពីកាលរស់នៅឯកជនទៀតឡើយ ។ ម្ល៉ោះហើយ បញ្ហាស្រឡាញ់ថែទាំ ទុកដាក់របស់របរួម បញ្ហាសន្សំសំចៃក្នុងការប្រើប្រាស់ ស៊ីចុក និងធ្វើការងារក៏ចោទខ្លាំងមែនទែនដែរ ។ ដោយសម្លាងតែមានរបបបើក សម្លាងតែអស់ទៅ ទៅបើកពីរួម ទៅបើកពីឃ្លាំង ម្ល៉ោះហើយ មិត្តយើងមិនសូវចេះស្តាយទេ ពេលឃើញរបស់របរខូចខាត បាក់បែក ឬបាត់បង់ចោល ។ ដោយមិនបានចំណាយកម្លាំងគិតគូរធ្វើ គិតគូររកដោយខ្លួនឯង ដូច្នេះក៏មិត្តយើងមិនសូវចេះស្រឡាញ់ថែទាំទុកដាក់ មើលអស់ មើលគង់របស់របររួម ឲ្យដូចជាខ្លួនស្រឡាញ់ថែទាំទុកដាក់ មើលអស់ មើលគង់ របស់របរផ្ទាល់ខ្លួន ដូចកាលនៅជាកម្មសិទ្ធិឯកជនដែរ ។ ម្ល៉ោះហើយ មិត្តយើង ស៊ីចុក ប្រើប្រាស់ខ្ជះខ្ជាយ បាត់បង់ បាក់បែក ខូចខាត អន្តរាយចោលពាក់កណ្តាលនៅគ្រប់ទីកន្លែង ។

ការខ្វះខាតសំខាន់មួយទៀត គឺបញ្ហាចាត់ចែងប្រើប្រាស់ពេលវេលាក្តី កម្លាំងពលកម្មក្តី មធ្យោបាយ ឬសម្ភារជាទុនផ្សេងៗក្តី ។ មិត្តយើងមិនទាន់ចេះចាត់ចែងរៀបចំ ប្រើប្រាស់យ៉ាងណាឲ្យមានប្រសិទ្ធភាពបំផុតនៅឡើយដែរ ។ កន្លែងខ្លះ នៅធ្វើការងារបែបនាម៉ឺន បែបការិយាល័យសក្តិភូមិចាស់ ធ្វើការគិតគូរតែម៉ោងតែពេលវេលា បើមិនទាន់ដល់ម៉ោងគឺមិនធ្វើ ឬក្នុងម៉ោងធ្វើការហើយក៏ធ្វើៗ ស្រាលៗ សោះអង្គើយ មិនទាន់វាយសម្រុកឲ្យក្តៅ ឲ្យខ្លាំងក្លាបំផុតជាប់ជានិច្ចនៅឡើយទេ នៅគិតគូរពីរឿងហត់នឿយ នៅខ្លាចខាតពេលសម្រាក ។ល ។

កន្លែងខ្លះទៀត នៅប្រើប្រាស់មធ្យោបាយ សម្ភារជាទុនផ្សេងៗសម្បូរបែប ខ្ជះខ្ជាយ តាមរបៀបការិយាល័យសក្តិភូមិនាយទុន ម្ល៉ោះហើយ ត្រូវចំណាយទុនច្រើន តែទទួលផលបានតិច មិនទាន់សមស្របនឹងទំហំទុនដែលចំណាយនៅឡើយទេ បើប្រៀបធៀបនឹងកន្លែងខ្លះ ដែលគេចេះចាត់ចែងរៀបចំកិច្ចដំណើរការងារបានស្រួល ហើយមានគោលជំហរសន្សំសំចៃកម្រិតខ្ពស់ ដោយប្រើប្រាស់ ឬចំណាយតែមធ្យោបាយ ឬសម្ភារដែលចាំបាច់ប៉ុណ្ណោះ ។

នៅកន្លែងខ្លះទៀត ប្រើកម្លាំងមនុស្សពពាក់ពពូនច្រើនណាស់ តែធ្វើការបានតិច ព្រោះមិនទាន់ចេះចាត់ចែង ចែកចាយកម្លាំងពលកម្ម ឲ្យសមស្របទៅតាមទំហំការងារនៅឡើយ ។

នៅកន្លែងខ្លះទៀត ខំវាយសម្រុកធ្វើការងារទាំងយប់ទាំងថ្ងៃ ខ្លាំងក្លាណាស់ដែរ តែទទួលផលបានតិច ព្រោះមកពីមិនទាន់ចេះដាក់ផែនការ ដាក់កម្មវិធី ប៉ាន់ប្រមាណទំហំការងារឲ្យបានហ្មត់ចត់ត្រឹមត្រូវនៅឡើយ ។

សរុបទៅ នៅច្រើនកន្លែង សឹងជាទូទៅ យើងនៅប្រើប្រាស់ខ្ជះខ្ជាយច្រើនណាស់ ក្នុងការធ្វើការងារ ក៏ដូចក្នុងការរស់នៅប្រចាំថ្ងៃ គឺនៅខ្ជះខ្ជាយទាំងសម្ភារ ខ្ជះខ្ជាយទាំងកម្លាំងពលកម្ម ខ្ជះខ្ជាយទាំងពេលវេលា ។ ម្ល៉ោះហើយ ជួនកាលនៅកន្លែងខ្លះយើងធ្វើការតិច ទទួលផលតិច តែចំណាយទុនច្រើន ។ នៅកន្លែងខ្លះទៀត ធ្វើការច្រើន ចំណាយទុនច្រើន តែទទួលផលតិច ។ បើយើងបន្តធ្វើការតាមរបៀបទាំងពីរខាងលើនេះទៀត យើងពុំអាចសម្រេចបដិវត្តន៍សង្គមនិយម កសាងសង្គមនិយមនៅកម្ពុជាបានឆាប់រហ័សទេ ។ ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើង នៅតាមគ្រប់ក្រសួង គ្រប់មន្ទីរ គ្រប់ការដ្ឋាន គ្រប់រោងចក្រ និងនៅតាមសហករណ៍នានា ចាំបាច់ត្រូវកម្ចាត់របៀបរបបធ្វើការងារទាំងពីរខាងលើនេះ ចោលចេញឲ្យបានដាច់ខាត ហើយត្រូវលើកកម្ពស់ស្មារតីសន្សំសំចៃបដិវត្តន៍ឲ្យខ្ពស់ជានិច្ច ហើយបំផុសចលនាសន្សំសំចៃបដិវត្តន៍នេះ ឲ្យគគ្រឹកគគ្រេងខ្លាំងក្លាបំផុត ទៅតាមគ្រប់មន្ទីរ ក្រសួង ការដ្ឋាន រោងចក្រ និងសហករណ៍នានា ឲ្យអនុវត្តពាក្យស្លោក **«ធ្វើការច្រើន ទទួលផលច្រើន តែចំណាយទុនតិច»** ឲ្យបានត្រឹមត្រូវ ហ្មត់ចត់ ដោយជ្រួតជ្រាប និងដោយភ្ញាក់រឭកបដិវត្តន៍ខ្ពស់ ។ យុវជន យុវនារីបដិវត្តន៍យើងទាំងអស់ ត្រូវយកពាក្យស្លោករបស់បក្សនេះ ទៅរៀនសូត្រ ឲ្យជ្រួតជ្រាប ហើយផ្សព្វផ្សាយឲ្យទូលំទូលាយ ទៅក្នុងមហាចលនាវាយសម្រុករបស់មហាជន នៅគ្រប់ទីកន្លែង ធ្វើឲ្យពាក្យស្លោកនេះ ក្លាយទៅជាគោលជំហរបដិវត្តន៍ និងទៅជាកម្លាំងប្រយុទ្ធដាក់ស្តែងមួយជំរុញភារកិច្ច វាយសម្រុកការពារប្រទេស កសាងប្រទេស ដោយជំហានមហាលោតផ្លោះ មហាអស្ចារ្យ ។ បើយុវជន យុវនារីបដិវត្តន៍យើងធ្វើយ៉ាងនេះបាន នោះយើងពិតជាសម្រេចបដិវត្តន៍ សង្គមនិយមនៅកម្ពុជា ដោយជោគជ័យ ហើយកសាងសង្គមនិយមនៅកម្ពុជា បានរីងប៉ឹងល្អ និងដោយល្បឿន មហាលោតផ្លោះ មហាអស្ចារ្យ ពុំខានឡើយ ។

**ឆាយ សារៈមុនិន្ទ**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬកា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ទីកន្លែង ៖ អគារ “ក” ជាន់លើ ◆ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *www.cambodiatribunal.org* គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *www.cambodiatribunal.org* ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី “សហកម្មឧក្រិដ្ឋកម្មរួម” ដែលភាសាអង់គ្លេសហៅថា “*Join Criminal Enterprise*” ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម “ផែនការឧក្រិដ្ឋរួម” ដែលភាសាអង់គ្លេសហៅថា “*Common Criminal Plan*” ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**

# បាត់បង់ប្អូនដោយសារចូលរួមធ្វើបដិវត្តន៍




ជាជនរងគ្រោះម្នាក់ និងជាអតីតអ្នកចូលរួមចលនាបដិវត្តន៍របស់ខ្មែរក្រហម ង៉ែត សុខឿន បានឆ្លងកាត់រឿងរ៉ាវជាច្រើនក្នុងអំឡុងពេលនោះ ។ សុខឿន បានបាត់បងបងប្អូនប្រុសស្រីពីរនាក់ក្នុងរបបខ្មែរក្រហម ។ ម្នាក់បាត់ខ្លួនដោយគ្មានដំណឹង និងម្នាក់ទៀតស្លាប់ដោយសារការធ្វើការហួសកម្លាំង និងអត់អាហារ ។ សុខឿន ជាកូនស្រីម្នាក់ក្នុងចំណោមបងប្អូនប្រុសស្រី៧នាក់ (ស្រីបួននាក់ និងប្រុសបីនាក់) ដែលមានឪពុកឈ្មោះ ទូច ជា និងម្តាយ ង៉ែត ហួន ។ គាត់មានស្រុកកំណើតនៅភូមិត្រពាំងឈូក ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ ។

កាលពីកុមារភាព សុខឿន មិនបានរៀនសូត្រនោះទេ ព្រោះក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅឆ្នាំ១៩៧០ នៅភូមិស្រុករបស់គាត់មានការទម្លាក់គ្រាប់បែកជាញឹកញាប់ពីសំណាក់កងទ័ពអាមេរិក ។ នៅឆ្នាំ១៩៧៣ គាត់មានវ័យប្រហែល១២-១៣ឆ្នាំហើយ បានចូលរួមជាមួយចលនាតស៊ូបដិវត្តន៍របស់ខ្មែរក្រហម ដែលពេលនោះ អ៊ុំរបស់គាត់ជាអ្នកនាំចូល ។ សុខឿន ចូលដំបូងគឺនៅក្នុងមន្ទីរកុមារ ហើយក៏មិនបានធ្វើការងារអ្វីដែរ ក្រៅពីរត់សំបុត្រឲ្យប្រធានមន្ទីរឈ្មោះតា ចុក ពីមន្ទីរមួយទៅមន្ទីរមួយ ឬពីស្រុកទៅតំបន់ជាដើម ។ ការងាររត់សំបុត្រនេះ មិនមែនមានតែគាត់ម្នាក់ឯងទេ គឺមានកុមារា កុមារីប្រហែល១០ ទៅ២០នាក់ ឯណោះ ។ បន្ទាប់មកទៀត គាត់បានផ្លាស់មកមន្ទីរកុមារ នៅជ្រុកខ្ពស់ ខាងខេត្តកំពង់ស្ពឺ ដែលមានឈ្មោះ វី ជាប្រធាន ។ សុខឿន និងកុមារឯទៀត ត្រូវអង្គការចាត់តាំងឲ្យដាំចេក និងរត់សំបុត្រដដែល ។

នៅឆ្នាំ១៩៧៥ គាត់ និងកុមារឯទៀតត្រូវអង្គការចាត់ទុកថាជាយុទ្ធជន និងយុទ្ធនារី ហើយបានបំពាក់អាវុធឲ្យ ហើយផ្លាស់ឲ្យមកនៅខាងកោះកុងវិញ ។ មកកោះកុងនេះ មិនមែនមកតែក្រុមរបស់ សុខឿន នោះទេ គឺមានមកពីគ្រប់ខេត្ត តំបន់ទាំងអស់ មកជុំគ្នានៅខេត្តកោះកុង ប្រហែល១០០០នាក់ ហើយអង្គការចាប់ផ្តើមរៀបចំកងថ្មីទៅតាមមុខសញ្ញានីមួយៗ ។ គាត់ត្រូវអង្គការចាត់ចូលវរសេនាតូច លេខ៣ មានឈ្មោះ ថុល នាទីប្រធាន ចំណុះឲ្យវរសេនាធំលេខ៤ កងពលទី៤ ដែលមានឈ្មោះ រឿន ជាប្រធានកងពល ។ បើនិយាយពីតា ម៉ុក វិញ គាត់មិនដែលបានទៅដល់ភូមិភាគខាងកោះកុងនោះទេ គឺគាត់ទៅត្រឹមតែ១០០៣ប៉ុណ្ណោះ ។ ក្នុងចំណោមមេដឹកនាំខាងលើដែល សុខឿន ស្គាល់ មានដូចជា តា ទិត្យ មានប្រពន្ធឈ្មោះ កេន និងតា សាន មានប្រពន្ធឈ្មោះ គឿន ជាដើម ហើយ តា សាន និងតា ទិត្យ នេះ ត្រូវជាប្អូនថ្លៃតា ម៉ុក ។

នៅកោះកុងចាប់ពីឆ្នាំ១៩៧៥-៧៦ សុខឿន ត្រូវអង្គការដកមកខាងនេសាទត្រីសមុទ្រវិញ គាត់រំឭកថា កាលណោះត្រីមានច្រើនខ្លាំងណាស់ មិនដូចពេលបច្ចុប្បន្នទេ ។ បើយើងទម្លាក់មងចោលតែមួយម៉ោង ឬពីរម៉ោងនោះ យើងពិតជាលើកមិនរួចឡើយ ។ ការហូបចុកនៅពេលនោះគឺគ្រប់គ្រាន់ណាស់ ហើយស្របពេលនោះ គាត់មិនដឹងថា ប្រជាជនជាច្រើនកំពុងជួបប្រទះនឹងភាពអត់ឃ្លាន ទទួលរងការធ្វើបាប និងសម្លាប់ដែរ ។ ក្រោយមកទៀត អង្គការបានផ្លាស់ សុខឿន ពីអង្គភាពនេសាទ មកនៅខាងកាត់ដេរវិញនៅម្តុំកងចល័ត ។

នៅទីនោះ ឈ្មោះ ទូច ជាប្រធានអង្គភាពកាត់ដេរ ហើយក៏ត្រូវជាបងជីដូនមួយរបស់ សុខឿន ដែរ ។ មិនយូរប៉ុន្មាន បងជីដូនមួយរបស់គាត់ ត្រូវអង្គការដកទៅខាងកំពង់ធំវិញ ហើយក៏បាត់ដំណឹងតាំងពីពេលនោះតែម្តង ។ អ្នកដែលត្រូវមកជំនួសកន្លែង ទូច គឺយាយ ណន ។ មនុស្សនៅអង្គភាពកាត់ដេរមួយចំនួនត្រូវបានធ្វើបាប ផ្លាស់ចេញ និងយកទៅរៀនសូត្រ ។ យាយ ណន ជាមនុស្សកាចខ្លាំងណាស់ ហើយ សុខឿន ក៏មិនដឹងថា គាត់ត្រូវអង្គការចាត់

តាំងមកពីខាងណាដែរ ។

ថ្ងៃមួយ យាយ ណន បានចាត់ឲ្យ សុខខឿន និងមនុស្សប្រហែល៣៥នាក់ ទៅយាមចម្ការដំឡូង ។ ចម្ការដំឡូងធំណាស់ ដំឡូងជាច្រើន ត្រូវជ្រូកព្រៃឈ្មុសស៊ី លុះព្រឹកឡើង យាន ណន ដើរពិនិត្យឃើញដំឡូងមួយចំនួនត្រូវជ្រូកព្រៃស៊ី ក៏បានបន្ទោសគាត់ និងអ្នកឯទៀតថា «ឲ្យមកយាមដំឡូងយ៉ាងម៉េចបានជាឲ្យជ្រូកមកស៊ីដំឡូងអស់យ៉ាងនេះ» ។

ក្រោយមក យាយ ណន បានដក ខឿន និងអ្នកឯទៀតឈប់ឲ្យយាមដំឡូង តែនៅតែមានឈ្លបតាមដានអ្នកទាំងអស់គ្នាដដែល ព្រោះពេលនោះ ខឿន និងអ្នកឯទៀត បានយកដំឡូងដែលសល់ពីជ្រូកឈ្មុសនោះមកដុតហូប ហេតុនេះ យាយ ណន ចោទថា អ្នកទាំងអស់នោះ លួចដំឡូងហូប មិនមែនជ្រូកនោះទេ ។

បង១នៅកងកាត់ដេរមួយចំនួនត្រូវយាយ ណន ដកទៅកងចល័ត ពេលនោះ ខឿន បានតវ៉ាជាមួយយាយ ណន ថា«តើបង១ហ្នឹងខុសអី បានជាដកគាត់ទៅកងចល័តយ៉ាងនេះ?» យាយ ណន ឆ្លើយវិញថា «ពួកវែងមានដឹងអីខុសស្អីក៏វែងអត់ដឹងដែរ» ហើយ ខឿន តបថា «ចុះគាត់នៅដេរទាំងអស់គ្នាហ្នឹងអត់មានធ្វើអ្វីខុសផង» ។ មនុស្សជាច្រើន ត្រូវបានដកមកខាងកងចល័ត គឺដកចេញដកចូល ហើយអ្នកដែលមិនសូវសកម្មនឹងការងារ ត្រូវអង្គការហៅទៅរៀនសូត្រ អប់រំ និងលត់ដំនៅខាងព្រៃទប់ ដែលជាកន្លែងកងចល័តធំ ។

នៅព្រៃទប់ ការងារមានការលំបាកខ្លាំងណាស់ ទោះបីជាឈឺក៏ត្រូវតែធ្វើការដែរ ។ ប្អូនរបស់ សុខខឿន ឈ្មោះ រឿន ដែលនៅទីនោះបានលួច មកលេង ខឿន និងប្រាប់ថា ការងារកងចល័តនៅព្រៃទប់នោះលំបាកខ្លាំងណាស់ អង្គការធ្វើបាប របបអាហារក៏មិនគ្រប់គ្រាន់ អ្នកខ្លះឈឺហើយ ត្រូវខំប្រឹងធ្វើការរហូតដល់ស្លាប់ក៏មាន ។ ប្អូនរបស់ ខឿន ឈ្មោះ រឿន ក៏បានស្លាប់នៅកងចល័តព្រៃទប់ហ្នឹងដែរ បន្ទាប់ពីត្រឡប់ទៅកងចល័តនោះវិញ ។ ក្រោយមក មានឡានមកយកបង១នៅកន្លែងកាត់ដេរនោះ សុខខឿន និងអ្នកនៅអង្គភាពកាត់ដេរនោះ ប្រហែល៣៦នាក់ បានរត់តាមបង១ទាំងនោះ យាយ ណន ក៏ហៅទ័ពស្រុកមកជួយ ហើយយកអ្នកទាំងអស់គ្នាទៅដាក់នៅក្រោមផ្ទះមួយ ដើម្បីសួមគោលការណ៍ពីអង្គការលើ ។ យាន ណន បានរាយការណ៍ទៅអង្គការលើថា ក្រុមរបស់គាត់ក្បត់ដោយរត់តាមគ្នា ហើយស្នើឲ្យគណៈតំបន់នៅព្រៃទប់មកប្រជុំដោះស្រាយ ។ សុខខឿន មកនៅខាងកាត់ដេរវិញដដែល ដោយមិនមានបញ្ជូនទៅទីណាទៀតទេ ប៉ុន្តែមិនបានប៉ុន្មានផង យាយ ណន ក៏ត្រូវអង្គការមកនាំខ្លួនយកទៅដែរ តែមិនដឹងអង្គការដកគាត់ទៅណាទេ ។ ខឿន បានឃើញឡានហ្ស៊ីបមួយមកដឹកគាត់យកទៅ ។

នៅឆ្នាំ១៩៧៩ ពេលវៀតណាមចូល សុខខឿន បានរត់ចូលព្រៃជាមួយកងទ័ពឯទៀត ដោយខ្លាចវៀតណាម ។ នៅក្នុងព្រៃគឺពិតជាមានការលំបាកខ្លាំងណាស់គ្មានអ្វីហូបក្រៅពីស្លឹកឈើ ផ្លែឈើនោះទេ ។ អំឡុងពេលរត់ក្នុងព្រៃនោះ គឺមានមនុស្សស្លាប់ច្រើនណាស់ តែគាត់មិនស្គាល់ថាជានរណាខ្លះទេ ។ គាត់បានធ្វើដំណើររហូតមកដល់ឆ្នាំ៨០-៨១ បានមកដល់ថ្មដាជាប់ព្រំដែនថៃ ដែលកាលណោះក៏មានការរៀបចំអង្គភាពជាថ្មី ។ សុខខឿន នៅពេលនោះបានមកនៅខាងកងដឹកជញ្ជូន ដោយដឹកជញ្ជូនគ្រាប់ អង្ករ ថ្នាំពេទ្យជាដើម យកទៅឲ្យយុទ្ធជន ដែលកំពុងប្រយុទ្ធជាមួយវៀតណាម ។ នៅឆ្នាំ១៩៨៥ ខឿន បានរៀបការ ដែលប្រព្រឹត្តឡើងនៅវត្តអូររំចេក នៅជិតសំឡូត ហើយបានទៅរស់នៅតំបន់១០០៣ ខាងតា ម៉ុក នៅខាងអន្លង់វែងវិញ ។

ចំពោះរូប ខឿន ផ្ទាល់ សម័យតស៊ូ និងបច្ចុប្បន្ន គឺបច្ចុប្បន្នមានភាពងាយស្រួលជាង មានផ្លូវ រដ្ឋាភិបាលដឹកនាំ ដឹងខុស ដឹងត្រូវ ហើយចំពោះការដែលធ្វើឲ្យប្រជាជនស្លាប់ និងលំបាកវេទនា គាត់មិនយល់ថាមកពីខាងលើទេ គាត់យល់ថាគឺ ខាងថ្នាក់ក្រោមហ្នឹងតែម្តង ព្រោះថ្នាក់លើបានណែនាំគាត់ ថា «ឧទាហរណ៍ កន្លែងរបស់ខ្ញុំគាត់ចុះមក រឿងហូបចុកដូចជាម្ហូបអាហារបាយទឹកអី គាត់ឲ្យដាំហូបត្រឹមត្រូវ ពេលដែលគាត់ទៅបាត់ ខាងក្រោម គេចាប់ផ្តើមធ្វើជាបបរធ្វើអីចឹងទៅ ។ អីចឹងបានខ្ញុំគិតថា មិនមែនខាងលើទេធ្វើ អីចឹងមានថ្នាក់ក្រោមទេធ្វើ» ។

បច្ចុប្បន្ននេះ សុខខឿនរស់នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយប្រកបរបរធ្វើចម្ការ ។ គាត់មានប្តីឈ្មោះ កាន់ ថា និងមានកូនប្រុសស្រី៤នាក់ (ស្រី៣នាក់ និងប្រុសម្នាក់) ។

**ធាង សារៈមុនិន្ទ**

# តាញ៉ៅន : អតីតគណៈស្រុកអង្គរជ័យ និងស្រុកសេរីសោភ័ណ តំបន់៥ ភូមិភាគពាយ័ព្យ

ណុប ញ៉ៅន ហៅ តាញ៉ៅន ត្រូវបានស្គាល់ថាជាស្វាមីរបស់ អ៊ឹម ចែម ហៅ យាយចែម ដែលជាជនសង្ស័យម្នាក់ក្នុងសំណុំរឿង ០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ តាញ៉ៅន បច្ចុប្បន្នមានអាយុ៧៦ឆ្នាំ រស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ តាញ៉ៅន មានមាឌតូចល្អិត សម្បុរសណ្តែកបាយ សក់រួចអង្គាដី និងមានភ្នែកស្រលៀង ។ គាត់គឺជាមនុស្សទុយមុយ មិនសូវចេះនិយាយស្តីជាមួយញាតិមិត្ត និងភ្ញៀវដែលមកលេងផ្ទះគាត់ទេ ។ ប៉ុន្តែ បើតាមលោក សួន ម៉ុត ដែលជាអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ធ្លាប់ធ្វើការនៅក្រោមការដឹកនាំរបស់តា ញ៉ៅន ចាប់តាំងពីគាត់ធ្វើជាគណៈស្រុកអង្គរជ័យរហូតដល់ផ្លាស់មកកាន់ស្រុកសេរីសោភ័ណ បានមានប្រសាសន៍ថា តាញ៉ៅន ជាមនុស្សមានវោហាសាស្ត្រខាងអង្គការបដិវត្តន៍ខ្មែរក្រហមល្អគួរសម នៅពេលប្រជុំម្តងៗគាត់តែងតែនិយាយដោយសម្តីម៉ាត់ៗច្បាស់ៗស្តាប់ទៅគួរឲ្យខ្លាច មិនមែនជាមនុស្សមិនចេះនិយាយមាំុងៗដូចនាពេលបច្ចុប្បន្ននេះឡើយ ។

តាញ៉ៅន បានរៀបការជាមួយ យាយចែម នៅឆ្នាំ១៩៦៥ ។ គាត់មានកូនទាំងអស់៨នាក់ (ស្រី២នាក់ និងប្រុស៦នាក់) សព្វថ្ងៃនៅរស់តែ៤នាក់ ។ តាញ៉ៅន បានចូលបម្រើក្នុងចលនាខ្មែរក្រហមក្រោមការដឹកនាំរបស់ តាម៉ុក នៅអំឡុងឆ្នាំ១៩៦៨ នៅខណៈពេលដែលគាត់ និងគ្រួសារចេញពីស្រុកកំណើតទៅកាប់រានដី ដើម្បីធ្វើស្រែចំការនៅក្នុងខេត្តកំពង់ស្ពឺ ។

នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានតែងតាំង តាញ៉ៅន ឲ្យធ្វើជាគណៈស្រុកអង្គរជ័យ បន្ទាប់ពី តាងិន ដែលជាអតីតគណៈស្រុកអង្គជ័យ ត្រូវបានចាប់ខ្លួនពីបទចូលរួមជាមួយ សេ. អ៊ី. អា និង កា. ហ្សេ.បេ ។ ចំណែក យាយចែម បានស្នាក់នៅជាមួយប្តី (តាញ៉ៅន) នៅស្រុកអង្គរជ័យដែរ ប៉ុន្តែគាត់មានតួនាទីខ្ពស់ជាង តាញ៉ៅន គាត់គឺជាគណៈគ្រប់គ្រងតំបន់១៣ រួមជាមួយឈ្មោះ មាស ម៉ុត (កូនប្រសារតាម៉ុក) និង តាសោម ។

នៅចុងឆ្នាំ១៩៧៦ តាម៉ុក បានចាត់តាំង និងបញ្ជូនកម្មាភិបាល និងប្រជាជននៅភូមិភាគនិរតីជាច្រើនពាន់នាក់ឲ្យមកគ្រប់គ្រង និងជួយបង្កបង្កើនផលប្រជាជននៅភូមិភាគពាយ័ព្យ ។ តាម៉ុក បានប្រាប់ទៀតថា នៅភូមិភាគពាយ័ព្យមានទឹកដីធំ និងសម្បូរស្រូវ ។ ប៉ុន្តែកម្មាភិបាលភូមិភាគពាយ័ព្យ ភាគច្រើនមិនសូវមានបទពិសោធក្នុងការដឹកនាំ និងបានក្បត់នឹងអង្គការថែមទៀត ។ សួន ម៉ុត រួមជាមួយនឹងប្រពន្ធ, កូនពីរនាក់, ម្តាយក្មេក, កម្មាភិបាល និងប្រជាជនរាប់ពាន់នាក់មកពីគ្រប់ស្រុកក្នុងតំបន់១៣ ក៏ត្រូវអង្គការបញ្ជូនឲ្យទៅនៅខាងភូមិភាគពាយ័ព្យដែរ ។ យាយចែម និងតាញ៉ៅន មានតួនាទីជាអ្នកដឹកនាំកម្មាភិបាល និងប្រជាជនទាំងអស់ពីខេត្តតាកែវតាមរថភ្លើងមកទីក្រុងភ្នំពេញ និងបន្តទៅភូមិភាគពាយ័ព្យ ។ ពេលមកដល់ទីក្រុងភ្នំពេញ កម្មាភិបាល និងប្រជាជនទាំងអស់ត្រូវស្នាក់នៅប្រាំងចម្រេះ រយៈពេលពីរយប់ ព្រោះ យាយចែម , តាញ៉ៅន និងកម្មាភិបាលដឹកនាំធំៗដទៃទៀតត្រូវចូលរួមប្រជុំជាមួយ ប៉ុល ពត ។ ដោយឡែកកម្មាភិបាលតូចៗ និងប្រជាជនដែលមិនបានចូលប្រជុំ ត្រូវអង្គការយករថយន្តមកដឹកឲ្យទៅទស្សនាទីក្រុងភ្នំពេញ ។ សួន ម៉ុត ដែលបានទស្សនាទីក្រុងភ្នំពេញនៅពេលនោះមាន ប្រសាសន៍ថា ទីក្រុងភ្នំពេញមានសភាពស្ងាត់ជ្រងំ គាត់បានឃើញតែកម្មកររោងចក្រ កងទ័ពដែលកំពុងធ្វើស្រែ ធ្វើរងបន្លែនៅជាយភ្នំពេញ ។ ផ្ទះ និងស្លាកយីហោផ្សេងៗភាគច្រើនបានបាក់បែក ។ រីឯសួនច្បារពីសង្គមចាស់ត្រូវបានខ្មែរក្រហមឈូសឆាយចោល រួចដាំដើមដូង និងស្ពៃជំនួសវិញ ។ បន្ទាប់មកអង្គការបានដឹកឲ្យទៅមើលភាពយន្តឯកសារអំពីតំបន់រំដោះរបស់ខ្មែរក្រហម និងកុនឯកសាររបស់ចិនដែលនិយាយពីបដិវត្តន៍របស់ប្រធាន ម៉ៅ និងកងផលិត ដាំស្រូវលើភ្នំដែលមានបកប្រែមកជាភាសាខ្មែរ ។

ពីរថ្ងៃក្រោយមក អង្គការបានដឹកកម្មាភិបាល និងប្រជាជន

ទាំងអស់មកដាក់នៅស្ថានីយរថភ្លើង ដើម្បីធ្វើដំណើរបន្តមកភូមិភាគពាយ័ព្យ ។ កម្មាភិបាលខ្មែរក្រហម និងប្រជាជនមួយចំនួនបានចុះនៅម្តុំខេត្តពោធិ៍សាត់ និងចុងក្រោយ យាយថែម, តាញ៉ែន, សួន ម៉ុត, កម្មាភិបាល និងប្រជាជនប្រមាណជាង១.០០០នាក់ បានឈប់នៅថ្មគោល ។ បន្ទាប់មកអង្គការបានដឹកបន្តតាមរថយន្តទៅដាក់នៅស្វាយស៊ីសុផុន, សេរីសោភ័ណ និងបន្តបែងចែកឲ្យទៅខាងស្រុកភ្នំស្រុក និងខាងស្រុកព្រះនេត្រព្រះ ។ ការបែងចែកតួនាទីគ្រប់គ្រងដូចជា មេភូមិ សហករណ៍ កងទ័ព និងតួនាទីផ្សេងទៀត ចំណាយរយៈពេលមួយអាទិត្យទើបហើយរួចរាល់ ។

ស្របពេលនោះគណៈតំបន់៥ រួមមាន ហេង រិន ហៅ ម៉ី (កម្មាភិបាលមកពីនិរតី), ជាល (កម្មាភិបាលចាស់ និងជាកូនប្រុសរបស់ រស់ ញឹម) និង យាយថែម មាននាទីជាគណៈតំបន់ និងជាគណៈស្រុកព្រះនេត្រព្រះ ។

តាញ៉ែន ត្រូវបានចាត់តាំងឲ្យធ្វើជាគណៈស្រុកសេរីសោភ័ណ ។ ស្រុកសេរីសោភ័ណមានឃុំ ចំនួន៨ គឺ ១) ឃុំភ្លៀត ឈ្មោះ ខាត់ ជាលេខា (ខាត់ មានប្រពន្ធឈ្មោះសៅ រី សព្វថ្ងៃរស់នៅស្រុកម៉ាឡៃ) ២) ឃុំបុស្សស្បូវ ឈ្មោះ ឌី ជាលេខា ៣) ឃុំសិង្ហ ឈ្មោះ អៀង ជាលេខា ៥) ឃុំកង្ហា ឈ្មោះ តាយន ជាលេខា ៦) ឃុំសំរោង ឈ្មោះ ជឿន ជាលេខា (សព្វថ្ងៃ ជឿន និង ភរិយារស់នៅឃុំសន្តិភាព ស្រុកសំពៅលូន) ៧) ឃុំម្កាក់ ឈ្មោះ ជាត ជាលេខា និង៨) ឃុំទឹកថ្លា ឈ្មោះ ផល ជាលេខា ។

ភាពមិនចុះសម្រុងគ្នាបានកើតឡើងជាញឹកញាប់រវាងកម្មាភិបាលចាស់ក្រោមការគ្រប់គ្រងរបស់ រស់ ញឹម និងកូនប្រុសរបស់ រស់ ញឹម ឈ្មោះ ជាល ដែលគ្រប់គ្រងនៅតំបន់៥ និងកម្មាភិបាលថ្មីមកពីខាងភូមិភាគនិរតី ។ ដូចជាហេតុការណ៍ជម្លោះមួយបានកើតឡើងនៅក្នុងវត្តស្វាយស៊ីសុផុន រវាងកម្មាភិបាលចាស់ ក្រោមការគ្រប់គ្រងរបស់ឈ្មោះ ជាល និងកម្មាភិបាលថ្មីមកពីភូមិភាគនិរតី ឈ្មោះ តារាម កាន់ខាងកងទ័ពតំបន់៥ បានភ្ជង់កាំភ្លើងដាក់គ្នា ។ ចំណែកកម្មករដែលធ្វើការនៅតាមរោងចក្រក្នុងតំបន់៥មកពី ខាងភូមិភាគនិរតី និងពាយ័ព្យ ក៏មិនសូវត្រូវគ្នាដែរ ។ ក្រោយមកនៅចុងឆ្នាំ ១៩៧៧ និង១៩៧៨ ជាល និង ហេង រិន ត្រូវបានអង្គការចាប់ខ្លួន ដោយចោទប្រកាន់ថា ពាក់ព័ន្ធជាមួយ រស់ ញឹម និងកងចាប គណៈភូមិភាគពាយ័ព្យ និងឧត្តរថ្មី ។ ចំណែក កម្មាភិបាលចាស់ផ្សេងៗទៀតក៏ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខរបស់តំបន់នៅភ្នំកងវ៉ា ។

នៅឆ្នាំ១៩៧៨ អង្គការបានផ្លាស់ប្តូរកម្មាភិបាលដឹកនាំថ្នាក់តំបន់ និងតាមស្រុក គឺ តាចាយ ត្រូវបានអង្គការផ្លាស់ឲ្យមកទទួលជាគណៈតំបន់៥ ជាមួយ យាយថែម ។ ចំណែក តាញ៉ែន ត្រូវផ្លាស់ទៅធ្វើជាគណៈស្រុកភ្នំស្រុក ។ តាសឹម ត្រូវបានដំឡើងជាគណៈស្រុកសេរីសោភ័ណ្ឌ (សព្វថ្ងៃ តា សឹម រស់នៅឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក) ។ យាយថែម មានតួនាទីជាគណៈតំបន់៥ និងជាគណៈស្រុកព្រះនេត្រព្រះ ។ តារាម ត្រូវផ្លាស់ពីយោធាតំបន់មកទទួលជាគណៈស្រុកថ្មពួក (សព្វថ្ងៃរស់នៅឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក) ។

**សោម ប៊ុនថន**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# ចាប់ពីរបបខ្មែរក្រហម ដល់ ឧបទ្ទវហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

***(តពីលេខមុន)***

***ចាម និងជ្វា : ភាពស្រដៀង និងភាពខុសគ្នា***

*សព្វថ្ងៃនេះ អ្នកស្រាវជ្រាវភាគច្រើនទំនងជាចាត់ទុកជនជាតិចាម និងជ្វា ថាជាជនជាតិដូចគ្នា ក្នុងអត្តបទរបស់ខ្លួន ។ នៅចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០ អ្នកស្រាវជ្រាវអំពីការដាក់អាណានិគមទំនងជាចាត់ទុកមូស្លីមកម្ពុជាជាប្រជាជនម៉ាឡេ ដូច្នេះវាពិបាកក្នុងការកំណត់ថា តើមូស្លីម ដែលអ្នកស្រាវជ្រាវទាំងនោះបានសិក្សា គឺសំដៅលើជនជាតិចាម ឬជនជាតិជ្វា ។ មធ្យោបាយតែមួយគត់ដើម្បីស្វែងយល់ពីបញ្ហានេះគឺថា យើងត្រូវដឹងពីទីតាំងរបស់ក្រុមមូស្លីមនោះ និងដឹងអំពីបរិបទនៃប្រវត្តិសាស្ត្រក្នុងអំឡុងពេលនោះ ។ យ៉ាងណាមិញ ឯកសារថ្មីៗស្តីអំពីមូស្លីមកម្ពុជាជាច្រើនតែងតែចាត់ទុកក្រុមជាតិសាសន៍នេះជា“ជនជាតិចាម” ។ ការកំណត់បែបនេះគឺខុសទាំងស្រុង ពីព្រោះ បច្ចុប្បន្ននេះយើងយល់ដឹងអំពីដើមកំណើត ទីកន្លែង ចំនួនប្រជាជន និងជំនឿរបស់ជនជាតិចាម និងជនជាតិជ្វាច្រើនជាងកាលពីអតីតកាល ។*

*ក្នុងចំណោមប្រជាជនកម្ពុជា ពាក្យ ម៉ាឡេ និង ជ្វា ត្រូវបានប្រើជំនួសគ្នាទៅវិញទៅមក ។ បើនិយាយអំពីឈ្មោះវិញ ម៉ាឡេ សំដៅលើក្រុមជាតិពន្ធុម៉ាឡេដែលរស់នៅឧបទ្វីបម៉ាឡេស៊ី និងតំបន់ផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ ចំណែកឯជ្វាវិញគឺសំដៅទៅលើប្រជាជនមូស្លីម ដែលមានដើមកំណើតមកពីប្រជុំកោះចាវ៉ា (Java) ។ ប៉ុន្តែ ការបែងចែករវាងជនជាតិចាម និងជនជាតិជ្វា ដែលបានធ្វើឡើងក្នុងឯកសារប្រវត្តិសាស្ត្រ និងឯកសារសព្វថ្ងៃនេះ ត្រូវបានបញ្ចូលដោយសារតែវាពិបាកក្នុងការបែងចែកភាពខុសគ្នារវាងជនជាតិចាម និងមូស្លីមដទៃ ដែលមានដើមកំណើតពីតំបន់ប្រជុំកោះតូចៗ ។ អាស្រ័យហេតុនេះ ក្នុងសៀវភៅនេះ ជនជាតិជ្វា ត្រូវបានប្រើដើម្បីសំដៅទៅកាន់ប្រជាជនដែលមានដើមកំណើតមកពីប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ។*

*ដោយសារតែការបែងចែករវាងជនជាតិចាម និងជ្វាមិនទាន់ច្បាស់លាស់ នៅក្នុងឯកសារបន្ទាប់បន្សំ និងព័ត៌មានទទួលបានពីអ្នកចូលរួមក្នុងការសិក្សានេះ សៀវភៅនេះប្រើពាក្យចាម-ជ្វា នៅពេលដែលយើងមិនអាចកំណត់ថា តើបុគ្គលម្នាក់នោះជាជនជាតិចាម ឬ ជ្វា ។ ជួនកាលពាក្យ មូស្លីម-កម្ពុជា ត្រូវបានយកមកប្រើដើម្បីសំដៅទៅកាន់ជនជាតិទាំងពីរក្រុមនេះ ក៏ដូចជាប្រជាជនខ្មែរដែលប្តូរទៅប្រណិប័តន៍សាសនាអ៊ីស្លាមដែរ ។*

*ការផ្តោតសំខាន់នៃសៀវភៅនេះគឺជនជាតិចាម និងអត្តសញ្ញាណរបស់ជនជាតិចាម ដែលជនជាតិនេះគោរពប្រណិប័តន៍សាសនាអ៊ីស្លាមច្រើនជាងគេនៅកម្ពុជា ។ ដោយសារអាចនិយាយភាសាខ្មែរដូចភាសាកំណើតរបស់ខ្លួន ជនជាតិជ្វាបានជួយសម្រួលដល់ការទំនាក់ទំនងរវាងចាម និងខ្មែរ រួមទាំងសង្គមកម្ពុជាទាំងមូលដែលមានប្រជាជនខ្មែរជាប្រជាជនភាគច្រើន ។ ជាលទ្ធផល ជនជាតិជ្វា ជួយពង្រឹងអត្តសញ្ញាណរបស់ចាម ជាពិសេស មុនគម្រោងខេមរភាវូបនីយកម្មរបស់ព្រះមហាក្សត្រ សីហនុ ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ គឺជាអំឡុងពេលដែលជនជាតិចាមជាច្រើនមិនអាចនិយាយភាសាខ្មែរបាន ហើយមានតែជនជាតិជ្វាតែប៉ុណ្ណោះ ដែលជាមូស្លីមដែលអាចនិយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញ ។*

*សម្រាប់ជនជាតិចាម និងជ្វាភាគច្រើន ភាពខុសគ្នានៃជាតិពន្ធុ និងដើមកំណើតរបស់ពួកគេ មិនមានខ្លឹមសារដូច សាវតារសាសនារួមគ្នារបស់ជនជាតិទាំងពីរនេះ ។ ជនជាតិទាំងពីរមិនបានព្យាយាមបកស្រាយអំពីដើមកំណើតរបស់ខ្លួនថា ជាជនជាតិចាម ឬជ្វាឡើយ ។ មូលហេតុសំខាន់ គឺកង្វះការយល់ដឹងអំពីដើមកំណើតប្រវត្តិសាស្ត្ររបស់ខ្លួន ។ កង្វះការយល់ដឹងនេះបណ្តាលឲ្យមានភាពលំបាកក្នុងការបែងចែកភាពខុសគ្នារវាងជនជាតិទាំងពីរនេះ ។ ប៉ុន្តែ វាក៏សមហេតុផលម្យ៉ាងដែរ ដែលអ្នកសារព័ត៌មាន និងអ្នកស្រាវជ្រាវជាច្រើន បានចាត់ទុកជនជាតិទាំងពីរក្រុមនេះថា មានជាតិពន្ធុ និង*

សាសនាតែមួយ ។

### ៣) បែបផែនស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ

ជាតិពន្ធុចាមនៅប្រទេសកម្ពុជា មិនត្រូវបានសិក្សាឲ្យបានស៊ីជម្រៅនោះទេ ។ ឯកសារដើមទាក់ទងនឹងជនជាតិចាមត្រូវបានបំផ្លាញ ចំណែកឯ ឯកសារបន្ទាប់បន្សំមានចំនួនតិចតួចបំផុត ។ ដើម្បីឆ្លើយតបនឹងចំណោទសួរខាងលើ អ្នកនិពន្ធនឹងធ្វើការប្រៀបធៀបរវាងអត្តសញ្ញាណចាមមុនរបបខ្មែរក្រហម និងក្រោយរបបខ្មែរក្រហម ដើម្បីកត់សម្គាល់បញ្ហាសំខាន់ៗក្នុងសហគមន៍ចាមនាពេលបច្ចុប្បន្ន (ដូចជាបញ្ហាសាសនា សង្គម និងនយោបាយ) សិក្សាអំពីអង្គការសង្គមស៊ីវិលរបស់សហគមន៍ចាម (រួមមានគោលបំណង មូលនិធិ សកម្មភាពការងារ និងបញ្ហាចោទរបស់អង្គការទាំងនោះ) សិក្សាអំពីទម្រង់ និងឥទ្ធិពលនៃលំហូរសកលលោក ដែលមានចំពោះសហគមន៍ចាម សិក្សាអំពីលក្ខណៈនៃការផ្លាស់ប្តូរថ្មីៗ ការឆ្លើយតបនឹងការផ្លាស់ប្តូរទាំងនោះ ព្រមទាំងវិធីសាស្ត្រទប់ស្កាត់ការផ្លាស់ប្តូរបែបជ្រុលនិយម ។

ដើម្បីប្រមូលទិន្នន័យ អ្នកនិពន្ធបានចុះសិក្សាតាមមូលដ្ឋានសហគមន៍ និងប្រមូលឯកសារបន្ទាប់បន្សំ ។ ការចុះសិក្សាតាមសហគមន៍បែងចែកជាពីរផ្នែកគឺ ៖ ការធ្វើបទសម្ភាសតាមមូលដ្ឋាន និងការអង្កេតការណ៍ ។ ការស្រាវជ្រាវបន្ទាប់បន្សំក៏បែងចែកជាពីរផ្នែកដែរ ៖ ទីមួយគឺការសិក្សាទៅលើឯកសារមួយចំនួនតូច ដែលសរសេរអំពីប្រជាជនមូស្លីមនៅកម្ពុជា ជាពិសេសគឺការសិក្សាអំពីប្រវត្តិសាស្ត្រមូស្លីម និងតាមដានអំពីការចូលមករស់នៅរបស់ជនជាតិចាមក្នុងទឹកដីកម្ពុជា ។ ទីពីរ គឺការវិភាគលើបទសម្ភាសស្តីអំពីបទពិសោធរបស់ជនជាតិចាមក្នុងរបបខ្មែរក្រហម ដែលត្រូវបានរក្សាទុកនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្នុងការសិក្សាអំពីទំនាក់ទំនងពហុជាតិពន្ធុ អ្នកនិពន្ធបានសម្ភាស និងស្ទាបស្ទង់មតិរបស់ប្រជាជនខ្មែរ ។

បន្ថែមលើនេះ ការស្រាវជ្រាវនេះត្រូវបានបែងចែកជាច្រើនដំណាក់កាល និងធ្វើការសិក្សាអំពីចំណេះដឹងមូលដ្ឋានជាច្រើន ។ ទីមួយ ដោយសារតែឯកសារបោះពុម្ពស្តីអំពីជនជាតិចាមនៅមានកម្រិត ការស៊ើបអង្កេតទៅលើក្រុមជាតិពន្ធុចាមគួរតែចាប់ផ្តើមពីការសន្មតជាហានដំបូង ។ គ្មានការយល់ស្រប ស្តីអំពីចំនួនប្រជាជនចាម និងមូស្លីមនៅក្នុងប្រទេសកម្ពុជាឡើយ ។ ដូច្នេះ ការស្រាវជ្រាវនេះ នឹងពិនិត្យមើលតួលេខជាច្រើនដែលទទួលបានពីប្រភពផ្សេងៗគ្នា ។ ចំនួនតួលេខសរុបនៃចំនួនប្រជាជនចាម និងមូស្លីមត្រូវបានដកស្រង់ និងចុះផ្សាយនៅក្នុងទំព័រសារព័ត៌មានជាច្រើន ។ ប៉ុន្តែព័ត៌មានទាំងនេះ មានលក្ខណៈមិនច្បាស់លាស់ និងពុំគួរឲ្យជឿទុកចិត្តឡើយ ។ ការស្រាវជ្រាវក្នុងសៀវភៅនេះ បានរួមបញ្ចូលការធ្វើជំរឿនអំពីចំនួនប្រជាជនមូស្លីមក្នុងប្រទេសកម្ពុជា តាមរយៈការស្ទាបស្ទង់មតិស្តីអំពីចំនួនប្រជាជនសរុបនៅតាមភូមិមូស្លីមមួយចំនួនក្នុងប្រទេសកម្ពុជា ដោយការធ្វើបទសម្ភាសជាមួយនឹងប្រធានភូមិមូស្លីម ហើយបន្ទាប់មកគណនាចំនួនជនជាតិចាមដោយដកចំនួនប្រជាជនជ្វាចេញពីចំនួនមូស្លីមសរុប ។

ទីពីរ សៀវភៅនេះបានសិក្សាអំពីការប្រណិប័តន៍សាសនាអ៊ីស្លាមជាក់លាក់មួយចំនួនដែលមាននៅកម្ពុជា និងភាពខុសគ្នានៃការប្រណិប័តន៍សាសនានៅតាមតំបន់នីមួយៗតាមរយៈការធ្វើបទសម្ភាស និងការចូលរួមក្នុងពិធីប្រពៃណីទាក់ទងនឹងវដ្តជីវិតរបស់សាសនាអ៊ីស្លាមរួមមានពិធីបុណ្យសព ពិធីមង្គលការ បុណ្យរ៉ាម៉ាដាន (Ramadan) បុណ្យម៉ាវលីដ (Mawlid) ថ្ងៃរំឭកអំពីសារសំខាន់នៃកំណើតរបស់មហាម៉ាត់ និងមរណភាពរបស់អ៊ីម៉ាមសាន់ និងថ្ងៃចូលឆ្នាំថ្មីរបស់សាសនាអ៊ីស្លាម ។

ទីបី អ្នកនិពន្ធបានជួប និងសម្ភាសជនជាតិចាមនៅកម្ពុជាជាច្រើននាក់ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ហើយស្របពេលជាមួយគ្នានោះ អ្នកនិពន្ធក៏បានពិភាក្សាជាមួយនឹងប្រជាជនចាម-អាមេរិក និងប្រជាជនចាមដទៃទៀតដែលរស់នៅបរទេសដែលអ្នកទាំងនោះបានធ្វើដំណើរមកកម្សាន្តនៅប្រទេសកម្ពុជា ។ ការពិភាក្សានេះបានផ្តល់ជាឱកាសឲ្យអ្នកនិពន្ធបានជួប និងសម្ភាសអ្នកទាំងនោះដោយទទួលបានផលច្រើនបំផុត ។

### ទីកន្លែងស្រាវជ្រាវ

ជនជាតិចាមរស់នៅតាមតំបន់ផ្សេងៗគ្នាពាសពេញប្រទេសកម្ពុជា ប៉ុន្តែ ខេត្តកំពង់ចាម គឺជាកន្លែងដែលមានជនជាតិចាមរស់នៅច្រើនជាងគេ ទោះបីជា ជនជាតិចាមគឺជាជនជាតិភាគតិច នៅក្នុងខេត្តកំពង់ចាមនេះក៏ដោយ ។ ជនជាតិចាមក៏រស់នៅតាមតំបន់ឆ្នេរសមុទ្រដូចជាខេត្តព្រះសីហនុ និងខេត្តកំពត ។ ជនជាតិចាមមួយភាគ

ធំទៀតរស់នៅតាមដងទន្លេមេគង្គ ដូចជា នៅខេត្តក្រចេះ និងខេត្តកំពង់ឆ្នាំង ។ នៅឯខេត្តបាត់ដំបងវិញមានសហគមន៍ជាដីធំមួយ ។ អ្នកនិពន្ធបានធ្វើដំណើរចុះស្រាវជ្រាវតាមតំបន់ទាំងអស់នេះ ។ រាល់ដំណើរស្រាវជ្រាវនីមួយៗ អ្នកនិពន្ធបានជួបនឹងអ៊ីម៉ាមខេត្ត អ៊ីម៉ាមស្រុក ហាគីម និង ទួន នៅតាមភូមិ ។ អ្នកនិពន្ធក៏បានទៅទស្សនាព្រះវិហារអ៊ីស្លាមនៅតាមភូមិ និងសុរ៉ាវ សំដៅទៅលើព្រះវិហារតូចមួយ ដែលប្រើប្រាស់ជាកន្លែងសម្រាប់បង្រៀន និងសំពះបន់ស្រន់ លើកលែងតែអ្នកដែលសំពះបន់ស្រន់នៅថ្ងៃសុក្រ ហើយអ្នកនិពន្ធក៏បានជួបជាមួយនឹងចាស់ទុំក្នុងភូមិដើម្បីពិភាក្សាអំពីប្រវត្តិ និងវប្បធម៌របស់ជនជាតិចាម ។

ទីក្រុងភ្នំពេញជារាជធានីដែលមានសហគមន៍ចាមដ៏ធំមួយ ។ នៅពេលដែលប្រទេសកម្ពុជាបានផ្លាស់ប្តូររាជធានីពីទីក្រុងឧដុង្គមកកាន់ទីក្រុងភ្នំពេញ ជនជាតិចាមបានផ្លាស់ទីលំនៅមកកាន់ទីក្រុងភ្នំពេញជាមួយនឹងព្រះមហាក្សត្រខ្មែរដែរ ។ ជនជាតិចាមទាំងនោះបានតាំងទីលំនៅនៅតំបន់ជ្រោយចង្វារ ដែលស្ថិតនៅតាមដងទន្លេមេគង្គក្បែរព្រះបរមរាជវាំង ។ អ្នកនិពន្ធបានចុះទស្សនកិច្ចនៅតំបន់មួយចំនួនដូចជា ៖ តំបន់កណ្តាលនៃទីក្រុងភ្នំពេញ តំបន់ព្រែកប្រា (ខាងត្បូងឆៀងខាងកើតទីក្រុងភ្នំពេញ) ប្រាំងចម្រេះ (ខាងជើងទីក្រុងភ្នំពេញ) ព្រែកលៀប (ខាងជើងឆៀងខាងកើត ទីក្រុងភ្នំពេញ) និង តាខ្មៅ (ខាងត្បូងទីក្រុងភ្នំពេញ) ។

## បទសម្ភាសតាមមូលដ្ឋាន

ក្នុងអំឡុងពេលនៃការស្រាវជ្រាវនេះ អ្នកនិពន្ធបានសម្ភាសជនជាតិចាមចំនួន៨៥នាក់ ហើយក៏បានជួបជាមួយនឹងជនជាតិចាមជាច្រើននាក់ផ្សេងទៀត ។ បទសម្ភាសបែងចែកជាពីរផ្នែក ៖ ទីមួយគឺបទសម្ភាសអំពីជីវប្រវត្តិផ្ទាល់មាត់ និងបទសម្ភាសជាក្រុមតូចៗ ។ បទសម្ភាសទាំងពីរប្រភេទនេះមានទាំងគុណសម្បត្តិ និងគុណវិបត្តិ ។ បទសម្ភាសអំពីជីវប្រវត្តិបានអនុញ្ញាតឲ្យអ្នកនិពន្ធស្វែងយល់ និងបង្កើតទំនាក់ទំនងជាមួយនឹងអ្នកចូលរួមក្នុងការស្រាវជ្រាវនេះ ប៉ុន្តែ ត្រូវចំណាយពេលច្រើនគួរសម ។ អាស្រ័យហេតុនេះ ជនជាតិចាមតែមួយចំនួនតូចប៉ុណ្ណោះត្រូវបានជ្រើសរើសសម្រាប់ធ្វើបទសម្ភាសអំពីជីវប្រវត្តិ ។ ការជ្រើសរើសអ្នកផ្តល់បទសម្ភាសធ្វើឡើង ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យមួយចំនួនដូចជា ៖ ការយល់ដឹងស៊ីជម្រៅ និងច្បាស់លាស់របស់អ្នកទាំងនោះទាក់ទងនឹងសហគមន៍ ប្រវត្តិសាស្ត្រ និងវប្បធម៌ចាម រួមទាំងជីវប្រវត្តិដ៏គួរឲ្យចាប់អារម្មណ៍ និងសមត្ថភាពរបស់អ្នកទាំងនោះក្នុងការរៀបរាប់ពីបទពិសោធរបស់ខ្លួន ។ បទសម្ភាសអំពីជីវប្រវត្តិ ក៏បានអនុញ្ញាតឲ្យអ្នកនិពន្ធបានធ្វើការសិក្សាអំពីការវិវត្តនានាក្នុងជីវិតរបស់អ្នកដែលបានចូលរួម ដើម្បីស្វែងយល់អំពីប្រវត្តិសាស្ត្រ និងការវិវត្តរបស់សហគមន៍ចាម ។

អ្នកនិពន្ធបានធ្វើបទសម្ភាសជាក្រុមតូចៗជាមួយនឹងអ្នកចូលរួមប្រមាណ៧០នាក់ ។ អត្ថប្រយោជន៍សំខាន់នៃបទសម្ភាសប្រភេទនេះបានអនុញ្ញាតឲ្យអ្នកនិពន្ធជួបជាមួយនឹងអ្នកចូលរួមច្រើនក្នុងរយៈពេលខ្លីជាងបទសម្ភាសអំពីជីវប្រវត្តិ ។ ភាគច្រើនអ្នកចូលរួមគឺជាមេដឹកនាំសហគមន៍ចាម និងជនជាតិចាមដែលរស់នៅតាមទីប្រជុំជន ដែលតែងតែជាប់រវល់ ហើយមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីផ្តល់បទសម្ភាសដែលមានរយៈពេលវែងនោះទេ ។ លើសពីនេះ បទសម្ភាសជាក្រុមតូចៗ អាចធ្វើឡើងនៅម៉ោងណាក៏បានដោយចំណាយពេលតិចជាងពីរម៉ោងប៉ុណ្ណោះ ហើយមិនប៉ះពាល់ដល់ពេលវេលាសម្រាប់សំពះបន់ស្រន់របស់អ្នកកាន់សាសនាអ៊ីស្លាមឡើយ ។ បទសម្ភាសជាក្រុមតូចៗ នេះត្រូវបានធ្វើឡើងជាមួយនឹងសមាជិកអង្គការសង្គមស៊ីវិល មន្ត្រីរាជការ មេដឹកនាំសាសនា និងអ្នកផ្សេងទៀត ។ ប៉ុន្តែ នៅពេលដែលពេលវេលា និងកាលៈទេសៈអំណោយផល អ្នកនិពន្ធក៏បានជ្រើសរើសអ្នកចូលរួមមួយចំនួនដើម្បីធ្វើបទសម្ភាសអំពីជីវប្រវត្តិដែលមានរយៈពេលវែង ។ អ្នកនិពន្ធបានព្យាយាមសម្ភាស ស្មាន អ៊ីស្មៀល *(Sman Ismael)* ប៉ុន្តែសំណើសុំជួបសម្ភាសន៍ ស្មាន អ៊ីស្មៀល នៅក្នុងគុកត្រូវបានបដិសេធ ។

## ការអង្កេតមើលអ្នកចូលរួម

អស់រយៈពេលជាងបីឆ្នាំ អ្នកនិពន្ធមានទំនាក់ទំនងល្អជាមួយនឹងសហគមន៍ចាមធំៗចំនួនពីរនៅកម្ពុជា ដែលស្ថិតនៅខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង ហើយទីតាំងទាំងពីរនេះបានក្លាយជាទីកន្លែងដ៏អំណោយផលសម្រាប់ការស្រាវជ្រាវតាមបែបចូលរួម ។ លើសពីនេះ ទីកន្លែងផ្សេងទៀតដូចជា សហគមន៍នៅខេត្តកំពតក៏ត្រូវបានជ្រើសរើសសម្រាប់ការស្រាវជ្រាវនេះដែរ ។ អ្នកនិពន្ធបានចូលរួម

ពិធីបុណ្យ ម៉ាវលីដ (*Mawlid*) ដើម្បីរំឭកដល់កំណើតរបស់មហាម៉ាត់ និងពិធីរៀបអាពាហ៍ពិពាហ៍ តាមបែបប្រពៃណី និងពិធីបញ្ចប់បុណ្យរាម៉ាដាន់ (*Ramandan*) ព្រមទាំងពិធីរំឭកដល់មរណភាពរបស់អ៊ីម៉ាម សាន់ (*Imam Sann*) ជាដើម ។

## ការស្រាវជ្រាវបន្ទាប់បន្សំ

ឯកសារមួយចំនួនធំស្តីអំពីការបំផ្លិចបំផ្លាញរបស់សហគមន៍ចាមក្នុងរបបខ្មែរក្រហមត្រូវបានប្រមូល និងរក្សាទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានធ្វើបទសម្ភាសរាប់រយជាមួយជនជាតិចាមទាក់ទងនឹងបទពិសោធដែលឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។ ឯកសារបន្ទាប់បន្សំភាគច្រើនត្រូវបានរៀបរៀងដោយអ្នកប្រាជ្ញទាំងក្នុង និងក្រៅប្រទេស ហើយត្រូវបានប្រមូល និងរក្សាទុកដែរ ។ ឯកសារទាំងនេះត្រូវបានយកមកប្រើប្រាស់ ដើម្បីផ្តល់ជាព័ត៌មានសង្ខេប និងជួយសម្រួលដល់ការឆ្លើយតបនឹងសំណួរខាងលើ ។ ឯកសារបន្ទាប់បន្សំមួយចំនួនទៀតក៏ត្រូវបានប្រមូលដើម្បីរក្សាទុកឯកសារទាំងនោះមានដូចជាអត្តសញ្ញាណសាសនាអ៊ីស្លាម ការស្រោចស្រង់ សាសនាអ៊ីស្លាម ការផុសផុល និងការចាប់ដំណើរការឡើងវិញរបស់សហគមន៍ចាម និងអំពើភេរវកម្ម ។

## ការសរសេរអត្ថបទស្រាវជ្រាវ

ការរក្សាការសម្ងាត់អំពីសមាសភាពរបស់អ្នកចូលរួម គឺជាកត្តាព្រួយបារម្ភមួយដែរ ។ តាមរយៈបទពិសោធរបស់អ្នកនិពន្ធក្នុងការជួបសន្ទនាជាមួយនឹងជនជាតិចាម បានបញ្ជាក់ថា នៅក្នុងសហគមន៍ចាម មានការប្រុងប្រយ័ត្នក្នុងការបង្ហាញពីទស្សនៈយល់ឃើញ ឬរិះគន់ជនជាតិចាមដូចគ្នា ។ ជាមួយគ្នានេះ ក៏មានការព្រួយបារម្ភអំពីការពិភាក្សាអំពីប្រជាជនខ្មែរ ។ ខ្ញុំបានដឹងថាវាមានសារសំខាន់ក្នុងការរក្សាការសម្ងាត់នៃសមាសភាពរបស់អ្នកចូលរួម ដែលមានឆន្ទៈឆ្លុះបង្ហាញពីទស្សនៈដ៏ចម្រូងចម្រាស និងទស្សនៈទាក់ទងនឹងដំណើរការជំរុញនៃជម្លោះក្នុងសហគមន៍ ។

## បញ្ហាប្រឈម និងដំណោះស្រាយ

ការជួបគ្នា និងការសម្ភាសជនជាតិចាមត្រូវតែធ្វើឡើងដោយការពិចារណា ពីព្រោះជនជាតិចាមត្រូវគោរពសំយ៉ាំងប្រាំដងក្នុងមួយថ្ងៃ៖ មុនពេលថ្ងៃរះ ពេលថ្ងៃត្រង់ ពេលរសៀល មុនពេលថ្ងៃលិច និងពេលយប់ ។ សម្រាប់ក្រុមជនជាតិចាម អ៊ីម៉ាម សាន់ ការគោរពសំយ៉ាំង មិនចោទជាបញ្ហាឡើយ ដោយសារក្រុមនេះគោរពសំយ៉ាំងតែពេលថ្ងៃត្រង់រៀងរាល់ថ្ងៃសុក្រប៉ុណ្ណោះ ។ ដូច្នេះ បទសម្ភាសភាគច្រើនត្រូវបានរៀបចំឡើងនៅពេលព្រឹក ពីព្រោះវាអនុញ្ញាតឲ្យអ្នកនិពន្ធមានពេលវេលាច្រើនសម្រាប់ជួបជាមួយនឹងជនជាតិចាម ។ នៅពេលរសៀល ជនជាតិចាមមានពេលវេលាទំនេរប្រមាណតែពីរទៅបីម៉ោងប៉ុណ្ណោះ មុនពេលពួកគេត្រូវគោរពសំយ៉ាំងម្តងទៀត ។

បញ្ហាប្រឈមមួយទៀត នៅពេលសិក្សាពីអំពើភេរវកម្មដែលអាចកើតមានក្នុងសហគមន៍ចាមមូស្លីមនៅកម្ពុជា គឺថាជនជាតិចាមមានការសង្ស័យចំពោះអ្នកស្រាវជ្រាវ ។ មេដឹកនាំសហគមន៍ចាម ភាគច្រើនបានយល់ឃើញថា អ្នកនរវិទូ បន ប្លេងស៊ី (*Bjorn Blengsi*) មានគោលបំណងមិនល្អមកលើសហគមន៍ចាម ។ ប្លេងស៊ីបានសិក្សាស្រាវជ្រាវពីអំពើភេរវកម្មអ៊ីស្លាមនៅប្រទេសកម្ពុជា និងបានសរសេរអត្ថបទអវិជ្ជមានមួយចំនួនទាក់ទងនឹងសហគមន៍ចាមនៅលើទំព័រសារព័ត៌មានជាភាសាអង់គ្លេសដែលបោះពុម្ពក្នុងស្រុក ។ មានសហគមន៍ចាមតាមមូលដ្ឋានមួយចំនួនមិនស្វាគមន៍ចំពោះលោក ប្លេងស៊ី ឡើយ ។ ដោយសារតែក្តីព្រួយបារម្ភថ្មីៗពីក្រុមអ្នកឃ្លាំមើលអន្តរជាតិទាក់ទងនឹងអំពើភេរវកម្មនៅក្នុងប្រទេសកម្ពុជា ជនជាតិចាមងាយនឹងបដិសេធជួបជាមួយនឹងអ្នកស្រាវជ្រាវ ដែលធ្វើការសិក្សាពីបញ្ហាភេរវកម្មនេះ ។ អ្នកនិពន្ធធ្លាប់ត្រូវបានចាប់ឃុំខ្លួនរយៈពេល កន្លះម៉ោងនៅភូមិភ្នំទ្រាពីរ ខេត្តកំពង់ចាម ខណៈពេលដែលគាត់ចូលរួមកម្មវិធី អ៊ីទីម៉ាស (*Ijtimas*) ប្រចាំឆ្នាំ ។ អ្នកនិពន្ធត្រូវបានចោទប្រកាន់ថា បានចូលរួមក្នុងកម្មវិធីនេះដោយគ្មានការអនុញ្ញាត បើទោះបីជាអ្នកនិពន្ធបានទទួលការអនុញ្ញាតពីប្រធានភូមិ និងឃុំរួចហើយក៏ដោយ ។ បទពិសោធនេះ បានឆ្លុះបង្ហាញឲ្យឃើញពីការបែងចែកពីគ្នាដ៏ជាក់លាក់មួយរវាងអំណាចអាជ្ញាធររបស់រដ្ឋាភិបាល និងមេដឹកនាំសាសនា ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការងារជាមួយនឹងជនជាតិចាមអស់រយៈពេលជាងដប់ឆ្នាំមកហើយ ដូច្នេះ ជនជាតិចាមជាច្រើននាក់ស្គាល់ និងទទួលស្វាគមន៍បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សព្វថ្ងៃនេះ អ្នកនិពន្ធគឺជានាយករងនៃមជ្ឈមណ្ឌល

ឯកសារកម្ពុជា ។ អ្នកនិពន្ធបានស្វែងយល់ដឹងយ៉ាងទូលំទូលាយពីឯកសារទាក់ទងនឹងបទពិសោធរបស់ជនជាតិចាមក្នុងរបបខ្មែរក្រហម ដែលត្រូវបានចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជាមួយគ្នានេះ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានបោះពុម្ពសៀវភៅពីរក្បាល និងអត្ថបទជាច្រើនស្តីអំពីបទពិសោធរបស់ជនជាតិចាមក្នុងរបបខ្មែរក្រហម ។

អ្នកនិពន្ធបានទាក់ទងសហគមន៍ចាមតាមរយៈការសិក្សាអំពីបទពិសោធរបស់សហគមន៍ចាមក្នុងរបបខ្មែរក្រហម និងក្រោយរបបខ្មែរក្រហមដើម្បីបង្កើតជាទំនាក់ទំនងយ៉ាងងាយស្រួល រវាងមេដឹកនាំសហគមន៍ចាម និងសមាជិកក្នុងសហគមន៍ ។ អ្នកនិពន្ធបានពិភាក្សាអំពីបញ្ហាអំពើភេរវកម្មជាមួយមេដឹកនាំ និងសមាជិកក្នុងសហគមន៍ចាមនៅដំណាក់កាលចុងបញ្ចប់នៃការស្រាវជ្រាវនេះ ។

## ៤) សេចក្តីសង្ខេបនៃជំពូកនីមួយៗ

ដើម្បីឆ្លើយតបនឹងសំណួរខាងលើ និងសម្រេចគោលបំណងទាំងបីដូចដែលបានកំណត់ សៀវភៅនេះសិក្សាអំពីប្រវត្តិសាស្ត្រជនជាតិចាមដែលអត្តសញ្ញាណរបស់ចាមត្រូវបានបង្កើតឡើង និងផ្លាស់ប្តូរ ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលនៃអត្តសញ្ញាណរបស់ចាមក្នុងអំឡុងពេលផ្សេងៗពីគ្នា និងដើម្បីកំណត់ថា តើការប្រែប្រួលនេះមានជាប់ពាក់ព័ន្ធនឹងអំពើភេរវកម្មរបស់ក្រុមអ៊ីស្លាម និងហាំបាលីយ៉ាងដូចម្តេចខ្លះ ។ តាមរយៈការស្វែងយល់អំពីប្រវត្តិសាស្ត្រ និងអត្តសញ្ញាណរបស់ជនជាតិចាម យើងអាចយល់ដឹងពីគោលជំហរទូទៅស្តីអំពីអំពើភេរវកម្មរបស់ក្រុមអ៊ីស្លាម ហើយក៏អាចកំណត់ពីនិន្នាការរបស់ជនជាតិចាមក្លាយទៅជាជនជ្រុលនិយមប្រើប្រាស់អំពើហិង្សា ។ ការសិក្សាពីបទពិសោធរបស់ជនជាតិចាមកាលពីអតីតកាលអាចឲ្យយើងទទួលបានការយល់ដឹងកាន់តែប្រសើរ អំពីសហគមន៍ចាម ដែលមិនទាន់បានធ្វើការស្រាវជ្រាវឲ្យបានទូលំទូលាយនៅឡើយ ។ គ្រប់ជំពូកទាំងអស់ នៃសៀវភៅនេះក៏សិក្សាអំពីទំនាក់ទំនងរបស់សហគមន៍ចាមក្នុងសកលលោក នៅពេលដែលមានភស្តុតាង បញ្ជាក់ពីឥទ្ធិពល និងទំហំនៃទំនាក់ទំនងជាសកល ដែលបានជះឥទ្ធិពលមកលើអត្តសញ្ញាណរបស់ជនជាតិចាម នៅក្នុងប្រទេសកម្ពុជា ។

**ជំពូកមួយ ៖ សេចក្តីផ្តើម ៖** ផ្តល់ជាសេចក្តីសង្ខេបនៃការស្រាវជ្រាវចំណោទសួរអំពីអត្តសញ្ញាណជនជាតិចាម ការត្រួតពិនិត្យអក្សរសាស្ត្រ និងវិធីសាស្ត្រនៃការស្រាវជ្រាវ ។

**ជំពូកពីរ ៖ ទិដ្ឋភាពទូទៅនៃជាតិពន្ធុចាម ៖** ជំពូកនេះសិក្សាអំពីភាពខុសគ្នារបស់ជនជាតិចាម ដែលធ្វើឲ្យជនជាតិចាមមានជាតិពន្ធុ និងសាសនាខុសប្លែកពីជាតិពន្ធុផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ។ ជំពូកនេះផ្តល់ការវិភាគដ៏លម្អិតមួយស្តីអំពីស្ថានភាពបច្ចុប្បន្ននៃអត្តសញ្ញាណចាម ។ ជំពូកនេះ សិក្សាអំពីភាពជាកម្មសិទ្ធិ និងបុគ្គលិកលក្ខណៈរួមរបស់ចាមដោយពិនិត្យមើលលើទំហំនៃចំនួនជនជាតិចាម ទីកន្លែង មុខរបរ ភាសា សាសនា និងសម្លៀកបំពាក់របស់ចាម ។ យ៉ាងណាមិញ អត្តសញ្ញាណស្នូល និងអត្តសញ្ញាណជាយរបស់ចាមមិនត្រឹមតែជាប់ពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ ភាពជាកម្មសិទ្ធិ និងការប្រតិបត្តិវប្បធម៌រួមគ្នានាពេលបច្ចុប្បន្ននេះប៉ុណ្ណោះទេ បន្ថែមលើនេះ អត្តសញ្ញាណទាំងពីរនេះក៏ត្រូវបានផ្សារភ្ជាប់ស្អិតរមួតជាមួយនឹងប្រវត្តិសាស្ត្រ ដែលបានដក់ជាប់ក្នុងផ្នត់គំនិតរបស់ជនជាតិខ្មែរ និងចាម ។ ប្រវត្តិសាស្ត្ររបស់ចាមត្រូវបានយកមកពិភាក្សាបន្ថែមទៀតនៅក្នុងជំពូកបន្ទាប់ ។

**ជំពូកបី ៖ ជនជាតិចាមនៅក្នុងទស្សនវិស័យប្រវត្តិសាស្ត្រ ៖**

ជំពូកនេះ វិភាគទៅលើទិដ្ឋភាពប្រវត្តិសាស្ត្រស្តីអំពីអត្តសញ្ញាណចាម ។ ការវិភាគនេះមិនមែនផ្តល់បញ្ជីដ៏លម្អិតល្អន់មួយស្តីអំពីការបកស្រាយផ្សេងៗទាក់ទងនឹងប្រវត្តិសាស្ត្ររបស់ជនជាតិចាម ឬវាយតម្លៃលើការបកស្រាយប្រវត្តិសាស្ត្រទាំងនោះ ឬក៏ដើម្បីកំណត់យកប្រវត្តិសាស្ត្រចាមដ៏ពិតប្រាកដមួយនោះទេ ។ គោលបំណងនៃជំពូកនេះគឺដើម្បីផ្តល់ជាសេចក្តីសង្ខេបស្តីអំពីប្រវត្តិសាស្ត្រចាម ដែលនឹងជួយសម្រួលឲ្យយើងអាចស្វែងយល់បន្ថែមអំពីអត្តសញ្ញាណស្នូល និងអត្តសញ្ញាណបន្ទាប់បន្សំរបស់ជនជាតិចាម ។ ជំពូកនេះ ក៏ផ្តល់ការវិភាគលើដើមកំណើតនៃសាសនាអ៊ីស្លាម ដែលប្រណិប័តន៍ដោយជនជាតិចាម ដើម្បីស្វែងយល់អំពីឫសគល់នៃអត្តសញ្ញាណខាងសាសនា ការផ្លាស់ប្តូរនិកាយរបស់សាសនាអ៊ីស្លាមក្នុងអំឡុងពេលកន្លងមក និងការវិវត្តដូចសព្វថ្ងៃនេះដោយរបៀបណា ។ ជំពូកនេះនឹងបញ្ចប់ដោយការវិភាគអំពីការមកដល់នៃរបបខ្មែរក្រហម ។ ប្រវត្តិសាស្ត្រខ្មែរក្រហម ដែលបានកើតឡើងកាលពីសាមសិបឆ្នាំ មុននឹងត្រូវយកមកពិភាក្សានៅក្នុង

ជំពូកមួយដាច់ដោយឡែក ពីព្រោះតែឥទ្ធិពលដ៏ខ្លាំងនៃរបបនេះ បានជះមកលើអត្តសញ្ញាណ និងរបៀបរបបសង្គមរបស់ជនជាតិចាម ។

**ជំពូកបួន ៖ បញ្ហាប្រឈមនៃអត្តសញ្ញាណស្នូល ៖ បទពិសោធរបស់ជនជាតិចាមក្នុងរបបខ្មែរក្រហម** ៖ ជំពូកនេះពិភាក្សាពីទំហំ និងកម្រិតនៃអត្តសញ្ញាណស្នូលមានដូចជា ជាតិពន្ធុ និងខាងសាសនា ដែលត្រូវបានប្រឈមនឹងឥទ្ធិពលផ្សេងៗ ។ ជំពូកនេះវិភាគលើគោលនយោបាយ មនោគមន៍វិជ្ជា និងការអនុវត្តគោលការណ៍របស់ខ្មែរក្រហមចំពោះជនជាតិចាម ។ ជំពូកនេះឆ្លុះបង្ហាញថា បើទោះបីជាគោលការណ៍សម្ងាប់ បង្អត់អាហារ និងធ្វើទារុណកម្មរបស់ខ្មែរក្រហមធ្វើឡើង ដើម្បីផ្លាស់ប្តូរអត្តសញ្ញាណស្នូលរបស់ជនជាតិចាមក៏ដោយអត្តសញ្ញាណស្នូលទាំងនោះនៅតែស្ថិតស្ថេរ ក្រោយរបបខ្មែរក្រហម ។ ប៉ុន្តែ ទិដ្ឋភាពស្តីអំពីអត្តសញ្ញាណជាយរបស់ជនជាតិចាម ដែលមានដូចជា គោលជំហរខាងនិកាយ នយោបាយ និងសេដ្ឋកិច្ចត្រូវបានទទួលរងផលប៉ះពាល់ ។ របបខ្មែរក្រហម ប៉ះពាល់ដល់ទស្សនៈយល់ឃើញរបស់ជនជាតិខ្មែរមកលើជនជាតិចាម និងទស្សនៈយល់ឃើញរបស់ជនជាតិចាមមកលើប្រជាជនខ្មែរ ហើយបណ្តាលឲ្យអត្តសញ្ញាណនយោបាយរបស់ចាម មានការផ្លាស់ប្តូរ ។

ម្យ៉ាងវិញទៀត របបខ្មែរក្រហមគឺជាដំណាក់កាលតែមួយគត់នៃប្រវត្តិសាស្ត្រជនជាតិចាមដែលធ្វើឲ្យអត្តសញ្ញាណស្នូលរបស់ជនជាតិចាមត្រូវបានដកហូត ហើយក៏ជាពេលដែលជនជាតិចាម មានសភាពដូចនឹងជនជាតិខ្មែរ ។ ដូច្នេះ របបខ្មែរក្រហមគឺជាដំណាក់កាលតែមួយគត់ ដែលជនជាតិចាម និងខ្មែរមានអត្តសញ្ញាណខាងសេដ្ឋកិច្ចរួមគ្នា ពោលគឺការប្រែក្លាយជាទាសករពលកម្មរបស់ខ្មែរក្រហម ។

**ជំពូកប្រាំ ៖ ការស្តាបនាឡើងវិញនៃអត្តសញ្ញាណជាយក្រោយរបបប្រល័យពូជសាសន៍** ៖ ជំពូកនេះសិក្សាអំពីវិធីសាស្ត្រផ្សេងៗ ដែលជនជាតិចាមបានអនុវត្តដើម្បីកសាងអត្តសញ្ញាណជាយរបស់ខ្លួនឡើងវិញបន្ទាប់ពីរបបខ្មែរក្រហម អត្តសញ្ញាណខាងនិកាយ នយោបាយ និងសេដ្ឋកិច្ច ។ ដោយសារតែជនជាតិចាមនៅតែបន្តប្រណិប័តន៍សាសនាអ៊ីស្លាម ហើយជនជាតិចាមភាគច្រើនមិនត្រូវបានលុបបំបាត់ប្រវត្តិសាស្ត្ររបស់ខ្លួនទេ ដូច្នេះបានជាអត្តសញ្ញាណស្នូលរបស់ចាមនៅតែរឹងមាំដដែល ។ ជំពូកនេះវិភាគថា តើចាមបានកសាងសហគមន៍ខ្លួនដោយរបៀបណាក្រោយពីឆ្លងផុតរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងក្នុងអំឡុងពេលដែលកម្ពុជាមានការផ្លាស់ប្តូររបបនយោបាយថ្មី ដូចជា របបកុម្មុយនីស្តរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលគាំទ្រដោយរដ្ឋាភិបាលវៀតណាម ។ ដើម្បីកសាងឡើងវិញនូវសហគមន៍របស់ខ្លួន ជនជាតិចាមមិនត្រឹមតែបានស្វែងរកជំនួយក្នុងប្រទេសកម្ពុជា ថែមទាំងស្វែងរកជំនួយ និងការគាំទ្រពីសហគមន៍ក្រៅប្រទេសផងដែរ ។ ជនជាតិចាម មានជម្រើសសំខាន់ៗពីរក្នុងអំឡុងទសវត្សឆ្នាំ៨០គឺ៖ កសាងជីវភាពរស់នៅរបស់ខ្លួនឡើងវិញនៅក្នុងប្រទេសកម្ពុជា ឬ នៅប្រទេសដទៃទៀតដោយជនភៀសខ្លួនទៅកាន់ជំរំភៀសខ្លួននៅតាមព្រំដែនកម្ពុជា-ថៃ ដើម្បីរង់ចាំការផ្លាស់ទីលំនៅថ្មី ។ ជនជាតិចាមមួយចំនួននោះប្រហែលជាបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ។ ជនជាតិចាមទាំងពីរក្រុមនោះ បានបង្កើតអត្តសញ្ញាណនយោបាយដោយឡែកពីគ្នា ក្នុងទម្រង់ជាសមាជិកនៃគណបក្សកាន់អំណាច និងជាសមាជិកនៃគណបក្សប្រឆាំងនៅក្នុងអំឡុងពេលនោះ ។ ជំពូកនេះក៏សិក្សាអំពីការស្តាបនាស្ថាប័នរដ្ឋនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងគោលនយោបាយដែលជះឥទ្ធិពលមកលើជនជាតិចាម ។ ដោយសារតែរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមានគោលនយោបាយផ្តល់សេរីភាពខាងសាសនា ភាពអត់ឱន និងការរួមបញ្ចូលជាតិពន្ធុចាម ក៏ដូចជា គោលការណ៍ឯកបក្សក្នុងអំឡុងជម្លោះនយោបាយ ពេលនោះជនជាតិចាមមានសេរីភាពតិចតួចប៉ុណ្ណោះក្នុងការពង្រីកអត្តសញ្ញាណរបស់ខ្លួនក្នុងអំឡុងទសវត្សរ៍ទី៨០ រហូតមកដល់ទសវត្សរ៍ទី៩០ ។ ជាមួយគ្នានេះ ជំពូកនេះក៏វិភាគអំពីស្ថាប័នសំខាន់ៗ ដូចជាតុលាការប្រជាជនបដិវត្តន៍ គម្រោង«ក៥» និងសមាគមចាម ។ ស្ថាប័នទាំងនេះមានឥទ្ធិពលមកលើកិច្ចខិតខំប្រឹងប្រែងកសាងឡើងវិញនូវអត្តសញ្ញាណនិកាយ និងសេដ្ឋកិច្ចរបស់ជនជាតិចាមក្រោយរបបប្រល័យពូជសាសន៍ ។

**(នៅមានត)**

**អេង កុកថាយ**

# សវនាការបឋមបន្ថែមស្តីពីសំណុំរឿង០០២ ដំណាក់កាលទី២

**(តបប់)**

## ១.ខ) មេធាវីការពារក្តីលោក ខៀវ សំផន

មេធាវីអន្តរជាតិ អង់តា ហ្គីសសេ ការពារក្តី ខៀវ សំផន បានបង្ហាញការយល់ស្របតាមក្រុមមេធាវីការពារក្តី នួន ជា ទាក់ទងនឹងការចាប់ផ្តើមពិភាក្សាដេញដោលនៅក្នុងសវនាការនៃសំណុំរឿង០០២ ដំណាក់កាលទី២ ស្តីពីជម្រោះប្រដាប់អាវុធ និងបញ្ចប់ដោយតួនាទីរបស់ជនជាប់ចោទ ដោយសារអាចប្រើប្រាស់ភស្តុតាងដែលនឹងទាញយកបានពីប្រធានបទទាំងពីរនេះ ។ ប៉ុន្តែ ប្រធានបទដែលនៅចន្លោះរវាងប្រធានបទទាំងពីរនេះ មេធាវីសូមឲ្យគោរពលំដាប់លំដោយនៅក្នុងដីកាដំណោះស្រាយ ដោយចាប់ផ្តើមពីសហករណ៍ និងការដ្ឋានធ្វើការងារ មន្ទីរសន្តិសុខ វិធានការទៅលើក្រុមជាក់លាក់ ការជម្លៀសប្រជាជន និងការរៀបការដោយបង្ខំ ។

មេធាវីបន្តថា បើនិយាយពីសហករណ៍ និងការដ្ឋានការងារនៅក្នុងវគ្គទី២នេះ គួរពិភាក្សាមុនជម្លោះប្រដាប់អាវុធ ដោយសារនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ អង្គជំនុំជម្រះបានពិភាក្សាពីការជម្លៀសប្រជាជន រហូតដល់ការពាក់ព័ន្ធនឹងសហករណ៍ ។ មេធាវីក៏បានបញ្ជាក់ជាថ្មីឡើងវិញថា ជម្លោះប្រដាប់អាវុធជាចំណុចសំខាន់ណាស់ ក្នុងការពិភាក្សាលើប្រធានបទនៅក្នុងការជំនុំជម្រះដំណាក់កាលទី២នេះ ។

## ១.គ) សហព្រះរាជអាជ្ញា

ជាការឆ្លើយតប តំណាងសហព្រះរាជអាជ្ញា បញ្ជាក់ពីការចាំបាច់ឲ្យមានភាពរលូននៃរចនាសម្ព័ន្ធសវនាការ និងតាមលំដាប់លំ



ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ និង០០២ ធ្វើបាតុកម្មតាមទាវសំណាងផ្ទាល់ខ្លួន ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីខែតុលា ឆ្នាំ២០១៤ ខណៈពេលដែលមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ធ្វើពហិការដើរចេញពីបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដោយ សំណើរបស់ខ្លួនស្នើមានការគាំទ្រដោយដើមបណ្តឹងរដ្ឋប្បវេណី ។ សហព្រះរាជអាជ្ញាបានស្នើឲ្យមានសវនាការទៅតាមលំដាប់លំដោយមួយចំនួន ទាក់ទងនឹងការចោទប្រកាន់នៅមន្ទីរសន្តិសុខស-២១ និងជនជាប់ចោទ ។ ជាទូទៅវិធីសាស្ត្របែបនេះ លើកឡើងអំពីបញ្ហាទូលំទូលាយដែលទាក់ទងនឹងរឿងក្តីទាំងមូល ស្របនឹងការគ្រប់គ្រងនៃការជំនុំជម្រះដំបូង ។ មន្ទីរសន្តិសុខស-២១ គឺជាទីតាំងឧក្រិដ្ឋកម្មតំណាងបានល្អបំផុតទាក់ទងនឹងការចោទប្រកាន់ពីសហឧក្រិដ្ឋកម្មរួមទាក់ទងនឹងការតម្រង់ទៅរកខ្មាំង ។ មន្ទីរសន្តិសុខស-២១ ក៏ជាប់ពាក់ព័ន្ធខ្លាំងនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន និងនួន ជា និងជាទីតាំងឧក្រិដ្ឋកម្មដែលទាក់ទងទៅមជ្ឈិមបក្សរបស់បក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងទាក់ទងផ្ទាល់នឹងមជ្ឈិមបក្សដែលទទួលអ្នកទោសមកពីទូទាំងប្រទេស ។ មានរចនាសម្ព័ន្ធរដ្ឋបាល និងការបញ្ជូនទាំងអ្នកទោសយោធា ជនស៊ីវិលរបស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីដោះស្រាយអំពីការបោសសម្អាតផ្ទៃក្នុង ។ តួនាទីរបស់ជនជាប់ចោទបង្ហាញពីមូលដ្ឋានដែលសំខាន់ថា ជាសហឧក្រិដ្ឋកម្មរួម និងជាផ្នែកទី២ បើនិយាយអំពីមន្ទីរសន្តិសុខបី រួមមាន មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ។ សហព្រះរាជអាជ្ញាយល់ឃើញថា នេះវាជាលំដាប់លំដោយ មួយដែលអាចបន្តនឹងការកំណត់មុខសញ្ញានៅក្រុមពិសេស ដូចជាក្រុមជនជាតិចាម និងជនជាតិវៀតណាម ។ មុននឹងចូលទៅដល់នយោបាយដាច់ដោយឡែកមួយ ដែលនិយាយអំពីការប្រតិបត្តិនៅសហករណ៍ និងការដ្ឋានពលកម្មដូចជា ការដ្ឋានទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង ព្រះរាជអាជ្ញាបានស្នើឲ្យមានសវនាការស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយមានការចោទប្រកាន់លើបទល្មើសទូទាំងប្រទេស ។ ព្រះរាជអាជ្ញាស្នើសុំឲ្យស្តាប់អ្នកជំនាញ និងសាក្សីជំនាញនាពេលចុងបញ្ចប់ ។ សហព្រះរាជអាជ្ញាយល់ថា ពុំមានសារប្រយោជន៍នោះទេ ក្នុងការបើកសវនាការដាច់ដោយឡែក ដែលនិយាយតែពីភ័ស្តុតាងប្រដាប់អាវុធអន្តរជាតិ ពីព្រោះថាបញ្ហានេះមិនបង្កើតជាស្នូល មូលដ្ឋាននៃដីកាដំណោះស្រាយនោះឡើយ ។ យោងតាមវិធាន៨៧.១ សហព្រះរាជអាជ្ញាមានបន្ទុក ក្នុងការបង្ហាញភ័ស្តុតាងគ្រប់ការចោទប្រកាន់ទាំងអស់ ដូច្នេះព្រះរាជអាជ្ញាបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់លំដាប់លំដោយ ហើយព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះគោរពតាមលំដាប់លំដោយដែលខ្លួនបានស្នើសុំ ។

### ១.ឃ) មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានគាំទ្រសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាទាក់ទងនឹងលំដាប់លំដោយនៃការបង្ហាញភ័ស្តុតាង ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏គាំទ្រសំណើរបស់សហព្រះរាជអាជ្ញាដែរ ដែលសុំឲ្យអង្គជំនុំជម្រះសម្រេចតាមផ្នែកនីមួយៗ និងសូមឲ្យអង្គជំនុំជម្រះសម្រេចអំពីការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់សក្ខីកម្ម ដើម្បីឲ្យខ្លួនអាចកំណត់បញ្ជីនៅពេលដែលកំណត់ផ្នែកនីមួយៗរួច ។ មេធាវីក៏សូមឲ្យអង្គជំនុំជម្រះកំណត់អំពីតម្លៃភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដោយសារការមកផ្តល់សក្ខីកម្មមានប្រយោជន៍បំផុត ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

### ២) ការពិនិត្យបឋមលើបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសក្ខីភាព

មុននឹងចូលដល់ការពិនិត្យលើបញ្ជីឈ្មោះបុគ្គលដែលអាចសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានផ្តល់ព័ត៌មានថ្មីៗចុងក្រោយ ដោយសង្ខេបអំពីការដាក់បញ្ជីឈ្មោះ ឯកសារ និងវត្ថុតាង ។ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគីដាក់បញ្ជីឈ្មោះ ឯកសារ និងវត្ថុតាងថ្មីៗចុងក្រោយ ដែលភាគីមានបំណងចង់បង្ហាញនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ ឯកសារ (E៣០៥) ។ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ ក្រុមមេធាវីការពារក្តី នួន ជា បានជូនដំណឹងដល់អង្គជំនុំជម្រះថា ដោយសារ ក្រុមមេធាវីការពារក្តីនេះពុំបានដាក់បញ្ជីឈ្មោះឯកសារ និងវត្ថុតាងដំបូង ដោយផ្អែកតាមដីកាបង្គាប់របស់អង្គជំនុំជម្រះឲ្យដាក់សម្ភារត្រៀមរៀបចំសម្រាប់ការជំនុំជម្រះនៅក្នុងឆ្នាំ២០១១ទេនោះ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តី នួន ជា មិនអាចមានលទ្ធភាពផ្តល់ព័ត៌មានថ្មីៗចុងក្រោយអំពីបញ្ជីទាំងនេះបានទេ ។ នៅក្នុងពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូង កំពុងពិនិត្យមើលបញ្ជីទាំងនេះ ។ ជាលទ្ធផលអង្គជំនុំជម្រះសាលាដំបូងរកឃើញថា ឯកសារជាច្រើននៅក្នុងបញ្ជីថ្មីទាំងនេះ ពុំត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីដំបូងរបស់ភាគីឡើយ ។

អង្គជំនុំជម្រះបានរំឭកដល់ភាគីទាំងអស់ថា ភាគីអាចស្នើសុំឲ្យមានសវនាការជាអសាធារណៈ បើពុំដូច្នេះទេ ការពិភាក្សានឹងនៅតែបន្តធ្វើជាសាធារណៈដោយ ប្រើរហស្សនាម ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ជូនដល់ភាគី កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៤ ។ រហូតមកដល់ពេលនេះ ភាគីបានធ្វើការស្នើសុំឲ្យបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីចំនួន៨៨នាក់ អ្នកជំនាញចំនួន២០នាក់ សាក្សីចំនួន២២១នាក់ ។ សហព្រះរាជអាជ្ញាបានស្នើសុំសាក្សីបម្រុងចំនួន៣៦នាក់បន្ថែមទៀត ។

ក្រោយពីបានពិចារណាលើបញ្ជីឈ្មោះកាន់តែច្រើនរបស់ភាគី និងរយៈពេលដែលត្រូវការសម្រាប់ស្តាប់សក្ខីកម្មបុគ្គលទាំងនេះ អង្គជំនុំជម្រះសូមអញ្ជើញភាគីពិភាក្សាអំពីលទ្ធភាពកាត់បន្ថយចំនួនបុគ្គលនៅក្នុងបញ្ជីរបស់ភាគីនីមួយៗ ។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ ក្រុមមេធាវីការពារក្តី នួន ជា បានដាក់បញ្ជីឈ្មោះបុគ្គលថ្មីៗមួយចំនួន សាក្សី៥នាក់ និងអ្នកជំនាញម្នាក់ ដើម្បីមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញា ដាក់សំណើដើម្បីសុំឲ្យកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលមិនមាននៅក្នុងបញ្ជីដើមរបស់ខ្លួន ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីឆ្នាំ២០១១ សម្រាប់សំណុំរឿង០០២ ។ សំណើសុំនេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល៨ថ្ងៃ ក្រោយពេលដែលសហព្រះរាជអាជ្ញាបានដាក់បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលខ្លួនបានកែតម្រូវ និងមានរយៈពេលតែពីរថ្ងៃប៉ុណ្ណោះ មុនចាប់ផ្តើមសវនាការបឋមបន្ថែមនេះ ។

អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ចំពោះសំណើនេះថា ធ្វើឡើងដោយយឺតយ៉ាវបំផុត ហើយទំនងជាយឺតពេលដើម្បីអាចពិភាក្សាបញ្ហានេះឲ្យបានពេញលេញនៅក្នុងសវនាការ ។ សហព្រះរាជអាជ្ញា បានដកចេញសាក្សីចំនួន៧នាក់ពីបញ្ជីសាក្សីដែលបានកែតម្រូវសម្រាប់សំណុំរឿង០០២ ដំណាក់កាលទី២ ។ ប៉ុន្តែ សហព្រះរាជអាជ្ញាស្នើសុំដាក់ជំនួសសាក្សី៣នាក់ ដែលបានដកចេញនេះដោយជំនួសមកវិញនូវសាក្សីបម្រុងម្នាក់ និងសាក្សីម្នាក់ទៀតពីបញ្ជីសាក្សីដែលបានដាក់កាលពីឆ្នាំ២០១១ ។ សហព្រះរាជអាជ្ញា ក៏បានស្នើសុំដាក់បញ្ចូលបុគ្គលម្នាក់ទៀតទៅក្នុងបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ខ្លួនសម្រាប់សំណុំរឿង០០២ ដំណាក់កាលទី២ផងដែរ ។ ប្រសិនបើកិច្ចការរៀបចំទាំងនេះ មិនអាចដំណើរការសវនាការបានដោយរលូនទេ នឹងអាចនាំឲ្យមានការពន្យារពេលវេលាចាប់ផ្តើមសវនាការ ឬការប្រព្រឹត្តទៅដោយរលូននៃសំណុំរឿង០០២ ដំណាក់កាលទី២ ។ អង្គជំនុំជម្រះបានផ្តល់ឱកាសជូនភាគីនានាឆ្លើយតបដោយផ្ទាល់មាត់នឹងសំណើរបស់សហព្រះរាជអាជ្ញា ឬដាក់សារណាតបជាលាយលក្ខណ៍អក្សរស្របតាមវិធានផ្ទៃក្នុងនៅពេលក្រោយ ។

អង្គជំនុំជម្រះបានបន្តថា ខ្លួននឹងធ្វើការពិចារណាលើការជំទាស់របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ចំពោះបុគ្គលមួយចំនួនដែលសហព្រះរាជអាជ្ញា បានស្នើនៅក្នុងបញ្ជីថ្មី និងអំណះអំណាងដែលក្រុមមេធាវីការពារក្តីនេះបានលើកឡើងថា ខ្លួនពុំមានព័ត៌មានគ្រប់គ្រាន់ពាក់ព័ន្ធនឹងបុគ្គលមួយចំនួន និងវិសាលភាពនៃការជំនុំជម្រះសម្រាប់ឲ្យខ្លួនធ្វើការវាយតម្លៃទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើនោះឡើយ ។

## ២.ក) ភាគីសហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គូមជាន បានស្នើឲ្យមានការកាត់បន្ថយថ្ងៃបើកសវនាការក្នុងករណីដែលមានបណ្តឹងសាទុក្ខលើសំណុំរឿង០០២ ដំណាក់កាលទី១ ។ សហព្រះរាជអាជ្ញាក៏បានគិតពិចារណាយ៉ាងប្រុងប្រយ័ត្នអំពីសំណើរបស់អង្គជំនុំជម្រះឲ្យមានការកាត់បន្ថយសាក្សី និងយល់អំពីតម្រូវការក្នុងការធ្វើឲ្យសវនាការនេះឆាប់រហ័ស និងមានប្រសិទ្ធភាព ។

ការិយាល័យសហព្រះរាជអាជ្ញាព្យាយាមផ្តោតការជ្រើសរើសសាក្សីដែលខ្លួនគិតថា ជាប់ពាក់ព័ន្ធនឹងសំណុំរឿងធំបំផុត និងធ្វើការពិនិត្យទៅលើភស្តុតាង ។ នៅពេលនេះការិយាល័យសហព្រះរាជអាជ្ញា បានស្នើសាក្សីចំនួន១២៣រូប ហើយសាក្សីទាំងអស់នេះភាគច្រើនគឺជាសាក្សីនៃទីតាំងឧក្រិដ្ឋកម្មដែលមានលទ្ធភាពផ្តល់សក្ខីកម្មបាន ព្រមទាំងអាចនឹងចំណាយពេលផ្តល់សក្ខីកម្មត្រឹមតែ១១១ថ្ងៃតែប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញាបានបន្តទៀតថា សាក្សីទាំងអស់នេះអាចបង្ហាញអំពីធាតុផ្សំនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក៏ដូចជាទីតាំងឧក្រិដ្ឋកម្មទាំងអស់ទៀតផង ។

## ២.ខ) សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ ម៉ារី ហ្គីរ៉ូដ៍ បានរំឭកពីចំនួនសរុបរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលខ្លួនតំណាងឲ្យជារួមមាន៣៨៦៧រូប ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ គឺជាភាគីនៃសំណុំរឿង ដូច្នេះមានសិទ្ធិចូលរួមក្នុងការជម្រះសេចក្តី ដោយមានសិទ្ធិអំណាចស្មើគ្នានឹងជនជាប់ចោទ ក៏ដូចជាសហព្រះរាជអាជ្ញាដែរ ។ មេធាវីបន្តថា ស្ថានភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចប្រៀបធៀបនឹងសាក្សី ក៏ដូចជាអ្នកជំនាញបាននោះឡើយ ។ វាពុំអាចទៅរួចឡើយ ក្នុងការស្តាប់ ដើមបណ្តឹងរដ្ឋប្បវេណីទាំង៣៨៦៧នាក់ ដូច្នេះ មេធាវីព្យាយាមកាត់បន្ថយចំនួនដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្លួនចង់ឲ្យមកផ្តល់សក្ខីកម្ម ។ កាលខែមេសា មេធាវីនាំមុខបានផ្ញើបញ្ជីទី១ ដែលមាន១៧២នាក់ ចំណែកមកទល់ពេលនេះ ខ្លួនបានកាត់បន្ថយមកត្រឹម៧៧នាក់ប៉ុណ្ណោះ ។

មេធាវីបានបន្ថែមទៀតថា ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះផ្តល់អត្ថប្រយោជន៍ពីរគឺ ទី១ៈ ជាជនរងគ្រោះដោយផ្ទាល់នៃឧក្រិដ្ឋកម្ម និងទី២ៈ នៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ គាត់អាចផ្តល់សក្ខីកម្មទាក់ទងនឹងឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្ត ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំង៧៧នាក់នេះមានលក្ខណៈចាំបាច់ណាស់ទៅលើវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ដំណាក់កាលទី២នេះ ។ ប្រសិនបើ អង្គជំនុំជម្រះគិតថាត្រូវតែបន្ថយបញ្ជីនេះទៀត មេធាវីនាំមុខនឹងសុំឲ្យតុលាការធ្វើការវាយតម្លៃតាមប្រធានបទនីមួយៗ ។ មេធាវីនាំមុខនឹងស្នើសុំឲ្យតុលាការកំណត់អត្តិភាពនៃដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងតម្លៃជាភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសារសំខាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការពិភាក្សានៅក្នុងសវនាការ ។ មេធាវីនាំមុខក៏បានស្នើសុំឲ្យតុលាការបដិសេធការជំទាស់របស់ក្រុម ខៀវ សំផន ដែលទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចមកធ្វើសក្ខីកម្មទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទដែលជាបញ្ហាសំខាន់ក្នុងការជម្រះក្តីនេះ ។

មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ្រ អង្គ បានលើកឡើងពាក់ព័ន្ធនឹងការជំទាស់របស់ក្រុមការពារក្តីលោក ខៀវ សំផន លើការកោះហៅសាជាថ្មីរបស់ដើមបណ្តឹងរដ្ឋប្បវេណី លេខ២TCCP២៣៧ ។ មេធាវីនាំមុខបានធ្វើការឆ្លើយតបថា ជាការពិតដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានការព្រួយបារម្ភអំពីបញ្ហាសុវត្ថិភាពដោយថាហេតុរបស់ខ្លួន និងក្រុមគ្រួសាររបស់គាត់ ក្នុងករណីដែលគាត់ផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងសកម្មភាព ឬព័ត៌មានអំពីជនជាប់ចោទដោយផ្ទាល់ ។ អាស្រ័យហេតុដូច្នេះ ទើបគាត់សុំឲ្យមានវិធានការការពារ ដែលក្រុមមេធាវីយល់ថា ជាការសមស្របមួយដែរ ។ ក៏ប៉ុន្តែ ដោយពិនិត្យអំពីលទ្ធភាព ដែលពុំអាចទទួលបាននូវវិធានការការពារ និងពិនិត្យអំពីសារសំខាន់នៃព័ត៌មានរបស់គាត់ក្នុងការផ្តល់ជាភ័ស្តុតាងនៅក្នុងការបង្ហាញការពិតចំពោះមុខអង្គសវនាការ ដើមបណ្តឹងរដ្ឋប្បវេណីយល់ថា សវនាការ០០២ ដំណាក់កាលទី២ នេះគឺជាឱកាសតែមួយគត់របស់គាត់ក្នុងការផ្តល់សក្ខីកម្ម ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីបានយកបញ្ហាសុវត្ថិភាពទុកមួយកន្លែង ហើយគិតអំពីការចង់ផ្តល់សក្ខីកម្ម ដើម្បីជាប្រយោជន៍នៃការស្វែងរកយុត្តិធម៌វិញ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់អំពីចេតនារបស់ខ្លួនយ៉ាងច្បាស់លាស់នៅក្នុងការមកផ្តល់សក្ខីកម្ម និងបានធ្វើលិខិតជាលាយលក្ខណ៍អក្សរមួយផ្ញើមកតាមរយៈមេធាវីផ្ទាល់ខ្លួនរបស់គាត់ជូនមកការិយាល័យមេធាវីនាំមុខ ។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ២TCCP២៣៧នេះ ផ្ទុកនូវព័ត៌មានដែលសំខាន់របស់ជនជាប់ចោទទាំងពីររូប ដែលបានផ្តល់ការបង្រៀននៅក្នុងបុរីកីឡា និងជាព័ត៌មាន ដែលបញ្ជាក់អំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ តាមរយៈខ្លឹមសារនៃការបង្រៀននេះ ព្រមទាំងជាធាតុមួយដ៏សំខាន់បញ្ជាក់ធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួម ។

## ២.ត) មេធាវីការពារក្តី នួន ជា

ក្រុមមេធាវីការពារក្តី នួន ជា មេធាវី គូប៉េ បានធ្វើការជំទាស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងការស្នើសាក្សីថ្មីរបស់ខ្លួន ។ មេធាវីការពារក្តី បានជម្រាបជូនអង្គជំនុំជម្រះថា ក្រុមរបស់ខ្លួនបានប្រឹងប្រែងបញ្ជាក់ និងកាត់បន្ថយបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសរុបមានចំនួន៥២៧នាក់ ដែលបានស្នើនៅឆ្នាំ២០១១ ក្នុងរឿងក្តី០០២ ទាំងមូល ។ ឥឡូវនេះមេធាវីបានកាត់បន្ថយបញ្ជីនោះច្រើនជាង៩០ភាគរយ ។ មេធាវីបន្តថា ខ្លួនបានស្នើចំនួនសរុបតែសាក្សី៤៣នាក់ប៉ុណ្ណោះ នៅក្នុងនោះត្រូវបានបន្ថែមចំនួន៦នាក់ថ្មី ។ មេធាវីលើកឡើងថា ខ្លួនស្នើតែសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលមានសារសំខាន់ក្នុងការ

បង្ហាញភ័ស្តុតាង ។ បុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងអស់នោះ មានសក្ខីកម្មពិសេស ដែលមិនអាចមានអ្នកណាជំនួសបាន គឺអ្នកជំនាញ ៧TCE៨៥ ហើយក្រុមរបស់ខ្លួនជឿជាក់ថា អ្នកជំនាញរូបនេះអាចផ្តល់សក្ខីកម្មជំនាញ ។

មេធាវីជាតិ សួន វិសាល ការពារក្តី នួន ជា បានស្នើសុំតុលាការអនុញ្ញាតឲ្យប្រើឈ្មោះរបស់សាក្សីជំនួសរហស្សនាម ហើយអង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់មេធាវីដែលអនុញ្ញាតឲ្យប្រើប្រាស់រហស្សនាម ឬក៏នាមរបស់សាក្សី ។ មេធាវីបានឆ្លើយតបទៅភាគីសហព្រះរាជអាជ្ញា ដែលបានជំទាស់ការកោះអញ្ជើញសាក្សីចំនួន៣រូបមកបំភ្លឺក្នុងតុលាការនេះ រួមមាន ទី១) សម្តេច ហេង សំរិន ទី២) សម្តេច ជា ស៊ីម និង ទី៣) ឯកឧត្តម អ៊ុក ប៊ុនឈឿន ។ មេធាវីលើកឡើងថា ការជំទាស់របស់សហព្រះរាជអាជ្ញាជាតិ ពុំមានមូលដ្ឋានច្បាប់ច្បាស់លាស់នៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដើម្បីបដិសេធសាក្សីទាំងនេះមកបំភ្លឺនៅចំពោះមុខតុលាការនោះទេ ។ សហព្រះរាជអាជ្ញាគ្រាន់តែសំអាងថា សាក្សីទាំងនោះមានតួនាទីសំខាន់នៅក្នុងរាជរដ្ឋាភិបាល ។ មេធាវីបន្តថា តាមច្បាប់ការស្នើសុំកោះអញ្ជើញសាក្សីមកបំភ្លឺនៅចំពោះមុខតុលាការ មិនទាក់ទងនឹងមុខតំណែងសាក្សីទាល់តែសោះ ។ កត្តាសំខាន់ គឺសាក្សីទាំងនោះបានដឹងបានឮនូវព្រឹត្តិការណ៍នានាទាក់ទងនឹងរឿងក្តី ដែលជាចំណែកមួយក្នុងការស្វែងរកការពិត និងយុត្តិធម៌ជូនជនរងគ្រោះ ក៏ដូចជាជនជាប់ចោទ ។ សាក្សីទាំងនោះពិតជាបានដឹងនូវរាល់បញ្ហានានាដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ១៩៧៥ រហូតមកដល់ឆ្នាំ១៩៧៩ ។ ជាពិសេសសកម្មភាពរបស់ពួកគាត់ ដែលធ្លាប់បានធ្វើជាកម្មាភិបាលនៅភូមិភាគបូព៌ា ហើយក្រោយមកបានរត់គេចទៅប្រទេសវៀតណាម ដើម្បីបង្កើតចលនាតស៊ូផ្ទៃក្នុង និងរួមគ្នាផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីបន្ថែមទៀតថា បើនិយាយទៅតាមផ្លូវច្បាប់វិញ ជនគ្រប់រូបត្រូវទទួលបានភាពស្មើគ្នាចំពោះមុខច្បាប់នេះ មានន័យថា ការអនុវត្តច្បាប់ត្រូវគោរព ឬអនុវត្តដូចៗគ្នា មិនថាជននោះមានឋានៈ មានតួនាទី អ្នកក្រ ឬអ្នកមាននៅក្នុងសង្គមឡើយ ។ លើសពីនេះ គ្មានបញ្ញត្តិណាមួយទាំងនៅក្នុងច្បាប់ជាតិ ច្បាប់អន្តរជាតិ ឬក៏នៅក្នុងវិធានផ្ទៃក្នុងនៃអ.វ.ត.ក ដែលអនុញ្ញាតឲ្យសាក្សីមានជម្រើសអាចផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរនឹងសំណួរដោយគ្មានវត្តមានរបស់ចៅក្រមទេ ។ មេធាវីបានព្យាយាមលើកអំណះអំណាងតាមផ្លូវច្បាប់ទៀតថា តាមពិតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុងសាក្សីអាចឆ្លើយសំណួរនៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរបាន ប្រសិនបើសាក្សីទាំងនោះគ ឬថ្លង់ ។ ចំណុចនេះមានបញ្ជាក់យ៉ាងច្បាស់នៅក្នុងមាត្រា៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទោះជាក្នុងស្ថានភាពបែបនេះក៏ដោយ សំណួរត្រូវសួរទៅសាក្សីនៅចំពោះមុខប្រធានអង្គជំនុំជម្រះ ហើយផ្តល់ជូននូវសំណួរទាំងនោះទៅសាក្សីតាមរយៈក្រឡាបញ្ជី ។

សាធារណជនទូទៅ ក៏បានដឹងច្បាស់ថា ស្ថានភាពសុខភាពរបស់សាក្សីទាំងបីរូបខាងលើនេះមានលក្ខណៈល្អប្រសើរ ហើយគ្មានសាក្សីណាម្នាក់មានជំងឺគ ឬថ្លង់ នោះទេ ។ ហេតុនេះវាមិនមានមូលដ្ឋានច្បាប់ ដើម្បីអនុញ្ញាតឲ្យសាក្សីទាំងនោះឆ្លើយនឹងសំណួរជាលាយលក្ខណ៍អក្សរ ជំនួសដោយការផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ដូចការស្នើសុំរបស់សហព្រះរាជអាជ្ញាជាតិនោះទេ ។ ក្នុងការគោរពច្បាប់ និងការចូលរួមចំណែកក្នុងការកសាងសង្គមជាតិដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញមាត្រា៤៩ ដោយហេតុថា ដំណើរការជំនុំជម្រះក្តីនៅក្នុងតុលាការនេះ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ។

កាតព្វកិច្ចទាំងនេះអាចមើលឃើញថា មានតម្លៃខ្ពស់ ដោយហេតុថា សូម្បីតែតំណាងរាស្ត្រដែលមានតំណែងជាន់ខ្ពស់នៅក្នុងរាជរដ្ឋាភិបាល ក៏ចូលមកឆ្លើយបំភ្លឺនៅចំពោះមុខតុលាការដែរ ។ នេះជាគំរូល្អសម្រាប់ប្រជាពលរដ្ឋខ្មែរ និងសង្គមជាតិទាំងមូលក្នុងការគោរពច្បាប់ និងធានាឲ្យបានឯករាជភាពរបស់តុលាការ ។ ដូច្នេះការជំទាស់របស់សហព្រះរាជអាជ្ញានេះ មិនគួរលើកឡើងនោះទេ ។ លោកមេធាវី វិសាល បានបន្តទៀតថា សាក្សីនេះអាចផ្តល់សក្ខីកម្មសំខាន់បំផុតក្នុងចំណោមសាក្សីដទៃទៀត ។ សាក្សីសម្តេច ហេង សំរិន អាចផ្តល់សក្ខីកម្មយ៉ាងច្បាស់លាស់នូវរាល់បញ្ហានានាដោយហេតុថា សម្តេច ហេង សំរិន ជាកម្មាភិបាលមួយរូបនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អង្គហេតុទាំងនោះ រួមមាន ការបះបោរនៃយោធានៅក្នុងភូមិភាគបូព៌ា និងតួនាទីរបស់ សោ ភឹម និងកម្មាភិបាលផ្សេងៗទៀត ការចងសម្ព័ន្ធភាពរវាងភូមិភាគពាយ័ព្យជាមួយ

នឹងក្រុមប្រឆាំងរបបកម្ពុជាប្រជាធិបតេយ្យ ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម និងគោលបំណងយ៉ាងយូរមកហើយរបស់វៀតណាមក្នុងការប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណុចមួយទៀតទាក់ទងនឹងការប្រល័យពូជសាសន៍ជនជាតិវៀតណាមនៅភូមិភាគបូព៌ា ព្រឹត្តិការណ៍លើជនជាតិចាមនៅភូមិភាគបូព៌ា ការបោសសម្អាតផ្ទៃក្នុង និងផែនការរួមផ្សេងៗទៀត ដែលត្រូវអនុវត្តនៅតាមតំបន់ផ្សេងៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានដាក់ចេញ ។ ដូចគ្នានេះដែរ សាក្សីសម្តេច ជា ស៊ីម និងឯកឧត្តមអ៊ុក ប៊ុនឈឿន ក៏អាចផ្តល់សក្ខីកម្មដ៏មានសារសំខាន់បំផុតទាក់ទងនឹងអង្គហេតុដែលបានជម្រាបជូនខាងលើដោយហេតុថាបុគ្គលទាំងពីរនេះ មានឋានៈ និងតួនាទីប្រហាក់ប្រហែលគ្នា ។ ដូច្នេះ ការជំទាស់របស់សហព្រះរាជអាជ្ញា ត្រូវបានលោកមេធាវីវិសាល កត់សម្គាល់ថា មិនមែនតែលោកម្នាក់ទេដែលពិចារណាឃើញថា សាក្សីទាំងបីមានសារសំខាន់សូម្បីតែសហព្រះរាជអាជ្ញាអន្តរជាតិផ្ទាល់ក៏ពុំបានចុះហត្ថលេខាលើការជំទាស់នោះដែរ ។

មេធាវីបានបន្ថែមថា អតីតសហព្រះរាជអាជ្ញាអន្តរជាតិក៏បានគាំទ្រដីហរបស់មេធាវីការពារក្តី នួន ជា ដែរ ។ ចំពោះសាក្សីឯកឧត្តម ប៉ុល សារឿន សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា ការស្នើសុំកោះអញ្ជើញហៅមកបំភ្លឺនៅចំពោះមុខតុលាការនេះ មានលក្ខណៈយឺតយ៉ាវ ។ ការជំទាស់នេះ ពុំអាចទទួលយកបានទេដោយសារវាខុសទាំងស្រុងនឹងគោលការណ៍ច្បាប់ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌគឺមាត្រា៣២១ ដែលបញ្ជាក់យ៉ាងច្បាស់ថាភាគីទាំងអស់មានសេរីភាពពេញលេញក្នុងការផ្តល់ភស្តុតាង ។ ចំណុចមួយទៀតគឺមាត្រា៣៣៤ ដែលបញ្ជាក់យ៉ាងច្បាស់អំពីការដាក់ភស្តុតាងបានចែងយ៉ាងច្បាស់ថា ភាគីទាំងអស់អាចដាក់ភស្តុតាងជូនតុលាការ ដរាបណាតុលាការមិនទាន់បិទការសួរដេញដោល ។ ដូច្នេះការដាក់ភស្តុតាងថ្មីនេះបង្ហាញឲ្យឃើញថាក្រុមមេធាវីរបស់ខ្លួនមានមូលដ្ឋានច្បាប់ច្បាស់លាស់ ដើម្បីដាក់ភស្តុតាងថ្មីជូនអង្គសវនាការ ដើម្បីស្វែងរកការពិត និងយុត្តិធម៌ ។

មេធាវីការពារក្តីស្នើសុំឲ្យតុលាការបដិសេធការជំទាស់របស់សហព្រះរាជអាជ្ញាជាតិ ហើយយល់ព្រមទទួលសំណើរបស់ខ្លួនដើម្បីកោះអញ្ជើញសាក្សីទាំង៣រូប មកចូលរួមនៅចំពោះមុខតុលាការដោយក្តីអនុគ្រោះ និងតាមច្បាប់ ។

## ២.ឃ) មេធាវីការពារក្តី ខៀវ សំផន

មេធាវី គង់ សំអុន ការពារក្តី ខៀវ សំផន បានធ្វើការឆ្លើយតបការជំទាស់របស់ខ្លួនចំពោះ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងការស្នើសុំមកឆ្លើយបំភ្លឺជាថ្មីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម ២TC-CP២៣៧ ។ មេធាវីការពារក្តី បានធ្វើការវាយតម្លៃថា ការទាមទារឲ្យមានការកោះមកឆ្លើយបំភ្លឺជាថ្មី ដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីគឺជាការហួសពេលទៅហើយ ។

មេធាវីបានផ្តល់ហេតុផលថា សាក្សីរូបនេះត្រូវ មកឆ្លើយបំភ្លឺតាំងពីក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ម្ល៉េះ ក៏ប៉ុន្តែត្រូវបានបដិសេធការឆ្លើយបំភ្លឺ ដោយមូលហេតុសាក្សីទាមទារឲ្យមានវិធានការការពារខ្លួន ។ តាមខ្លឹមសារពាក់ព័ន្ធនឹងការចង់មកឆ្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលនោះការពិភាក្សារបស់អង្គជំនុំជម្រះរកឃើញថា ជាប់ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង០០២ដំណាក់កាលទី១ ។ ដូច្នេះ វាលែងជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០២ដំណាក់កាលទី២នេះទៀតហើយ ។ មេធាវីបានបន្ថែមទៀតថា ក្នុងករណីនេះ គេអាចយល់បានថា វាហួសពេលសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមកផ្តល់ការធ្វើសក្ខីកម្មជូនអង្គជំនុំជម្រះ ដោយហេតុថា អង្គជំនុំជម្រះបានសម្រេចនូវកិច្ចបំបែកនីតិវិធី ដែលកម្រិតនូវវិសាលភាពទៅតាមសំណុំរឿងនីមួយៗ ដែលមានសំណុំរឿង០០២ ដំណាក់កាលទី១ និងសំណុំរឿង០០២ ដំណាក់កាលទី២ រួចទៅហើយ ។ មេធាវីក៏បានឆ្លើយតបចំពោះការជំទាស់របស់ខ្លួនទាក់ទងនឹងការអញ្ជើញសាក្សីជំនាញមួយរូប ដែលមានរហស្សនាម ២TC-E៨២ ដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានជំទាស់ដោយផ្តល់ហេតុផលថា សាក្សីជំនាញរូបនេះពុំមានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ធ្វើជាអ្នកជំនាញ ។

បន្ទាប់ពីក្រុមមេធាវីការពារក្តី ខៀវ សំផន បញ្ចប់សេចក្តីថ្លែងរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បានប្រកាសបិទបញ្ចប់សវនាការបឋមបន្ថែមសម្រាប់សំណុំរឿង០០២ ដំណាក់កាលទី២ នេះ នៅម៉ោងប្រមាណ៣រសៀល ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ។

**ក្រុមសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម**

# ការឆ្លើយតបទៅអត្ថបទរបស់ រ៉េនឌុល ដឹហ្វាលកូ ៖ ការបកស្រាយពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានយុត្តាធិការលើ «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត» ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ អ.វ.ត.ក ។ អត្ថបទរបស់លោក រ៉េនឌុល ដឹហ្វាលកូ មានចំណងជើងថា សំណុំរឿង០០៣ និង ០០៤ នៅសាលាក្ដីខ្មែរក្រហម ៖ និយមន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ផ្អែកលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ សន្និដ្ឋានថា ជនសង្ស័យក្នុងសំណុំរឿង០០៣ និង ០០៤ អាចត្រូវបានចាត់ទុកថា ជាបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត ដូច្នេះមានតែយន្តការផ្លូវច្បាប់ត្រឹមត្រូវតែមួយគត់គឺការជំនុំជម្រះសំណុំរឿងទាំងពីរ ។ ការវិភាគរបស់ រ៉េនឌុល គឺជាការវិភាគមួយដែលមានលទ្ធផលកំណត់ទុកមុនហើយជាស្រេច និងផ្អែកទៅលើការសន្មតដែលថា ប្រសិនបើជនសង្ស័យមិនត្រូវបានរកឃើញថាជាបុគ្គលទទួលខុសត្រូវខ្ពស់បំផុតទេ នោះការជំនុំជម្រះក៏ពុំអាចកើតមានឡើង ហើយជនសង្ស័យអាចនឹងរួចផុតពីការទទួលខុសត្រូវនៃឧក្រិដ្ឋកម្ម ។ ទោះបីជាវិធីសាស្ត្រមូលដ្ឋានរបស់ រ៉េនឌុល ក្នុងការកំណត់និយមន័យនៃពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" មានលក្ខណៈសមហេតុផល ប៉ុន្តែ គាត់បានប្រព្រឹត្តកំហុសមួយចំនួននៅក្នុងការវិភាគរបស់គាត់ ហើយកំហុសទាំងអស់នេះបានបណ្ដាលឲ្យមានសេចក្ដីសន្និដ្ឋានកំណត់ទុកជាមុនរបស់គាត់ ។ ការសន្និដ្ឋានបែបនេះរបស់ រ៉េនឌុល ពុំមែនជាអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ ប្រសិនបើយើងពិចារណាអំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា និងចំណាប់អារម្មណ៍ក្នុងការបញ្ជាក់អំពីសេចក្ដីសន្និដ្ឋានទុកជាមុនរបស់មជ្ឈមណ្ឌលនេះដែលថា មានអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលធ្លាប់កើតឡើងក្នុងប្រទេសកម្ពុជា ។ អត្ថបទនេះនឹងវិភាគអំណះអំណាងរបស់ រ៉េនឌុល ។

## ១) សេចក្ដីផ្ដើម

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បង្កើតឡើងដើម្បីកាត់ទោស «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលបានប្រព្រឹត្តពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ ។ អត្ថន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" និង "មេដឹកនាំជាន់ខ្ពស់" មានភាពចម្រូងចម្រាស ពីព្រោះពាក្យទាំងពីរមិនត្រូវបានកំណត់ន័យច្បាស់លាស់នៅក្នុងឯកសាររបស់ អ.វ.ត.ក មានដូចជា ច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឲ្យឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង) ។ ពាក្យទាំងពីរមានសារសំខាន់ណាស់សម្រាប់សំណុំរឿងដែលយកមកជំនុំជម្រះនៅសាលាក្ដីខ្មែរក្រហម ពីព្រោះវានឹងចង្អុលបង្ហាញថា បុគ្គលណានឹងត្រូវនាំយកមកកាត់ក្ដី ។

នៅក្នុងសំណុំរឿងទីមួយនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អតីតមេគុកខ្មែរក្រហម កាំង ហ្គេកអ៊ាវ (ហៅ ឌុច) បានទាមទារឲ្យតុលាការដោះលែងខ្លួនដោយលើកហេតុផលថា

ខ្លួនមិនមែនជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដូច្នេះខ្លួនពុំស្ថិតនៅក្រោមដែនយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា ឌុច ស្ថិតនៅក្រោមដែនយុត្តាធិការរបស់តុលាការដែលបានកំណត់ត្រឹមតែមេដឹកនាំកំពូលរបស់ខ្មែរក្រហមដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត និងអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមផ្សេងៗទៀត ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសខ្ពស់បំផុត ។ អង្គជំនុំជម្រះបានរកឃើញថាពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ តែពាក្យនេះជាគោលការណ៍នៃការស៊ើបអង្កេត និងការចោទប្រកាន់ ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលអាក់ខានមិនបានកំណត់ន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឲ្យបានច្បាស់លាស់នោះទេ ។

ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា វ៉េនឌល បានបោះពុម្ពផ្សាយអត្ថបទមួយ ដែលលោកពិចារណាអំពីអត្ថន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ វ៉េនឌល ធ្វើការសន្និដ្ឋានថា ជនសង្ស័យទាំង៤នាក់ ដែលត្រូវបានសន្មតថា ជាប់ទាក់ទងនឹងសំណុំរឿង០០៣ និង ០០៤ ស្ថិតក្នុងលំដាប់នៃជនដែលត្រូវបានចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដូច្នេះមិនមានយន្តការផ្លូវច្បាប់ណាសក្តិសម ក្រៅពីបន្តការជំនុំជម្រះ ។ វ៉េនឌល ធ្វើសេចក្តីសន្និដ្ឋាននេះដោយវិភាគលើសាលក្រមសំណុំរឿង០០១ នៃអង្គជំនុំជម្រះ តុលាការកំពូលច្បាប់អនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលារការកម្ពុជា យុត្តិសាស្ត្រនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងនីតិវិធីទាំងឡាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗ ។ វ៉េនឌល ពន្យល់អំពីលក្ខណៈ វិនិច្ឆ័យចម្បងចំនួនពីរគឺ ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ បន្ទាប់មក សង្ខេបដោយផ្អែកទៅលើយុត្តិសាស្ត្រដែលលោកបានពិនិត្យថាមាន "ប្រភេទបុគ្គលជាក់លាក់ដែលតែងតែត្រូវបានយកមកកាត់ទោស" ។ ក្រោយមក លោកពិនិត្យទៅលើបទចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង ០០៤ និងធ្វើសេចក្តីសន្និដ្ឋានថា ជនសង្ស័យទាំងអស់នេះត្រូវចាត់ទុកថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ទោះបីវិធីសាស្ត្រមូលដ្ឋានរបស់ វ៉េនឌល ក្នុងការកំណត់និយមន័យនៃពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" គាត់បង្កើតកំហុសមួយចំនួនមុននឹងឈានដល់សេចក្តីសន្និដ្ឋានរបស់គាត់ដែលបានកំណត់ទុកមុនរួចទៅហើយ ។ គាត់ប្រព្រឹត្តខុស ដោយសារតែគាត់សន្មតជាមុនថា ការដែលអាចកើតមានឡើងនៃការមិនបន្តជំនុំជម្រះសំណុំរឿង០០៣ និង ០០៤ បណ្តាលមកពីឥទ្ធិពលខាងក្រៅ មិនមែនមកពីគោលការណ៍ច្បាប់ និងអាក់ខានមិនបានពិចារណាលើព័ត៌មានទាក់ទងនឹងប្រវត្តិចរចានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមទាំងការប្រៀបធៀបមិនត្រឹមត្រូវជាមួយតុលាការដទៃ ដែលគ្មានភាពស្រដៀងគ្នាសំខាន់ណាអាចយកមកប្រៀបធៀបគ្នាបាន ។ លើសពីនេះទៅទៀត វ៉េនឌល ខកខានមិនបានទទួលស្គាល់ថាគោលបំណងនៃការស៊ើបអង្កេតធ្វើឡើងដើម្បីកំណត់ថាតើមានភស្តុតាងគ្រប់គ្រាន់ដើម្បីបន្តសវនាការដែរឬទេ?

ការវិភាគរបស់ វ៉េនឌល មានកំហុស ហើយកំហុសនេះកើតចេញពីការវិភាគ ដែលផ្អែកលើការកំណត់លទ្ធផលទុកជាមុនរបស់គាត់ ។ ការវិភាគរបស់ ដីហ្វាលកូ គឺផ្អែកលើសេចក្តីសម្អាងដែលថាជនសង្ស័យក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវតែយកមកកាត់ទោស ពីព្រោះអ្នកទាំងនោះគួរតែត្រូវបានចាត់ទុកជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ប្រសិនបើអ្នកទាំងនោះមិនត្រូវបានយកមកកាត់ទោសទេ ជនសង្ស័យទាំងអស់នេះនឹងរួចផុតពីការទទួលខុសត្រូវឧក្រិដ្ឋកម្ម ។ សេចក្តីសន្និដ្ឋានដែលបានកំណត់ទុកជាមុនរបស់ វ៉េនឌល បានប៉ះពាល់ទៅដល់ការវិភាគរបស់គាត់ទាក់ទងនឹងពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" និងសំណួរដែលចោទសួរថា តើជនសង្ស័យក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវចាត់ទុកជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរ ឬទេ? អត្ថបទនេះនឹងពិភាក្សាអំពីកំហុសទាំងឡាយនៅក្នុងការវិភាគរបស់ វ៉េនឌល និងពន្យល់ថាស្ថាបនិកនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានបំណងពន្យល់ពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឲ្យមានន័យចង្អៀត ។

### ៧) សេចក្តីសម្អាងមិនត្រឹមត្រូវរបស់ វ៉េនឌល ៖ ការបង្កើតឲ្យមានភាពលម្អៀងមួយយ៉ាងច្បាស់

ជាដំបូង វ៉េនឌុល ពន្យល់អំពីភាពចម្រូងចម្រាសជុំវិញ សំណុំរឿង០០៣ និង ០០៤ ។ បន្ទាប់មក គាត់សង្ខេបអំពីសេចក្ដីសម្រេចលើយុត្តាធិការផ្ទាល់ក្នុងសាលក្រមសំណុំរឿង០០១ របស់អង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែរកឃើញថា សេចក្ដីសម្រេចនេះពុំបានជួយដល់ការផ្ដល់និយមន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ។ វ៉េនឌុល ពិនិត្យទៅលើប្រវត្តិចរចាជុំវិញការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកំពូល និងច្បាប់ទាំងឡាយដើម្បីបង្កើតសាលាក្ដីនេះ ប៉ុន្តែរកឃើញរាជរដ្ឋាភិបាលកម្ពុជា រួមទាំងអង្គការសហប្រជាជាតិ មិនបានកំណត់និយមន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះទេ ។ ក្រោយមក គាត់រកឃើញសេចក្ដីណែនាំក្នុងមាត្រា១២ កថាខណ្ឌ១ នៃកិច្ចព្រមព្រៀង ដែលបានចែងថា៖

> *នីតិវិធីត្រូវតែអនុលោមតាមច្បាប់របស់ប្រទេសកម្ពុជា ។ នៅពេលដែលច្បាប់ប្រទេសកម្ពុជាមិនដោះស្រាយចំពោះបញ្ហាមួយចំនួន ឬនៅពេលដែលមិនមានភាពច្បាស់លាស់ប្រជាទាក់ទងនឹងការបកស្រាយ ឬ ការបកស្រាយវិធានផ្ទៃក្នុងពាក់ព័ន្ធក្នុងច្បាប់ប្រទេសកម្ពុជា ឬនៅពេលដែលមានសំណួរទាក់ទងនឹងភាពមិនស្របគ្នានៃវិធានផ្ទៃក្នុងជាមួយនឹងបទដ្ឋានអន្តរជាតិ សេចក្ដីណែនាំនោះ អាចត្រូវបានស្វែងរកក្នុងវិធាននីតិវិធីដែលបានបង្កើតនៅក្នុងកម្រិតអន្តរជាតិ ។*

បន្ទាប់ពីរកឃើញថាច្បាប់កម្ពុជាផ្ដល់នូវសេចក្ដីណែនាំមិនគ្រប់គ្រាន់ វ៉េនឌុល ងាកទៅពិនិត្យលើយុត្តិសាស្ត្រ និងនីតិវិធីនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលគាត់កំណត់លក្ខណៈវិនិច្ឆ័យពីរសំខាន់គឺ ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ។ វ៉េនឌុល សន្និដ្ឋានថា "តាមរយៈទស្សនៈនៃការអនុវត្តច្បាប់នៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិ...ជាទូទៅ វាច្បាស់ដែលថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅពេលដែលបុគ្គលនោះជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ" ។ បន្ទាប់ពីពន្យល់អំពីបទចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង ០០៤ ដោយផ្អែកទៅលើឯកសារដែលត្រូវបានអះអាងថា ជាដីកាបញ្ជូនសំណុំរឿងទាំងពីរឲ្យស៊ើបសួរត្រូវបានបែកធ្លាយ គាត់សន្និដ្ឋានថា ជនសង្ស័យទាំងអស់ត្រូវចាត់ទុកជា "អ្នកទទួលខុសត្រូវខ្ពស់" ។ គាត់អះអាងថា បរាជ័យណាមួយដោយមិនបាននាំយកសំណុំរឿង០០៣ និង ០០៤ មកជំនុំជម្រះ គួរតែចាត់ទុកថា ជាបច្ច័យនៃការវិនិច្ឆ័យដោយមិនមានលក្ខណៈវិជ្ជាជីវត្រឹមត្រូវ និងមិនមានសុចរិតភាព ។

សំណុំរឿង០០៣ និង ០០៤ មានភាពចម្រូងចម្រាសដោយសារតែមានការខ្វែងគំនិតគ្នាថា តើជនសង្ស័យដែលជាប់ពាក់ព័ន្ធគួរតែចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់" ដែរឬទេ ។ ជាដំបូង សហព្រះរាជអាជ្ញាមានការខ្វែងគំនិតថាតើការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង ០០៤ គួរតែបើកដែរឬទេ ពីព្រោះអ្នកទាំងនោះមិនទាន់យល់ព្រមថា ជនសង្ស័យទាំងអស់ត្រូវចាត់ទុកជា "អ្នកទទួលខុសត្រូវ ខ្ពស់" ។

អង្គបុរេជំនុំជម្រះមិនអាចស្វែងរកសំឡេងភាគច្រើនដាច់ខាតដើម្បីចេញសេចក្ដីសម្រេចលើការខ្វែងគំនិតរបស់សហព្រះរាជអាជ្ញា ដែលជាលទ្ធផលនាំឲ្យមានការបើកការស៊ើបអង្កេតរបស់តុលាការក្នុងសំណុំរឿងទាំងពីរ ។ សហចៅក្រមស៊ើបអង្កេតបានបិទការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ នៅខែមេសា ឆ្នាំ២០១១ ដោយមិនបានចោទប្រកាន់ជនសង្ស័យណាមួយឡើយ ។

**(នៅមានត)** **ម៉ៃឃើល កាណាវ៉ាស់**

# អានទស្សនាវដ្ដីតាមគេហទំព័រ

ទស្សនាវដ្ដីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ទូច ឈុំ និងការតស៊ូ




ទូច ឈុំ ជាអតីតយោធាខ្មែរក្រហមមួយ ដែលធ្លាប់ឆ្លងកាត់សមរភូមិជាច្រើនអំឡុងពេលប្រយុទ្ធជាមួយនឹងកងទ័ពសាធារណរដ្ឋខ្មែរ ។ ការចូលរួមរបស់គាត់ជាមួយនឹងចលនាខ្មែរក្រហម គឺ ដោយសារតែគាត់យល់ថា លន់ នល់ ជាជនក្បត់ជាតិ ទើបបានជាគាត់ស្ម័គ្រចិត្តចូលរួមតស៊ូ ដើម្បីប្រឆាំងជាមួយ លន់ នល់ ។ ឈុំ គឺជាកូនទី៣ ក្នុងគ្រួសារកសិករមួយដែលមានបងប្អូនប្រុសស្រី៧នាក់ ។ ឪពុករបស់ ឈុំ ឈ្មោះ ញ៉ាំង សឿង (ស្លាប់) និងម្តាយ ឆាយ ប៊ូ (ស្លាប់) ។ អ្នកទាំងអស់គ្នារស់នៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

កាលពីក្មេង ឈុំ បានរៀនសូត្រត្រឹមថ្នាក់ទី១០ ប៉ុណ្ណោះ នៅសាលាអមលាំង ។ នៅឆ្នាំ ១៩៦៥ ដោយសារតែជីវភាពគ្រួសារមានការលំបាក និងជាពិសេស ម្តាយរបស់គាត់ដែលជាជំហរនៅក្នុងគ្រួសារបានទទួលមរណភាពទៀតនោះ ឈុំ បានឈប់រៀន ហើយត្រឡប់មកជួយមើលគោ ក្របី និងថែរក្សាប្អូនៗជាមួយឪពុកវិញ ។ រហូតដល់ឆ្នាំ១៩៦៧ ឈុំ បានសម្រេចទៅបួសជាសង្ឃនៅវត្តកន្ទែងសំ ក្នុងភូមិអមលាំង ប៉ុន្តែការបួសនេះ បានត្រឹមតែមួយឆ្នាំប៉ុណ្ណោះ គាត់ក៏សឹកត្រឡប់មកធ្វើស្រែចម្ការដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារដែលមានបងប្អូនប្រុសស្រីប្រាំពីរនាក់វិញ នៅឆ្នាំ១៩៧០ ។

ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ មានចលនារបស់ខ្មែរក្រហម បានចូលមកឃោសនាអប់រំនៅភូមិស្រុករបស់ ឈុំ ។ ខ្មែរក្រហមលើកថា លន់ នល់ គឺជាជនក្បត់ជាតិ ហេតុនេះ សូមឲ្យបងប្អូនទាំងអស់នាំគ្នាចូលព្រៃតស៊ូប្រឆាំងនឹង លន់ នល់ ។ ឈុំ បានស្ម័គ្រចិត្តចូលធ្វើជាទ័ពឃុំ ដោយមាននាទីជាឈ្លបឃុំ ។ ពេលនោះ នៅភូមិនីមួយៗនៅក្នុងឃុំមានអ្នកចូល២-៣នាក់ សរុបប្រហែល១០-១១នាក់ ដែលអ្នកទាំងនោះ ត្រូវចាត់ឲ្យធ្វើជាឈ្លបឃុំ ដើម្បីយាមការពារភូមិឃុំ ដែលមាន តាឆែ ជាគណៈឃុំព្រៃជ្រៅ ជាអ្នកគ្រប់គ្រង ។ នៅអំឡុងឆ្នាំ១៩៧១ ក្រោយពីធ្វើឈ្លប ឃុំបាន៤ខែ ឈុំ ត្រូវថ្នាក់លើចាត់តាំងឲ្យទៅធ្វើទ័ពស្រុកវិញ គឺនៅស្រុកជ្រាវ និងឱរ៉ាល់ ដោយមានឈ្មោះ យឿន ជាប្រធាន ។ ទ័ពស្រុក នៅពេលនោះ មានគ្នាប្រហែល ៣០នាក់ប៉ុណ្ណោះ ដែលមានភារកិច្ចវាយតាមផ្លូវជាតិលេខ៤ ។ ការវាយនេះ គឺមិនមែនជាការប្រឆាំងតទល់នឹងទ័ពសាធារណរដ្ឋខ្មែរជាទ្រង់ទ្រាយធំនោះទេ គ្រាន់តែវាយជាលក្ខណៈឈ្លបប៉ុណ្ណោះ ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧១ដដែល សមាជិកទ័ពស្រុកទាំង៣០នាក់នេះ ត្រូវបានថ្នាក់លើបញ្ចូលជាកងតំបន់វិញ ដែលកាលណោះ ជាតំបន់៣២ ហើយទ័ពតំបន់នេះ មានមួយវរសេនាតូច ដែលមានសមាជិកជាង ៣០០នាក់ ។

ឈុំ នៅទ័ពតំបន់ ដោយមាននាទីជាមេក្រុម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តា ឃឹម ប្រធានតំបន់ ។ មិនយូរប៉ុន្មាន ទ័ពតំបន់នេះ ត្រូវបញ្ចូលទៅជាទ័ពភូមិភាគទៀត ដែលហៅថា ភូមិភាគនិរតី ។ ភូមិភាគនិរតី នៅពេលនោះ មិនទាន់មានការរៀបចំជាកងពលឲ្យបានច្បាស់លាស់នោះទេ គឺនៅកងវរសេនាតូចឯករាជ្យរៀងៗខ្លួននៅឡើយ រហូតដល់ឆ្នាំ១៩៧៣ ទើបមានការរៀបចំជាកងពល ។ តមកទៀតថ្នាក់លើបានចាត់តាំងឲ្យកងវរសេនាតូចនីមួយៗ មកវាយនៅខាងកំពត តាមផ្លូវជាតិលេខ៤ ក្នុងនោះមាន៣កងវរៈគឺ កង១៣១, កង១៧០ និងកង១៨០ ដែលមាន តាស្រស់ ជាអ្នកក្តាប់រួមទាំង៣កង ។

នៅឆ្នាំ១៩៧៤ អង្គការដកគាត់មកវាយខាងកំពង់ឆ្នាំងវិញ ដែលពេលនោះ វរៈ១៣១ ដកមកបញ្ចូលក្នុងកងពលទី១វិញ ហើយកងវរៈ២ទៀត រក្សានៅដដែល ។ កងពលទី១នេះមាន តាសឿង ជាប្រធាន និង ស៊ូ ម៉េត ជាអនុប្រធានទទួលរៀបចំកម្លាំងវាយខាង

កំពង់ឆ្នាំង មកខាងលិចលផ្ទៃក និងខត្តក្ក ។ ក្នុងគណៈកងពលនេះមាន តាសឿង, តាម៉េត និងតាល្វៃ ជាសមាជិក ។ ស្ថិតក្នុងតួនាទីជាអនុសេនាធំក្នុងវរសេនាតូច១៣១ ឈុំ បានឲ្យដឹងថា អំឡុងឆ្នាំ១៩៧៤ នេះ ការប្រយុទ្ធគ្នារវាងទាហានខ្មែរក្រហម និង លន់ នល់ មិនទាន់សម្រុកខ្លាំងណាស់ណាទេ គឺវាយសាចុះសាឡើង រហូតដល់ឆ្នាំ១៩៧៥ ទើបចាប់ផ្ដើមសម្រុកវាយយកភ្នំពេញ ចូលទៅតាមច្រកបាសិត ដោយសហការជាមួយកងពលភូមិភាគខត្ដរ ។ យុទ្ធសាស្ត្រវាយ គឺវាយរំកិលខ្សែត្រៀម ដោយពេលនោះសម្ភារ អាវុធ គឺមានគ្រប់គ្រាន់ ។ ឈុំ បាននំរឭកថា សភាពការណ៍ពេលនោះ គឺតឹងតែងណាស់ ហើយគាត់ ចូលទៅមុខសញ្ញាខាងពោធិ៍ចិនតុង ។ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលក្រុមរបស់ ឈុំ ចូលដល់ពោធិ៍ចិនតុងនោះ គាត់បានឃើញប្រជាជនធ្វើដំណើរចេញមកបណ្ដើរៗហើយ ។ កងរបស់គាត់ គឺនៅឈរជើងការពារត្រឹមពោធិ៍ចិនតុងនេះជាមួយកងវរៈដទៃទៀត នៅខាងលិចកងវរៈមួយទៀតនៅខាងប៉ុស្តិ៍វិទ្យុ និងកងវរៈផ្សេងទៀតនៅចោមចៅ ។

ក្រោយជ័យជម្នះនេះ កងពលទី១របស់តាសឿង ត្រូវអង្គការដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគបស្ចិម ហើយតាម៉េត ត្រូវឲ្យមកកាន់កងពល៥០២ របស់អគ្គសេនាធិការវិញ ។ ឈុំ មិនបានផ្លាស់ទៅណាទេ គឺនៅជាមួយ តាម៉េត នៅកងពល៥០២ ដោយមាននាទីជាអនុសេនាធំដដែល ឈរជើងការពារព្រលានយន្ដហោះ និងជួយធ្វើស្រែ លើកទំនប់ ជីកប្រឡាយ ជាមួយប្រជាជន ។ ឈុំ និយាយថា "ខ្ញុំជួយធ្វើស្រែផង ការពារផង និង ចែកកម្លាំងគ្នាយើង ឧទាហរណ៍ថា មួយអនុសេនាធំ ចេញអ៊ីចឹងទៅ ទៅធ្វើស្រែ មួយអនុសេនាធំខ្ញុំទៅជួយធ្វើស្រែប្រជាជន ២អនុសេនាធំនៅការពារ នឹងខ្ញុំមួយកងវរៈវាមាន៣អនុសេនាធំ ។ ដូរគ្នាទៅកន្លះខែ ម្នាក់អ៊ីចឹងទៅ វិលមកការពារក្រុងអ៊ីចឹងទៅ ។" ឈុំ រំឭកថា អំឡុងពេលនៅពោធិ៍ចិនតុង គាត់ក៏ធ្លាប់បានទៅប្រជុំនៅស្តាតអូឡាំពិកដែរ ដែលពេលនោះ គាត់បានឃើញ ប៉ុល ពត, ខៀវ សំផន និងនួន ជា ដែលជាគណៈអចិន្ត្រៃយ៍ ។ ការប្រជុំនៅពេលនោះ គាត់មិនសូវជាចងចាំច្បាស់ទេ ព្រោះវាកន្លងផុតមកច្រើនឆ្នាំហើយ ។ ប៉ុន្តែច្រើនតែលើកអំពីការកសាងប្រទេសជាតិប៉ុណ្ណោះ ។ អំឡុងពេលដែលជួយធ្វើការប្រជាជន ចំពោះរបបហូបចុក ឈុំ បានឲ្យដឹងថា យើងជាទ័ពក៏ហូបដូចប្រជាជនដែរ ហើយបើនិយាយពីរឿងហូបឆ្អែតនោះ គឺមិនឆ្អែតនោះទេ ហើយក៏មិនមាននរណាស្ងួរដេញដោលដែរ ព្រោះឃើញថា ប្រជាជនក៏ហូបរបបដូចយើងដែរ ។ ឈុំ បានរៀបការជាមួយនារី រុន នៅខាងកាត់ដេរវដ្ឋ ក្នុងឆ្នាំ១៩៧៧ ប៉ុន្តែមិនសូវបានរស់នៅជាមួយគ្នាទេ គឺប្រពន្ធនៅខាងកាត់ដេរឯគាត់នៅខាងព្រលានយន្ដហោះពោធិ៍ចិនតុង ។ បន្ទាប់ពី ឈុំ ត្រូវអង្គការដកទៅខាងកំពង់ឆ្នាំង គាត់បានជួបប្រពន្ធគាត់តែម្ដងគត់ពេលដែលគាត់ត្រូវទៅព្រំដែន ហើយធ្វើដំណើរកាត់ភ្នំពេញ ។ តាំងពីពេលនោះមក គាត់ក៏បែកពីប្រពន្ធរហូត ។

ក្រោយមកទៀត ក៏មានការចាប់ខ្លួនចំពោះកងទ័ព ក៏ដូចជាកម្មាភិបាលមួយចំនួនដែរ ដែលបានប្រព្រឹត្តកំហុស ឬត្រូវអង្គការចោទថា ក្បត់ ។ ឈុំ ធ្លាប់ឮពីគុកទួលស្លែង ប៉ុន្តែគាត់មិនបានដឹង ថាគុកនោះនៅទីណានោះទេ? ។

នៅឆ្នាំ១៩៧៧ ឈុំ ត្រូវអង្គការដកមកខាងកំពង់ឆ្នាំងវិញ ដើម្បីធ្វើព្រលានយន្ដហោះ ដែលពេលនោះ ឈុំ ដកទៅជាមួយនឹងមនុស្ស២-៣នាក់ ទៀតប៉ុណ្ណោះ ដោយមានឈ្មោះ ប៊ិត វរសេនាតូចជាអ្នកដកទៅ ។ ការងារនៅទីនោះ គឺ ផ្ទាក់ដី រើសស្មៅ ជីកថ្មទៅក្រាលផ្លូវ និងយកអាឡូកិនបង្ហាប់រួចទើបចាក់បេតុង ។ ព្រលាននេះ ធ្វើឡើងដើម្បីដាក់យន្ដហោះចម្បាំង ។ ឈុំ បានឲ្យដឹងថា មានមនុស្សប្រហែលមួយម៉ឺននាក់ដែលមកធ្វើនៅការដ្ឋានព្រលានយន្ដហោះកំពង់ឆ្នាំងដែលមកពីគ្រប់កងពល មិនដឹងជាកងពលណាខ្លះទេ ។ អ្នកគ្រប់គ្រងនៅការដ្ឋានព្រលានយន្ដហោះកំពង់ឆ្នាំងនេះ គឺមាន តាម៉េត ប៉ុន្តែគាត់មិននៅគ្រប់គ្រងជាប់លាប់នោះទេ គឺចេញចូលទៅមក ។ របបអាហារដែលទទួលបាន គឺមានបាយហូប ព្រោះថា អ្នកទាំងអស់គ្នាត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ។ គ្រប់កងធ្វើទៅតាមជំនាញរៀងខ្លួន កងខ្លះជំនាញធ្វើផ្លូវ កងខ្លះពង្រាបដី ជាដើម ។

នៅចុងឆ្នាំ១៩៧៨ ឈុំ ត្រូវអង្គការដកទៅព្រំដែន ដើម្បីទប់ទល់ជាមួយនឹងវៀតណាមនៅខាងក្រចេះ ។ ឈុំ ត្រូវធ្វើដំណើរត្រឡប់មកព្រលានយន្ដហោះពោធិ៍ចិនតុង រួចជិះយន្ដហោះបន្តដំណើរទៅចុះនៅក្រចេះ ហើយបន្តដំណើរទៅស្នួល និងជប់ ។ អ្នករួមដំណើរជាមួយគាត់នៅពេលនោះមានគ្នាតែ៧នាក់ប៉ុណ្ណោះ ព្រោះមានអ្នកទៅមុនពីរលើករួចមកហើយ ក្រុមរបស់ ឈុំ គឺ តាម៉េត ដក

ទៅក្រោយគេ ។ ពេលដក ឈុំ ទៅទីនោះ គាត់ត្រូវអង្គការដំឡើងនាទីជាវរសេនាតូច ។ ពេល ឈុំ ទៅដល់បានកន្លះខែ កងទ័ពវៀតណាម វាយចូលតាមចម្ការកៅស៊ូជប់កងរបស់ ឈុំ ក៏ថយ ដោយទប់ទល់បានពីរលើក តែអត់ឈ្នះ ក៏ដករហូត ។ គាត់ត្រូវដើររហូត មកវាយខាងព្រំប្រទល់សៀមរាប កំពង់ធំវិញ រួចបានទៅដងរែក ។

នៅឆ្នាំ១៩៨៨ ឈុំ ត្រូវ តាម៉ុក ចាត់តាំងឲ្យមកកាន់ខេត្តកំពង់ឆ្នាំង និងកំពង់ស្ពឺវិញ ព្រោះពេលហ្នឹងមានមេកងពលឈ្មោះ ស៊ឺន មានស្រុកកំណើតនៅកំពង់ឆ្នាំង ក៏តា ម៉ុក ឲ្យមកកាន់នៅកំពង់ឆ្នាំង និងកំពង់ស្ពឺ ហើយមេកងពលនោះដឹងថា ឈុំ នៅរស់ក៏ស្នើគាត់មកជាមួយ ព្រោះគាត់ជាអ្នកស្រុកនៅទីនោះស្រាប់ ជាពិសេស ឈុំ ស្គាល់ភូមិសាស្ត្រខាងភ្នំឱរ៉ាល់ច្បាស់លាស់ផង ។ មកដល់ខាងកំពង់ស្ពឺ កំពង់ឆ្នាំងនេះ ឈុំ មិនមាននាទីអ្វីទេ គឺនៅអែបជាមួយ តាស៊ឺន ហើយមើលសភាពការណ៍យួនល្បាត ។ ឈុំ ក៏ធ្លាប់នៅជាមួយ តាសានមួយរយៈដែរ នៅភ្នំស្រួច បន្ទាប់ពីគាត់មកដល់ឱរ៉ាល់ ។ ឈុំ បញ្ជាក់ថា តា សាន ជាអ្នកគ្រប់គ្រងធំជាងគេ នៅតំបន់ភ្នំស្រួចនេះ ។ ចំណែកខាងអមលាំង គឺមាន កែវ ពង្ស ជាអ្នកគ្រប់គ្រង ។ ឈុំ បានរំឭកថា ពេលដែលចល័តជាមួយ តាសាន នៅឱរ៉ាល់ជាប់ គឺមិនមានកន្លែងច្បាស់លាស់នោះទេ ។ សម្រាកទីនេះមួយយប់ ទីនោះមួយយប់ គឺកងទ័ពនៅជាប់ជាមួយប្រជាជន ឃោសនាអប់រំប្រជាជន ។ នៅឆ្នាំ១៩៩៣ ឈុំ បានចាកចេញពីឱរ៉ាល់ ភ្នំស្រួច ត្រឡប់ទៅសំឡូតវិញ ដើម្បីជួបប្រពន្ធក្រោយពីប្រពន្ធរបស់គាត់ធ្លាក់ពីលើផ្ទះ ហើយតា ម៉ុក បញ្ជូនទៅជំរំខាវអ៊ីដាង ដើម្បីព្យាបាល ។ តាំងពីពេលនោះមក គាត់មិនត្រឡប់ចូលសមរភូមិប្រយុទ្ធទៀតទេ ។ នៅឆ្នាំ២០០០ គាត់ និងគ្រួសារបានត្រឡប់មករស់នៅភូមិចម្ការជ្រៃ ក្នុងស្រុកវាលវែង ។ ក្រោយមក ឈុំ ត្រូវបានចាត់តាំងជាមេភូមិចម្ការជ្រៃ ដែលគ្រប់គ្រងប្រជាជនប្រហែល៣០-៤០គ្រួសារ និងនៅឆ្នាំ២០០២ គាត់បានផ្លាស់មកធ្វើជាក្រុមប្រឹក្សាឃុំវិញ ។

ឈុំ បានរៀបការជាមួយប្រពន្ធក្រោយឈ្មោះ ដួន ថេន នៅឆ្នាំ១៩៨១ នៅតំបន់១០០៣ ភ្នំដងរែក ដែលកាលនោះស្ថិតក្រោមការគ្រប់គ្រងរបស់តា ម៉ុក ។ សព្វថ្ងៃ ឈុំ មានកូន៨នាក់ រស់នៅឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

**ផាង សារៈមុនិន្ទ**

# ដំណឹងស្វែងរកឪពុក

ខ្ញុំបាទឈ្មោះ ព្រា ភារុន កើតឆ្នាំ១៩៦០ មានស្រុកកំណើតនៅភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ សព្វថ្ងៃរស់នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ខ្ញុំបាទមានបងប្អូន៥នាក់ (ស្រី២នាក់ ប្រុស៣នាក់) និងមានម្តាយឈ្មោះ នួន គីមហៀង សូមប្រកាសរកឪពុក ឈ្មោះ ព្រា ហង្សរី កើតឆ្នាំជូត ។ មុនរបបខ្មែរក្រហម ឪពុកខ្ញុំធ្វើជាពិធីការសាលាក្រុងសៀមរាប ផ្នែករៀបចំបុណ្យជាតិ ។ ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ខេត្តសៀមរាប ក៏ដូចជាភូមិស្រុកដែលគ្រួសារខ្ញុំរស់នៅ គឺភូមិទ្រាំង ។ ខ្មែរក្រហមបានស៊ើបដឹងថា ឪពុកខ្ញុំជាអតីតអ្នករដ្ឋការ ធ្វើការនៅសាលាខេត្ត ។ នៅយប់មួយចន្លោះពីថ្ងៃ១៧ ដល់ ១៩ មេសា ឆ្នាំ១៩៧៥ ខ្ញុំចាំមិនច្បាស់ ខ្មែរក្រហមបានមកហៅឪពុកខ្ញុំពីផ្ទះទាំងយប់ ដោយមិនប្រាប់ថាទៅណាទេ ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង និងស្គាល់ពីឪពុកខ្ញុំឈ្មោះ ព្រា ហង្សរី នេះ សូមទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទខ្ញុំបាទផ្ទាល់លេខៈ ០១៦ ៥១៨ ៧៨៧

***សូមអរគុណ!***

# សាងអ្វី នឹងទទួលផលនោះ

អ្នកដែលរស់រានពីរបបខ្មែរក្រហម ជាពិសេសអ្នកដែលខ្មែរក្រហមចាត់ទុកថា ជាអ្នក ១៧ មេសា ប្រាកដជាពុំអាចភ្លេចនូវការជម្លៀសថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បានទេ ។ អ្នកទាំងនោះបានប្រឈមនឹងទុក្ខវេទនាជាច្រើនក្នុងអំឡុងពេលជម្លៀសដោយបង្ខំនេះ ជាក់ស្តែងលោកយាយ ឡឹក សុខ ។

ឡឹក សុខ បានចាប់កំណើតក្នុងគ្រួសារកសិករមួយ ។ នាឆ្នាំ ១៩៦២ គាត់បានផ្លាស់ពីស្រុកកំណើតដែលស្ថិតក្នុងភូមិព្រៃតាកុយ ឃុំដំណាក់ចង្អើរ ស្រុកពងទឹក ខេត្តកែប មកនៅភ្នំពេញ ។ នៅពេលនោះ គ្រួសាររបស់គាត់រស់នៅក្បែរផ្សារធំថ្មី ។ សុខ បានរៀបការ នៅឆ្នាំ១៩៧៣ ក្នុងវ័យ២៣ឆ្នាំ ។ គាត់បានខិតខំប្រកបរបរទ្រទ្រង់ ជីវភាពគ្រួសារ ដោយគាត់លក់នំ ឯប្តីរបស់គាត់ប្រកបការងារផ្សេងទៀត តាមដែលអាចរកបាន ។ ការខិតខំរបស់គាត់ទាំងពីរ បានធ្វើឲ្យគ្រួសារគាត់រស់នៅក្នុងជីវភាពប្រសើរជាងមុន ថែមទាំងអាចបញ្ជូនកូនប្រុសច្បងឲ្យទៅរៀនរហូតដល់ថ្នាក់ទី១០ ។ មិនយូរប៉ុន្មាន សង្គ្រាមបានផ្ទុះឡើង ។ ថ្ងៃមួយ ស្រាប់តែមានគ្រាប់បែកធ្លាក់នៅក្បែរផ្ទះរបស់គាត់ ដែលស្ទើរតែបញ្ចប់ជីវិតគ្រួសាររបស់គាត់ទៅហើយ ។ ចាប់តាំងពីពេលនោះ គ្រួសាររបស់គាត់ត្រូវរស់នៅក្នុងភាពភ័យខ្លាច ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ វេលាម៉ោងប្រមាណជា៧ព្រឹក រថយន្តយោធារបស់ខ្មែរក្រហមបានចូលមកដល់ភ្នំពេញ ។ ខ្មែរក្រហមបានប្រកាសថា ដើម្បីសម្រេចបាននូវសន្តិភាព ប្រជាជនទាំងអស់ត្រូវចាកចេញពីភ្នំពេញ ហើយអ្នកទាំងអស់នឹងត្រូវបានឲ្យវិលត្រឡប់មកវិញ ក្នុងពេលពីរ ឬបីថ្ងៃក្រោយមក ។ ឮដូច្នោះ សុខ បានរៀបចំនូវរបស់របរដើម្បីចាកចេញ ។ គាត់យកតែរបស់ដែលចាំបាច់មួយចំនួនប៉ុណ្ណោះ ។ គោលដៅដំបូងនៃការជម្លៀស គឺគ្រួសារគាត់ធ្វើដំណើរទៅស្នាក់នៅពោធិ៍ចិនតុង ។ ផ្ទុយទៅវិញ គាត់បែរជាត្រូវយោធាខ្មែរក្រហម ជម្លៀសទៅកាន់តែឆ្ងាយ ។ ដោយជឿលើការឃោសនា ហើយយករបស់របរមកជាមួយបន្តិចបន្តួច គ្រួសារគាត់ត្រូវប្រឈមនឹងការខ្វះអាហារសម្រាប់បរិភោគ ហើយគាត់ត្រូវដេកនៅកន្លែងទាំងឡាយណា ដែលគ្រួសារគាត់ទៅដល់ ។

បន្ទាប់ពីដំណើរដ៏លំបាកនេះ នៅទីបំផុត គាត់បានមកដល់ឃុំពងទឹក ។ ដោយសារគាត់ជាប្រជាជន ១៧មេសា គាត់ត្រូវខ្មែរក្រហមធ្វើបាបជាខ្លាំង ។ គ្រួសារគាត់ពុំមានកន្ទេលសម្រាប់ដេកទេ ហើយគាត់ត្រូវអង្គការបង្អត់អាហារថែមទៀតផង ។ ក្រោយមកអង្គការបានសាងសង់ខ្ទមតូចមួយ សម្រាប់ឲ្យគាត់ស្នាក់នៅ ។ គាត់ឈឺចិត្តចំពោះខ្លួនឯង និងសមាជិកគ្រួសាររបស់គាត់ជាខ្លាំង ។ បន្ទាប់ពីការមកដល់របស់គាត់បានប្រហែលជា៧ខែ ប្តីរបស់គាត់បានធ្លាក់ខ្លួនឈឺហើយបានបាត់បង់ជីវិត ដោយសារការអត់ឃ្លាន ។ គាត់បានរស់នៅក្នុងទុក្ខសោកដោយសារតែបាត់បង់ប្តី ។

នៅឆ្នាំ១៩៧៦ គាត់ត្រូវបានអង្គការបញ្ជូនឲ្យទៅលើកដីនិងជីកប្រឡាយ នៅវាលវង់ ដែលជាទីតាំងសម្លាប់មនុស្ស និងនៅឯព្រែកតាណែន ។ ស្ថានភាពការងារមានភាពយ៉ាប់យ៉ឺនជាខ្លាំង ។ ដោយពុំមានជម្រើស គាត់ត្រូវស៊ូទ្រាំរហូតដល់របបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩ ។ ក្នុងរបបនេះ គាត់បានបាត់បង់កូនចំនួន ៥នាក់ និងប្តី ។ បច្ចុប្បន្ន គាត់ពឹងផ្អែកលើការងារស្រែចម្ការដើម្បីចិញ្ចឹមជីវិត ។

ទាក់ទងនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម គាត់គាំទ្រជាខ្លាំងចំពោះ ការសម្រេចដាក់ទោសមួយជីវិតដល់មេដឹកនាំ នួន ជា និង ខៀវ សំផន ដែលស្ថិតនៅពីក្រោយការជម្លៀសដ៏ព្រៃផ្សៃនេះ ។ គាត់បានលើកឡើងថា «ដៃរបស់អ្នកទាំងនេះ ប្រឡាក់សុទ្ធតែឈាម ការដាក់ទោសមួយជីវិតយ៉ាងហោចណាស់ក៏អាចនាំមកនូវភាពអាម៉ាស់ និងឈ្មោះអាក្រក់ក្នុងប្រវត្តិសាស្ត្រកម្ពុជារបស់អ្នកទាំងពីរនេះដែរ» ។ គ្រួសាររបស់គាត់ និងប្រជាជនជាង ២លាននាក់ដែលជួបប្រទះរឿងរ៉ាវនេះ មានក្តីរីករាយ ហើយគិតថាសាលក្រមនេះបានឆ្លើយតបនូវការចង់បានរបស់យើង ។

**ស៊ុក្រ្គ ភាណា**

# អ្នករួចរស់ជីវិតពីរបបខ្មែរក្រហម

## រឿងពិតរបស់ខ្ញុំ


អ៊ុច ស៊ុនឡាយ រៀបរាប់ពីប្រវត្តិនៅពេលខ្មែរក្រហមគ្រប់គ្រង

**(តពីលេខមុន)**

### ៦) អំពីគណៈបម្រើប្រជាជន

ស្តាប់អត្ថន័យដំបូងៗអំពីគណៈបម្រើប្រជាជននេះ គឺត្រឹមត្រូវ យុត្តិធម៌ និងមានការចូលចិត្ត ព្រមទាំងពេញចិត្ត ដោយការជឿជាក់ក្រៃលែង ។ ការគោរពផលប្រយោជន៍ប្រជាជន ព្រោះមិនមានធ្វើអ្វីឲ្យប៉ះពាល់ដល់ប្រជាជនសោះឡើយ សូម្បីម្ទេសមួយផ្លែ អង្ករមួយកំប៉ុងក្តី ។ បើមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិប្រជាជន ត្រូវទទួលការស្តីបន្ទោសទិតៀន និងត្រូវសងដល់ដៃប្រជាជនវិញ ។

គណៈបម្រើប្រជាជននេះ ទោះនៅថ្នាក់ខេត្តក្តី ថ្នាក់ស្រុកក្តី និងថ្នាក់ភូមិឃុំក្តី ត្រូវបានជ្រើសរើសពីក្នុងប្រជាជនគ្រប់ស្រទាប់នៅភូមិឃុំ ជាអ្នកចេះដឹងផ្លូវលោក ផ្លូវធម៌ មានសីលធម៌ សុជីវធម៌ល្អ មានកេរ្តិ៍ឈ្មោះ និងកិត្តិយសល្អប្រសើរ ពិសេស ជាអ្នកមានប្រជាប្រិយភាពក្នុងប្រជាជន ។

គណៈបម្រើប្រជាជន ជាមនុស្សដែលមានការលះបង់ខ្ពស់ លះបង់ផ្តល់ផ្ទះសម្បែងសម្រាប់ជាមន្ទីរធ្វើការងារ ធ្វើការិយាល័យ ធ្វើការបម្រើប្រជាជន លះបង់កូនប្រុសកូនស្រីឲ្យចូលបម្រើក្រុមយុវជន យុវនារីរណសិរ្ស លះបង់កូនប្រុសស្រីឲ្យចូលបម្រើក្នុងជួរកងទ័ពរំដោះជាតិ និងប្រជាជនកម្ពុជា ទៅសមរភូមិមុខវាយខ្មាំង ។ ក្នុងចំណោម គណៈបម្រើប្រជាជននេះ លោក សូ ដួន ហៅ កែវ ដួន ជាព្រឹទ្ធាចារ្យមួយរូប ដែលមានសុភវិនិច្ឆ័យល្អ ជួយដោះស្រាយបញ្ហានៅក្នុងភូមិ ឃុំបានល្អ សម្របសម្រួល និងរកយុត្តិធម៌ ជូនប្រជាជន ព្រោះមនុស្សម្នាក់ៗ គ្រួសារនីមួយៗសុទ្ធតែនៅជាប់កម្មសិទ្ធិជាឯកជនទាំងដីធ្លីផ្ទះសម្បែង គោក្របី រទេះសាឡី កង់ ម៉ូតូ ជាដើម មិនទាន់បញ្ចូលទៅជាកម្មសិទ្ធិសមូហភាពទេ ។

គណៈបម្រើប្រជាជនមានទំនាក់ទំនងគ្នាជាមួយភូមិឃុំនានា ដោយស្មើភាពគ្នា និងមានសិទ្ធិ សេរីភាព រាយការណ៍ជូនថ្នាក់លើ ហើយអាចអញ្ជើញថ្នាក់លើ ឬថ្នាក់ភូមិ ឃុំស្មើគ្នា ផ្លាស់ប្តូរទស្សនកិច្ច ផ្លាស់ប្តូរកសិផលដូចជា ផលិតផលថ្នាំជក់ ដូរផ្លាស់ជាមួយពោត សណ្តែក គោ ជ្រូក មាន់ ទា ជាដើម ។

ចំពោះ គណៈបម្រើប្រជាជននេះ ក្រោយមកបានរៀបចំបោះឆ្នោតទៅជាគណៈកម្មាធិការប្រជាជនឃុំក្រគរ ហើយជាប់ឆ្នោតឈ្មោះ ក្រង ទូច ហៅ តាំង ឈន ជាប្រធានឃុំវិញ បើប្រៀបធៀប ប្រធានគណៈកម្មាធិការឃុំ គឺជាមេឃុំ ឬចៅសង្កាត់ដូចកាលជំនាន់ សីហនុ អ៊ីចឹង ។

គណៈបម្រើប្រជាជននេះ មានក្រុមកងឈ្លបមួយក្រុម ឬកងស្វ័យការពារ មានអាវុធខ្លះ ដូចជា ការ៉ាប៊ីន ឬគ្រាប់ស៊ីស សម្រាប់ការពារភូមិឃុំ របស់ខ្លួនរៀងៗខ្លួន គ្រប់ឃុំទាំងអស់ ដោយដាក់វេនគ្នាយាមយប់ យាមថ្ងៃ ពុំដែលលស់ឡើយ ។

### ៧) សមាគមបញ្ចូវន្តឃុំ

នៅតាមភូមិ ឃុំនីមួយៗ មានក្រុមសមាគមច្រើនផ្អែកតាមវិន័យ តាមធនធាន និងមានពួកក្រុមតូចៗ ដើម្បីបង្កើនផលិតផល បង្កើនធនធាន ពង្រីកការយល់ដឹង ទាំងផ្នែកសេដ្ឋកិច្ច យោធា និងសង្គមកិច្ច ។ ដោយគណៈបម្រើប្រជាជនបដិវត្តន៍ឃុំមានសមាសភាពៈ

១) ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ឃុំ ជាអ្នកទទួលខុសត្រូវរួមក្នុងឃុំសង្កាត់

២) អនុប្រធានគណៈកម្មាធិការទទួលខុសត្រូវផ្នែកសេដ្ឋកិច្ច

៣) សមាជិកគណៈកម្មាធិការទទួលបន្ទុកប្រធានយោធាគ្រប់គ្រងកងឈ្លបភូមិ ឃុំ

៤) សមាជិកទទួលបន្ទុកផ្នែកសង្គមកិច្ច ពិនិត្យស្ពាន ផ្លូវឆ្លងកាត់ភូមិ និងដោះស្រាយការងារ សង្គមកិច្ច ផ្នែកជំងឺតម្កាត់ ទាក់ទងពេទ្យ

៥) សមាជិកទទួលបន្ទុកសិក្សាធិការ អប់រំដោយលោកគ្រូនាយកសាលារៀននៅភូមិឃុំផ្ទាល់

៦) សមាជិកទទួលការងារយុវជន

៧) សមាជិកមួយរូបជាស្ត្រីទទួលការងារនារី

ចំពោះសមាគមបញ្ញវន្តនេះ ត្រូវមានការបង់ប្រាក់សមាជិកប្រចាំខែក្នុងតម្លៃ៥០០៛ រៀលរាល់ខែ ដើម្បីជួយទ្រទ្រង់អគ្គការណេសិរ្សផង និងសម្រាប់ក្រដាសឯកសារ ប៊ិចរបស់សមាគមពុំមានដាច់សោះឡើយ ។

នៅក្នុងអំឡុងឆ្នាំ១៩៧២ មានបើកមហាសន្និបាតមួយឈ្មោះថា មហាសន្និបាតបញ្ញវន្តរណសិរ្សរួបរួមជាតិកម្ពុជា ដោយមានថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណៈមជ្ឈិមបក្សប្រជាជនបដិវត្តន៍កម្ពុជាមាន មនុស្ស៧នាក់អង្គុយលើវេទិកា ដោយមានដាក់ពាក្យស្លោកៈ

«ជយោ! រណសិរ្សរួបរួមជាតិកម្ពុជាដ៏រុងរឿង!»

«ជយោ! កងកម្លាំងប្រដាប់អាវុធប្រជាជនកម្ពុជា!»

«ជយោ! មិត្តភាព សាមគ្គីភាពស្អិតរមួតកម្ពុជា វៀតណាមឡាវ!»

«ប្តេជ្ញា! ជំរុញចលនាបង្កបង្កើនផលឲ្យខ្លាំងក្លា»

«អបអរសាទរ! មហាសន្និបាតបញ្ញវន្តស្នេហាជាតិកម្ពុជា!»

«ប្តេជ្ញា! វាយសម្រុកកម្ទេចពួកចក្រពត្តិ និងបរិវារ លន់ នល់ សិរិមតៈ»

ក្នុងចំណោមគណៈអធិបតី ខ្ញុំបានសម្លឹងមើលអ្នកដឹកនាំជាន់ខ្ពស់ គឺមានលោក ទីវ អុល ជា សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៅវិទ្យាល័យព្រះអង្គឌួង ខេត្តព្រៃវែង ដែលគ្រប់គ្នាតែងហៅថា មិត្តឯម ។ សមមិត្ត យី ឈ្មោះដើម ប៊ុនណាន ជាប្រធានគណៈតំបន់ ៥០៥ ។ កាលរៀននៅវិទ្យាល័យ ព្រះមហាក្សត្រិយានីកុសុមៈ ខេត្តក្រចេះ ក្រោយពេលប្រឡងឌីប្លូមជាប់ហើយ រៀននៅថ្នាក់ទី២ «ក» ជំនាន់ជាមួយគ្នា ព្រោះក្រោយជាប់ឌីប្លូមហើយ ខ្ញុំរៀនថ្នាក់ទី២«ខ» ហើយស្គាល់គ្នា ព្រោះកាលនៅរៀន គាត់រៀនពូកែ ជាប់លេខ១ រៀងរាល់ខែ និងជាប្រធានថ្នាក់ទី២«ក» តែក្រោយមកក្រោយខែឧសភា ឆ្នាំ១៩៧០ គាត់រត់ចូលព្រៃម៉ាកគីបាត់ ទើបឃើញមុខនាពេលសន្និបាតបញ្ញវន្តនេះ ។ គាត់បានចាប់ដៃសួរសុខទុក្ខខ្ញុំដោយរាក់ទាក់ជិតស្និទ្ធជាមិត្តភក្តិរៀនសូត្ររួមជំនាន់និងនិយាយថា «មិត្តត្រូវដឹងថា ព្រះអាទិត្យក្រហមឆ្អៅបាននឹងកំពុងរះនៅទិសបូព៌ាហើយ ទោះបីមាន់គករងាវ ឬមិនរងាវក៏ដោយ ក៏ព្រះអាទិត្យរះនៅទិសបូព៌ាជានិច្ច» ។ រួចហើយគាត់ឡើងលើវេទិកាជាមួយកម្មាភិបាលថ្នាក់ដឹកនាំបក្សជាច្រើននាក់ទៀត ។ ព្រមជាមួយគ្នាក៏បានឃើញលោកសាស្ត្រាចារ្យ ស៊ឹម សុន ធ្លាប់បង្រៀនគណិតសាស្ត្រថ្នាក់ទី១ទំនើប ប៉ុន្តែគាត់ប្តូរឈ្មោះថា មិត្ត យ៉ែម និងឃើញលោកគ្រូ អ្នកគ្រូជាច្រើននាក់ទៀតក្នុងសមាគមបញ្ញវន្តអ្នកស្នេហាជាតិមានៈ

១) លោកគ្រូ ថាច់ តូណែត បង្រៀនបារាំង

២) លោកគ្រូ ជុន យោង បង្រៀនគីមី

៣) លោកគ្រូ ងឹម ហ៊ាង បង្រៀនអង់គ្លេស

៤) លោកគ្រូ គិត គិមសៅរ៍ បង្រៀនគណិត

៥) អ្នកគ្រូ ឈិត សារឹម ហៅ មិត្ត រឹម

៦) លោកគ្រូ សុខ មិហ៍ ហៅ មិត្ត ម៉ែន

៧) លោកគ្រូ ញ៉ែម ពុន ត្រូវជាស្វាមីអ្នកគ្រូ ឈិត សារឹម

៧) អ្នកគ្រូ រឿន គណៈមូលដ្ឋាន

៨) លោកគ្រូ ហុន សាមឿន គណៈមូលដ្ឋាន

និងគ្រូជាច្រើនរូបទៀត ។ ដោយខ្ញុំមិនបាននៅក្នុងជួរបដិវត្តន៍នឹងគេម្ល៉ោះហើយមិត្តភក្តិខ្ញុំ ហៅខ្ញុំថា ជាអ្នកសម្បុំសុខ ជាមនុស្សគេចវេះក្នុងសង្គម មិនឃើញការឈ្លានពានពីចក្រពត្តិ និងបរិវារ ជាមនុស្សចម្រើនដែរ តែគិតគូរគ្រួសារ ប្រពន្ធកូនខ្លាំង ហៅថា គ្រួសារនិយមអាត្មានិយមនៅមាន សិស្ស និស្សិត ទាំងធ្លាប់នៅក្នុងខេត្ត និងសាស្ត្រាចារ្យ ព្រមទាំងពួកវេជ្ជបណ្ឌិត ភ្នាក់ងារសុខាភិបាលទាំងជំនាន់ចាស់ សម័យសង្គមរាស្ត្រនិយមជាច្រើននាក់ទៀត បានចូល

រួមសន្និបាតនេះ ។

មហាសន្និបាតបញ្ញវន្តនេះ ប្រារព្ធធ្វើនៅភូមិថ្មក្រែ ឃុំថ្មក្រែ ជិតជើងភ្នំសំបុក មានសមាជិក ចូលរួម៣៥០នាក់ រយៈពេល៣ថ្ងៃ ដោយសម្រាកនៅតាមផ្ទះប្រជាជនឃុំថ្មក្រែនោះ ព្រមទាំងដោះស្រាយបាយទឹក ព្រឹក-ល្ងាច នៅទីនោះផ្ទាល់ ។

ខ្លឹមសារសំខាន់គឺចលនាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ការចាត់តាំងក្រុមសាមគ្គីបង្កបង្កើនផល ក្រុមប្រវាស់ដៃជាមួយគ្នាបង្កបង្កើនផល ទិសដៅសាមគ្គីកម្ពុជា វៀតណាម ឡាវ និងពង្រឹងជីហរដាច់ខាតវាយខ្មាំង ជាបរិវារចក្រពត្តិអាមេរិក និងឈានទៅរំដោះភ្នំពេញ រំដោះក្រុងព្រៃនគរ រំដោះក្រុងវៀងច័ន្ទ ប្រទេសឡាវនាពេលខាងមុខ ។

ការប្តេជ្ញាចិត្ត បានពុះពោរយ៉ាងដាច់ខាត និងខ្លាំងក្លាបំផុត ។ នៅក្នុងរយៈពេលមហាសន្និបាតនេះ ជារយៈពេលនៃសង្គ្រាមអាមេរិកាតួបនីយកម្មធំនៅកម្ពុជា ។ ជារយៈពេល២០០យប់ ២០០ថ្ងៃ ដែលយន្តហោះអាមេរិកហោះចេញពីទីក្រុងព្រៃនគរ ឡើងមកបាញ់រះទម្លាក់គ្រាប់បែកនៅកម្ពុជាយើងតាមគ្រប់រូបភាព និងគ្រប់ម៉ាក ។ ជាពិសេស ពួកបេ៥២ ដែលទម្លាក់គ្រាប់ទាំងខ្សែ មានរណ្តៅធំៗ កាត់ផ្លូវឆ្លង ហើយផ្លូវដឹកជញ្ជូនដូចជា ផ្លូវលំហូជីមិញជាដើម ។

ក្រោយមហាសន្និបាតបញ្ញវន្តចប់ មានគ្រូបង្រៀន សិស្ស និស្សិតជាច្រើន បានចុះឈ្មោះ និងលះបង់ប្រពន្ធកូន ម៉ែឪ ទៅចូលរួមបដិវត្តន៍ បម្រើជាតិ ប្រជាជន ពង្រឹងជីហរស្នេហាជាតិ ស្នេហមាតុភូមិ ។ នៅសល់រូបខ្ញុំផ្ទាល់ មិនអាចទៅចូលរួមបដិវត្តន៍ សុខចិត្តនៅធ្វើស្រែជាមួយក្រុមគ្រួសារផង និងរត់រ៉ឺម៉កម៉ូតូរកប្រាក់ចិញ្ចឹមគ្រួសារផង ។ ប៉ុន្តែ ករណីចាំបាច់បំផុតក្នុងគ្រួសារ គឺការដែលភរិយាខ្ញុំទើបសម្រាលកូនប្រុសទី២ ដែលទើបកើតបាន៧-៨ថ្ងៃនេះ មិនអាចឲ្យខ្ញុំលះបង់ចូលរួមជាមួយបដិវត្តន៍បានឡើយ ។

ដោយសភាពយន្តហោះ ធ្វើសកម្មភាពខ្លាំងទាំងពេលយប់-ថ្ងៃ ជួនកាលពេលព្រលឹមអុរម៉ោង៥ព្រឹកក៏មាន យន្តហោះ ហោះកាត់ចុះឡើង ធ្វើឲ្យប្រជាជន មិនអាចនឹងនរចិត្ត នៅលើផ្ទះសម្បែងតាមភូមិបានទៀតឡើយ ។

បងប្អូនបាននាំគ្នាដឹកកូនជញ្ជូនចៅចេញពីផ្ទះ ទៅនៅតាមដីចម្ការ ដីស្រែ ដីកលេណដ្ឋាននៅទីនោះ ដើម្បីរស់ និងធ្វើស្រែចម្ការឆ្ងៀតជាំផ្ទុះផង ។

លោកតា តាំង ឆាយ និងកូនចៅ ក៏បាននាំគ្នាចេញទៅនៅស្រែវាលផ្សិត ហើយធ្វើការកាប់គាស់រើរានដីថ្មីដាំដំឡូង ត្រាវ និងដំណាំផ្សេងៗសម្រាប់ដោះស្រាយជីវភាពផ្ទាល់ខ្លួន ដោយឡែកៗពីគ្នា នៅទីជនបទ ។

ខ្ញុំនៅចាំបានខ្លះនូវពាក្យពេចន៍ដែលលោកឪពុកខ្ញុំបាននិយាយជារឿយៗចូលក្នុងទំនាយកូនហើយ ខ្ញុំសួរគាត់ថា ទំនាយនោះថាយ៉ាងម៉េចខ្លះប៉ា? ទំនាយនោះមានឃ្លាប្រយោគច្រើនណាស់ លុះត្រាតែកត់ត្រា មើលអាន សូត្រទន្ទេញ ទើបចាំបាន បើអ៊ីចឹងឲ្យប៉ានិយាយមើលថាម៉េច? ពេលនោះ គាត់និយាយថាៈ

ពពេចក្រាបពងក្រោមគគ្គា ក្អែកពាំផ្លែល្វារាយគ្រប់ស្រុក អ្នកផងឃើញហើយរើសយកទុក ចំណេរទៅមុខទើបដឹងខ្លួន ។

ដឹងខ្លួនពេលនោះ គឺមនុស្សទាំងអស់ស្លៀកពាក់ខ្មៅ ខោខ្មៅ អាវខ្មៅទាំងអស់នៅគ្រប់ភូមិ ឃុំ ស្រុកទាំងអស់ ប្រៀបដូចសត្វក្អែកដែលរាយគ្រប់ស្រុកយ៉ាងដូច្នោះដែរ ។

## ៨) ចលនាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ

ចលនាបដិវត្តន៍ប្រជាជាតិបាន និងកំពុងបក់បោកបញ្ចេញឥទ្ធិពលខ្លាំងក្លាធំធេងនៅក្នុងតំបន់រំដោះទាំងអស់ ។ បើតាមន័យរបស់បដិវត្តន៍ គឺជាការប្រែប្រួល ឬការផ្លាស់ប្តូរ ។ ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវរបបគ្រប់គ្រងចាស់ ដែលមិនចម្រើនឲ្យបានចម្រើនលូតលាស់ ទាន់សម័យកាល គឺជាការប្រព្រឹត្តប្រឆាំងដោយកម្លាំងប្រដាប់អាវុធ ចំពោះអំពើរំលោភ អំពើជិះជាន់ ទោះបីត្រូវលះបង់អាយុជីវិតក៏ដោយ ។

ចលនាប្រជាធិបតេយ្យ គឺជាចលនាក្នុងប្រទេសដែលមានប្រជារាស្ត្រជាអធិបតី គឺប្រទេសឬរដ្ឋបាលដែលមានប្រជាជនជាធំ ក្នុងការរើសតំណាងរបស់ខ្លួនឲ្យជាអ្នកសម្រេចកិច្ចការក្នុងប្រទេស ។ ពាក្យ ប្រជារាស្ត្រ ឬប្រជានិករ ឬប្រជាពលរដ្ឋបាន និងកំពុងផុលផុសយ៉ាងខ្លាំងក្លាណាស់ តាមរយៈឯកសារ ចុះអប់រំផ្សព្វផ្សាយទាំងយប់-ថ្ងៃ ទោះពេលអគ្រាត្រក៏ឃើញមានក្រុមយុវជន យុវនារី ពាក់បាឡូនៅខ្នងរាប់រយនាក់ ដើរកាត់ជាជួរកាត់ភូមិ ឃុំទៅកាន់ទីតាំងគោលដៅ ថ្នាក់ឃុំ សង្កាត់ ឬទៅថ្នាក់តំបន់ពុំមានអ្នកត្អូញត្អែរ រអ៊ូរទាំ តវ៉ាអ្វីសោះឡើយ ។ ការងារនេះ

ចលនានេះ ហាក់ដូចជា មានការបង្ខិតបង្ខំបន្តិចដែរ ប៉ុន្តែ មិនចេញជារូបភាព ឬប្រកែកប្រណាំងថា មិនព្រម មិនទៅ មិនតាម ឬយ៉ាងណាសោះឡើយ ។

ហេតុដូចម្តេច ក៏មនុស្សពេលនោះ នាំគ្នាទៅតាមបែបនេះអ៊ីចឹង? ឬមួយជាទំនាយស្រុកទេស នាំឲ្យមនុស្សយល់ឃើញអ៊ីចឹង នាំគ្នាធ្វើអ៊ីចឹង ទោះបីក្នុងផ្ទះមានកម្លាំងពលកម្មធ្វើស្រែចម្ការ មានកូន៣នាក់ ឬ៤នាក់ ក៏អ្នកទាំង៣ ឬទាំង៤នាក់ នាំគ្នាទៅចូលជួរបដិវត្តន៍អស់មួយផ្ទះ នៅសល់តែឪពុកម្តាយ ចាស់ៗនៅចាំផ្ទះតែប៉ុណ្ណោះ ។

សភាពការណ៍នៅតាមភូមិ ឃុំ កាន់តែមានការផ្លាស់ប្តូរពីមួយថ្ងៃទៅមួយថ្ងៃ ។ សភាពការណ៍ ទម្លាក់គ្រាប់បែកយន្តហោះបាញ់រះតាមដងផ្លូវកាន់តែមានសកម្មភាពខ្លាំងឡើងៗ ។ នៅតាមផ្លូវជាតិ ពីកន្ទួតទៅទីរួមខេត្តក្រចេះ មានចម្ងាយ២០គីឡូម៉ែត្រ មានរ៉ឺម៉កម៉ូតូមួយគ្រឿងបើកបរដោយឈ្មោះ ដាង អ៊ួរ ត្រូវយន្តហោះធុនទ្រុងជ្រូក និងអាកន្ទុំរុយ ដេញតាមបាញ់តាមដងផ្លូវជាប់រហូតតាំងពីពេលចេញរហូតដល់វាលវង់ គឺវាលយន្តហោះ ហើយបាញ់ត្រូវស៊ុះសាច់ទាំងមនុស្ស ទាំងជ្រូក នៅលើរ៉ឺម៉ក ស្លាប់ខ្លួនតែហោង ពុំមានអ្នកណាហ៊ានទៅមើល ឬយកសាកសពទៅធ្វើបុណ្យទានទេ រហូតដល់ព្រលប់យប់ នៅពេលស្ងាត់បាត់យន្តហោះ ទើបយកសព ដាង អ៊ួរ បាន ។

យន្តហោះអាមេរិក បានបាញ់រះ និងទម្លាក់គ្រាប់បែកទាំងយប់ ទាំងថ្ងៃ អស់រយៈពេល២០០យប់ ២០០ថ្ងៃ ទើបលេចព្រឹត្តិការណ៍ចរចារវាងចក្រពត្តិអាមេរិក និងវៀតណាម ដែលមានឈ្មោះ លោកស្រី ង្វៀងធីប៊ិញ ជាអ្នកដឹកនាំប្រតិភូវៀតណាម នៅទីក្រុងប៉ារីស ប្រទេសបារាំង ។ នៅថ្ងៃមួយ ក្នុងចុងឆ្នាំ១៩៧៣ មានការបាញ់គ្រាប់ណាប៉ាល់ និងបាញ់ឆេះភូមិអណ្តែងដូន ដែលកាលពីពេលមុនធ្លាប់មានជនជនវៀតណាមរស់នៅច្រើន តាំងពីស្ពានអណ្តែងដូន មាត់ព្រែកទាំងសងខាង រហូតដល់ផ្ទះទឹក ដែអណ្តែតទឹក នៅទន្លេមេគង្គទៀតផង ។ ការឆេះផ្ទះរាប់រយនៅភូមិអណ្តែងដូននេះ ពុំមានអ្នកណាទៅលត់ភ្លើង ឬជញ្ជូនទ្រព្យសម្បត្តិចេញបានឡើយ បានត្រឹមតែរត់ចេញភៀសខ្លួន យកតែព្រះអាយុរៀងៗខ្លួនទៅកាន់ទីឆ្ងាយ ។ ព្រឹកឡើង យន្តហោះធុនមិច ធុនហ្វង់តូម មកហោះពិនិត្យ មើលសភាពការណ៍នេះ ដើម្បីថតរាយការណ៍ទៅថ្នាក់លើថា បានកម្ទេចជីវិតយៀកកុងស្លាប់អស់ ។ រំលងប៉ុន្មានថ្ងៃក្រោយ យន្តហោះបានមកបាញ់រះ និងទម្លាក់គ្រាប់នៅកំពង់ផែក្រចេះក្រុង ដោយពុំមាននរណាម្នាក់រងគ្រោះថ្នាក់ ឬរបួសស្លាប់សោះឡើយ ។ ប៉ុន្តែ នាវាតូចធំ កប៉ាល់ កាណូតទាំងអស់ ត្រូវឆេះលិចលង់ក្នុងទឹកទន្លេមេគង្គទាំងអស់គ្មានសល់ ។ សូម្បីដើមគគីរធំៗ រាប់សិបដើមនៅតាមដងមាត់ទន្លេចាប់តាំងពីកំពង់ផែខាងលើរហូតដល់ផែក្រោម ក៏ត្រូវគ្រាប់បែក គ្រាប់បាញ់ គ្រាប់រ៉ុក្កែតគ្រប់បែបយ៉ាង បាញ់ទំលុះធ្លុះធ្លាយ បាក់បែក ដួលរលំប្រផេងប្រផាងតាមដងផ្លូវ ក្លាយទៅជាទីរហោស្ថានមួយរំពេច ។

ផ្សារក្រចេះ ធ្លាប់តែមានមនុស្សដើរជាស លក់ដូរទំនិញសព្វសារពើ ត្រូវប្រែក្លាយជាស្ងាត់ជ្រងំ ចាប់ពីក្រោយដែលយន្តហោះអាមេរិកចាប់ផ្តើមសកម្មភាពជាដំបូងមកម៉្លេះ ។

មនុស្សម្នា បាននាំគ្នាទៅរកស្រែភ្លឺនៅជនបទ បណ្តាពួកពាណិជ្ជករ អាជីវករតូចធំ កន្លែងលក់ដូរ ពាណិជ្ជកម្មធំៗពីមុន ត្រូវបិទទ្វារហើយដាក់ស្លាកថា "ផ្ទះខ្ញុំទៅស្រែ" ចងបិទនៅក្លោងទ្វារ ឬសរសេរជាប់នឹងជញ្ជាំងតែម្តង ។

សភាពការណ៍នេះ គឺសកម្មភាពបាញ់ទម្លាក់គ្រាប់ទៅលើទីប្រជុំជន ទីចំណតរថយន្ត កំពង់ផែ ផ្ទះធំៗនៅទីក្រុង ជាមូលហេតុបណ្តេញមនុស្សឲ្យទៅជនបទធ្វើស្រែចម្ការ បោះបង់ការរកស៊ីលក់ដូរ នៅទីប្រជុំជន ។

ការបង្កើនសកម្មភាពតាមយន្តហោះទាំងយប់ថ្ងៃនេះ បានដុតកម្តៅ និងកំហឹងចងអាឃាតជាមួយ ពួកចក្រពត្តិកាន់តែខ្លាំងឡើងៗ និងប្រែក្លាយសភាពការណ៍ដែលធ្លាប់សុខដុមរមនាក្នុងក្រុមគ្រួសារទៅជាការព្រាត់ប្រាសគ្នា ទៅជាសោកនាដកម្ម ទុក្ខវេទនាខ្លោចផ្សា ដោយការឆេះផ្ទះសម្បែង ឆេះវត្តអារាម សាលារៀន របួស ពិការ និងដុតកំហឹងប្រជាពលករទៅជាការចងអាឃាតដោយចូលធ្វើកងទ័ពប្រជាជនរំដោះ កាន់អាវុធ ចូលប្រយុទ្ធវាយផ្តួលរំលំទីតាំងរបស់រដ្ឋការលន់ នល់ និងរបបសាធារណរដ្ឋខ្មែរ ពិសេស ភ្នំពេញដែលជាសំបុកចុងក្រោយនោះ ។

ការកត់ត្រា និងកំណត់ស្ថិតិមនុស្សតាមភូមិ ឃុំ ត្រូវបានកត់ត្រាឡើងវិញ ចំពោះអ្នកដែលជាប់និន្នាការជាមន្ត្រីរាជការសង្គម

ចាស់ អ្នកមានវណ្ណភាពខ្ពស់ អនុធន ជាងកាត់សក់ អ្នកលក់ដូរតាមតូបតៀម កសិករថ្នាក់លើ មានថ្នាក់លើខ្ពស់ ថ្នាក់លើថ្នាក់កណ្តាល និងថ្នាក់លើស្រទាប់ក្រោម ។ ចំពោះ កសិករថ្នាក់ក្រោម ក៏មានការវាយតម្លៃថា ជាកសិករថ្នាក់ក្រោមស្រទាប់លើ កសិករថ្នាក់ក្រោមស្រទាប់កណ្តាល និងកសិករថ្នាក់ក្រោម ក្រោមបង្អស់ ។ បញ្ហានេះជាការលាក់ការសម្ងាត់បំផុត ដែលជាទិសដៅសម្រាប់បែងចែកប្រជាជនជា៣ប្រភេទនោះ ។

## ៩) ការបញ្ឈប់ការចាយវាយប្រាក់កាស

ចលនាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យនេះ បានចាប់ផ្តើមពីការឈប់ចាយលុយកាក់រូបគោមួយនឹមរបស់ លន់ នល់ ដោយគណៈកម្មាធិការឃុំ ផ្តើមប្រមូលពីក្នុងប្រជាជនទាំងអស់ ដើម្បីកាត់ផ្តាច់ ឲ្យអស់ពីរបប លន់ នល់ ។ តំបន់រំដោះ នឹងត្រូវមានការចាយវាយផ្សេងពីពួកប្រតិកិរិយាលន់ នល់ សិរិ មតៈ ។ នៅឆ្នាំ ១៩៧៤ មានលេចឮប្រតិបត្តិការជាច្រើនកន្លែងរបស់ឧត្តមសេនីយ៍ រដ្ឋបាលភ្នំពេញ ដូចជាៈ

១) ប្រតិបត្តិការឈ្នះទាំងស្រុង ចេញពីវៀតណាម ស្នួល

២) ប្រតិបត្តិការនាងកង្រី នៅខាងកំពង់ឆ្នាំង

៣) ប្រតិបត្តិការចេនឡា នៅខាងខេត្តកំពង់ធំ និងមានចេនឡាទី១ ចេនឡាទី២ ទៀតផង ។

ប៉ុន្តែ រាល់យុទ្ធនាការនៃការបោសសម្អាតយៀកកុងទាំងនោះ ត្រូវបរាជ័យ ពិសេសកម្លាំងឃោសនា និងគោលនយោបាយរណសិរ្សដែលមានសម្តេច ព្រះនរោត្តម សីហនុ ជាព្រះប្រធាននេះ បានក្លាយជាមន្តស្នេហ៍ ជាដែកឆក់ខ្មែរស្នេហាជាតិឲ្យឈប់បាញ់គ្នាទម្លាក់អាវុធ ព្រោះបាញ់កាប់សម្លាប់ខ្មែរ បានអន្ទងដួងចិត្តខ្មែរ ដែលជាទាហានការពាររដ្ឋបាល លន់ នល់ បោះបង់អាវុធ ចោលការងារការពាររបបភ្នំពេញ ហើយវិលមករកម៉ែឪ ស្រុកភូមិកំណើតនៅស្រុក ខេត្តជាច្រើននាក់ ។

ចំពោះ តំបន់រំដោះក្រចេះ ស្ទឹងត្រែង រតនគិរី កាន់តែបង្កើនការជិតស្និទ្ធ និងទទួលការរៀបចំក្រុមសាមគ្គីបង្កបង្កើនផល ជួយភ្ជួររាស់គ្នា ជួយដកស្ទូងប្រវាស់ដៃគ្នា ដោយមនុស្សទាំងអស់គ្រប់មជ្ឈដ្ឋាន ត្រូវទទួលការចាត់តាំងឲ្យចូលក្រុមសាមគ្គី ឬប្រវាស់ដៃ ពុំមានអ្នកណានៅក្រៅក្រុមសោះឡើយ ។

ក្រោយពេលបញ្ឈប់ការចាយវាយប្រាក់កាសនៅតំបន់រំដោះ ចលនាលើកទំនប់ប្រឡាយ ប្រព័ន្ធ ភ្លឺស្រែធំ ក៏ចាប់ផ្តើមមានសកម្មភាព មានចលនាកាប់ដី រែកដី ការហៅមនុស្សទៅអប់រំរៀនសូត្រ បំពាក់បំប៉នសតិអារម្មណ៍ ណែនាំឲ្យទៅតាមមាគ៌ានយោបាយរបស់អង្គការ ។ ពាក្យថា អង្គការស្មើនោះ គឺអង្គការសុំយក ។ ពាក្យថា "សម្រាក" គឺឈប់ ទោះបីឈប់ធ្វើការងារ ក៏ហៅថា សម្រាកពីការងារដែរ ។ ទោះបីទៅដេក ក៏ហៅ សម្រាក ហើយពាក្យ ហូប តែមួយ គឺជំនួសពាក្យ ស៊ី បរិភោគ អាស្រ័យ ទទួលទាន ពិសារ ឆាន់ សោយ ទាំងអស់ គឺទាំងអស់ប្រើពាក្យ "ហូប" តែមួយគត់ បានន័យថា ស្មើភាពគ្នាទាំងអ្នកមាន អ្នកក្រ អ្នកខ្ពស់ អ្នកទាបទាំងអស់ ។ នោះគឺបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដែលប្រជាជនទាំងអស់បានកត់ចំណាំ និងនិយាយរត់មាត់គ្រប់ក្រុម សាមគ្គីទាំងអស់តាមការណែនាំរបស់គណៈកម្មាធិការភូមិ ឃុំ ដែលគេប្តូរឈ្មោះទៅជាអង្គការបដិវត្តន៍ នៅគ្រប់ស្រទាប់ជាន់ថ្នាក់ ។

អង្គការបដិវត្តន៍គ្រប់ស្រទាប់ជាន់ថ្នាក់ ចាប់ផ្តើមធ្វើសកម្មភាពយ៉ាងមមាញឹកបំផុត ទាំងយប់ ទាំងថ្ងៃ ។ ការចុះផ្សព្វផ្សាយការឃោសនាអប់រំ ការនិយាយប្រជុំ ទោះបីផ្ទះ៥ខ្នង ក៏ហៅប្រជុំហៅផ្សព្វផ្សាយយ៉ាងសកម្មបំផុត លើចំណុចសំខាន់ៗគឺៈ

១) ការរៀបចំក្រុមសាមគ្គីបង្កបង្កើនផល

២) ការលុបចោលការចាយវាយប្រាក់កាស

៣) ការគ្មានសាលារៀនមធ្យមសិក្សា សកលវិទ្យាល័យ ឬពុទ្ធិកសិក្សា សាលាធម្មវិន័យ

៤) ការចលនាព្រះសង្ឃវ័យក្មេង សាមណេរឲ្យលាចាកសិក្ខាបទ និងឈានទៅផ្សឹកព្រះសង្ឃ នៅតាមវត្តនានា នៅទូទាំងខេត្ត ។

៥) ការបែងចែកក្រុមនៅតាមភូមិ ឲ្យទៅជាសហករណ៍ភូមិ ដាក់ឈ្មោះ ក១ , ក២ , ក៣ .....

ចាប់ពីដើមឆ្នាំ១៩៧៤ មានលេចឮព័ត៌មានថា ព្រះគ្រូ ហង្ស ប៉េង ជាព្រះគ្រូមេគណខេត្តក្រចេះ ត្រូវសន្តិសុខខេត្តចាប់ខ្លួនពីបទថាលោកជាចារកម្ម សេ.អ៊ី.អា អាមេរិក មានគេអូទាក់ទងពីលើកុដិធំទៅដល់ភ្នំពេញ ហើយនៅមានដៃជើង ខ្សែរយៈយ៉ាងច្រើនដែលអង្គការយើងកំពុងស្រាវជ្រាវបន្តទៀត ដើម្បីកម្ទេចខ្សែរយៈទាំងអស់នេះ ។

ក្រោយពេលចាប់ខ្លួនព្រះគ្រូ ហង្ស ប៉េង ប្រមាណ១០ថ្ងៃ លេចព្ញព័ត៌មានចាប់ខ្លួនលោកគ្រូ ធម្មាចារ្យ គង់ ឃិន គង់នៅអរញ្ញវាសីសួង និងរមណីយដ្ឋានភ្នំសំបុក ភូមិថ្មក្រែ ស្រុកក្រចេះ នាំយកទៅធ្វើគុតដោយចោទប្រកាន់ថា លោកគ្រូសង្ឃរាជអង្គនេះ មានគេអូទាក់ទងជាមួយពួកចក្រពត្តិអាមេរិក បញ្ជាឲ្យយន្តហោះមកបាញ់រះ និងទម្លាក់គ្រាប់បែកលើទីតាំងសំខាន់ៗរបស់កងទ័ពបដិវត្តន៍កម្ពុជា ។

ការចាប់ខ្លួន និងយកព្រះសង្ឃទៅធ្វើគុតនេះ ដូចពាក្យចាស់បុរាណធ្លាប់ពោលថា «បើចង់វាយឆ្កែ គេចោទថាឆ្កែនោះវាឆ្កួត» ។ ចាប់តាំងពីពេលនោះមក ចលនាផ្សឹកព្រះសង្ឃប្រែក្លាយវត្តអារាមទៅជាទីកន្លែង ធ្វើមីទ្ទីង យកព្រះវិហារដាក់អង្ករ អំបិល ស៊ីម៉ងត៍ ដែលជាជ័យភណ្ឌនានាវិញអស់ ហើយចាប់ផ្តើម រុះរើកុដិសាលាយកទៅធ្វើជាស្ពានផ្ទះបាយរួមនៅតាមសហករណ៍ ។

ក្នុងរយៈពេលនៃការបាញ់រះពីយន្តហោះអាមេរិក នៅគ្រប់ជនបទកម្ពុជានោះ ខ្លួនខ្ញុំផ្ទាល់ដែលបានបូរវណ្ណភាពពីគ្រូបង្រៀន ធ្លាប់បង្រៀនសិស្ស និងមានលុយកាក់ផ្គួនល្មមអាចចិញ្ចឹមគ្រួសារ បានក្លាយ ទៅជាជនក្រីក្រ ខ្វះខាតជីវភាព រកស៊ីរត់រ៉ឺម៉កម៉ូតូផង ធ្វើស្រែជាមួយឪពុកម្តាយក្មេកផង រកលុយកាក់ ស៊ើរមិនគ្រប់គ្រាន់ផ្គត់ផ្គង់ជីវភាព ។ ណាមួយដឹកជញ្ជូនតាមរ៉ឺម៉កម៉ូតូត្រូវមើលសភាពការណ៍យន្តហោះ ក្អែកស ក្អែកខ្មៅ ដោយឆ្លងកាត់តាមដងផ្លូវប្រឈមនឹងការបាញ់រះពីយន្តហោះអាមេរិកជាច្រើនដង ។

សម័យកាលមួយនោះ ក្នុងចុងឆ្នាំ១៩៧៣ ពេលដែលលុយកាក់ចាយវាយមិនទាន់ត្រូវបានបញ្ឈប់ ខ្ញុំបានដឹកអង្ករពីភូមិសណ្តាន់ ឃុំសណ្តាន់ ស្រុកសំបូរទៅកាន់ភូមិសង្កម ដើម្បីយកទៅឲ្យកងទ័ពរំដោះយៀកកុង ដែលគាត់ទិញពីអ្នកស្រុកតាមតម្លៃត្រឹមត្រូវ គាប់ជួនព្សូរសំឡេងយន្តហោះ ហោះកាត់ពីលើ ខ្ញុំក៏បង្អន់រ៉ឺម៉កម៉ូតូរត់រកកន្លែងឈប់សំចតក្នុងព្រៃឈ្លៃ តាមដងផ្លូវជាប់នឹងដីបួកមួយ ។ ពេលនោះ យន្តហោះធុនទ្រុងជ្រូកពណ៌ស ឬហៅថា អាចានស្រាក់ បានហោះក្រឡឹងពីលើព័ទ្ធជុំវិញខ្ញុំ ។ ប៉ុន្តែ បើយន្តហោះនៅខាងលិច ខ្ញុំសសៀរទៅខាងកើតដីបួក បើយន្តហោះនៅខាងលិចខ្ញុំសសៀរទៅខាងត្បូង ក្រឡឹងជុំវិញដីបួកនោះទាំងភ័យព្រួយ ភ្នែកនោកញ្ចឹងកនឹកដល់គុណម៉ែ ជីដូនជីតា សុំឲ្យបាំងខ្លួនខ្ញុំកុំឲ្យយន្តហោះឃើញ ព្រោះថា បើឃើញ វានឹងបាញ់មិនខាន ។ ពេលនោះ ស្រាប់តែព្ញគ្គុងដោយអាចានស្រាក់នេះ វាបាញ់ផ្សែងពណ៌ ស ឲ្យសញ្ញាហៅយន្តហោះមិច២គ្រឿងមកដល់ភ្លាមៗ ប្រមាណពី៣-៥នាទី ខ្ញុំប្រឹងរត់ចេញពីកន្លែងដីបួកយ៉ាងលឿន ឆ្ពោះទៅទិសខាងកើតជួបនឹងអូរចាស់មួយដែលគ្មានទឹក ព្រោះជារដូវប្រាំងរាំងស្ងួត ហើយក្រាបនៅបាតអូរនោះ ដេកមើលយន្តហោះមុជ ទម្លាក់គ្រាប់ណាប៉ាល់ ផ្ទុះខ្ទាំងៗញ័ររញ្ជួយដី ខ្ទាតដីមកលើក្បាលខ្ញុំ ធ្វើឲ្យខ្ញុំកាន់តែភ័យដោយមាត់ទន្ទេញ តែពាក្យថា «ពុទ្ធោ ពុទ្ធោ!» គុណមាតាបិតាសូមលោកជួយថែរក្សាអាយុជីវិតកូន កុំឲ្យរងរបួសគ្រោះ ថ្នាក់អ្វីឡើយ ។ រយៈពេលចាប់ពីម៉ោង១រសៀល រហូតដល់ព្រលប់ទើបបានស្ងប់ការទម្លាក់គ្រាប់ និងលូនចេញមកសន្សឹមៗពិនិត្យមើលម៉ូតូ ដែលបានដោះកន្ទុយរ៉ឺម៉កចោលនៅជាប់ដីបួក ហើយជិះម៉ូតូចេញពីកូនឈើតូចៗទៅខាងកើតចុះទម្លាក់ក្នុងអូរ ។

ខ្ញុំត្រេកអរណាស់ ដោយមិនមាន របួស មានរបួសតិចតួចទេ ពេលដែលភ័យពេលដែលរត់ទៅលាក់ខ្លួននៅបាតអូរ ដោយទាក់រយៈខោអាវប៉ុណ្ណោះ ។ រឿងយន្តហោះអាមេរិក តាមបាញ់ទម្លាក់គ្រាប់បែកនេះ ខ្ញុំបានជួប២-៣ ដងហើយ មួយដងនោះពេលដោះរ៉ឺម៉ក ពេលយប់ឆ្លងកាត់ព្រែកទេ តាមផ្លូវក្រចេះស្នួល ក៏ជួបព្រឹត្តិការណ៍យន្តហោះមក ដល់ពេលយប់ ប្រមាណម៉ោង៩យប់ ហើយបាញ់ភ្លើងគោមបំភ្លឺ៤៥នាទី ដោយយន្តហោះហោះក្រឡឹងមើលដើម្បីបាញ់ ប៉ុន្តែដោយយើងកាច់មែកឈើគ្របទាន់កាលៈទេសៈ ហើយសម្ងំនៅស្ងៀមរយៈពេល៤៥នាទី អស់ពន្លឺភ្លើងបំភ្លឺពីយន្តហោះ ទើបយើងលើកអង្ករដាក់ទូកឆ្លងកាត់ទទឹងពីត្រើយម្ខាងទៅត្រើយម្ខាងទៀត ដោយសុវត្ថិភាព ។

ក្រៅពីសកម្មភាពយន្តហោះបាញ់ និងទម្លាក់គ្រាប់បំផ្លិចបំផ្លាញផ្លូវថ្នល់ ស្ពាន និង មធ្យោបាយដឹកជញ្ជូននានា ពួកចក្រពត្តិអាមេរិកជួបគ្រោះមហន្តរាយក៏ច្រើនដែរ ធ្វើឲ្យពួកវាមានការបាក់ស្បាតខ្លះដែរ ដោយសារ ការបាញ់ទម្លាក់យន្តហោះពីចុងឈើទាលខ្ពស់ៗពីសំណាក់កងទ័ពរំដោះ ពួកយៀកកុងបានបាញ់ធ្លាក់បាន២គ្រឿង គឺមួយគ្រឿងប្រភេទខទ្ធម្កាគចក្រនៅឃុំសណ្តាន់ ស្រុកសំបូរ និងមួយគ្រឿងទៀតធុនហ្វង់តូម អាមិច នៅកោះស្រកាធ្លាក់ចូលក្នុងព្រែកទេ បាត់រូបបាត់ស្រមោល ។

នៅតាមសហករណ៍វិញ ក្រោយពេលអង្គការប្រកាសតាមភូមិនីមួយៗ បង្កើតក្រុមសាមគ្គីបង្កបង្កើនផល និងក្រុមប្រវាស់ដៃ ហើយមានការដាក់ទិសឲ្យចេញពីភូមិ ឃុំទៅនៅជនបទ ដែលអង្គការមិនប្រើ ពាក្យជម្លៀសឲ្យចេញចោលផ្ទះសម្បែងភូមិករទេ តែគេប្រើពាក្យ "ដាក់ទិស" ឲ្យមានខ្លឹមសារស្រាលជាង ពាក្យ "បណ្តេញ ឬជម្លៀស" នេះ ។ នៅក្នុងភូមិក្រគរ ឃុំក្រគរ អ្នកដែលផ្ទះក្បឿងធំៗ ដំបូល ៣-៤ខ្នង គឺអង្គការហៅប្រាប់ឲ្យរៀបចំសម្ភារដាក់ទិសចេញទៅធ្វើស្រែនៅភ្នំដែកភ្លើង ជាប់មាត់ព្រែកកាំពី ខាងជើងឃុំគោណប់ ប្រមាណ១០គីឡូម៉ែត្រ ។

ពេលវេលាមកដល់ ត្រូវដឹកជញ្ជូនបងប្អូន អ្នកទៅ មានជាង ១០គ្រួសារ ។ ចំណែកខ្ញុំ បានត្រឹមតែបររទេះជូនអ្នកទាំងអស់គ្នាចេញពីផ្ទះទៅកាន់ឃុំចង្ក្រង់ ហើយវិលត្រឡប់មកវិញតាមការចាត់តាំងរបស់គណៈសហករណ៍ ។ អ្នកនៅភូមិក្រគរ អង្គការដាក់ឈ្មោះសហករណ៍ "ក៥", ភូមិទួលមនោរម្យ ហៅ"ក២", ក្រុមសាមគ្គីអូរឫស្សីទី២ ហៅ "ក៤" និងអ្នករស់នៅសហគមន៍ និងអូរឫស្សី១ ហៅ "ក១" ។

ចំពោះរូបខ្ញុំផ្ទាល់ និងគ្រួសារ មានដីស្រែ៣០អា ដែលឪពុកម្តាយក្មេកចែកឲ្យដើម្បីធ្វើស្រែ ដែលស្ថិតនៅភូមិវាលផ្សិតនៅទួលមនោរម្យនោះ គឺស្ថិតនៅក្រុមសាមគ្គីជាផ្នែកនៃសហករណ៍"ក២" ។ សហករណ៍"ក២" នេះ មានគណៈដឹកនាំឈ្មោះ សមមិត្ត សុន ទទួលរួម ហើយសមមិត្ត ច្រឹង ម៉ុងអាន ហៅមិត្ត អាន ជាអនុប្រធានសហករណ៍ទទួលខាងសេដ្ឋកិច្ច និងសមមិត្ត ម៉េត ជាប្រធានយោធា និងមានរចនាសម្ព័ន្ធគ្រប់គ្រងទាំងផ្នែកសង្គមកិច្ច វប្បធម៌ ។

គ្រប់សហករណ៍"ក១,ក២,ក៣,ក៤ និងក៥" គឺសំខាន់នៅសង្កាត់ក្រគរនេះផ្ទាល់ រីឯឃុំសង្កាត់ ផ្សេងទៀតមាន ឃុំថ្មក្រែ ឃុំសំបុក ឃុំដារ ឃុំគោណប់ ឃុំចង្ក្រង សុទ្ធតែមានរចនាសម្ព័ន្ធចាត់តាំងដឹកនាំ គ្រប់គ្រង របៀបរបបប្រហាក់ប្រហែលគ្នា ដែលមានផ្ទៃដីស្រែ ស្រែប្រាំង ដីចម្ការ និងដីភូមិ ផ្ទះសម្បែងប្រហាក់ប្រហែលគ្នា ។ បើភូមិឃុំណាមានច្រើនតែដីស្រែវស្សា និងស្រែប្រាំង ប៉ុន្តែ ខ្វះខាតដីចម្ការនោះ ភូមិឃុំដែលមានដីចម្ការ ត្រូវដកហើយចែករំលែកទៅភូមិឃុំ សហករណ៍នោះឲ្យមាន ខ្វះដែរ ។

ជារៀងរាល់ឆ្នាំ បក្សតែងកោះអញ្ជើញមនុស្សពីក្នុងក្រុមសាមគ្គី និងពីក្នុងសហករណ៍ស្លៀកពាក់ស្អាតបាតឲ្យទៅចូលរួមបុណ្យខួបអនុស្សាវរីយ៍កំណើតបក្សថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ ជាថ្ងៃកំណើតបក្សនៅទីតាំងសាលាខេត្តរយៈពេលតែមួយព្រឹកប៉ុណ្ណោះ ពុំដែលខានឡើយ ។

ពេលនោះ មានការចាត់តាំងបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភាជាតិ ដោយអ្នកទៅចូលរួម ទាំងអស់ចូលបោះឆ្នោត ។ បេក្ខជនមានតែម្នាក់ ដែលគេបោះពុម្ពជាសន្លឹកឆ្នោតរួចជាស្រេច ហើយតម្រង់ជួរចូលបោះឆ្នោត ដោយបត់ក្រដាសនោះជាពីរផ្នត់ ហើយដើរចូលទម្លាក់ក្រដាសនោះទៅក្នុងហិបឆ្នោតជាការស្រេច ។ ខ្ញុំក៏បានចូលរួមបោះឆ្នោតជាមួយគេឯងដែរ គឺយើងនាំគ្នាធ្វើតាមការណែនាំ ការពន្យល់ពីគណៈដឹកនាំ ពុំមានតបឆ្លើយ សួរនាំ ឬតវ៉ាអ្វីសោះឡើយ ។

ការបោះឆ្នោត ជ្រើសសភាតំណាងប្រជាជននោះ ធ្វើឡើងតែមួយដងគត់ ពុំមានការផ្សាយចេញអំពីរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យឲ្យប្រជាជនដឹងឡើយ ។

### ១០) ដំណឹងពីជ័យជម្នះ ១៧ មេសា ១៩៧៥

មុនថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥ តាមក្រុមសាមគ្គីគ្រប់សហករណ៍ទាំងអស់ ត្រូវបាន ជួបជុំគ្នាដោយឡែកៗស្តាប់ការឧទ្ទេសនាមពីកម្មាភិបាលបដិវត្តន៍ថ្នាក់លើ ដែលបានចុះទៅបើកមីទ្ទីង មហាជនតាមសហករណ៍នានា ។

កម្មាភិបាលភូមិ ឃុំ និងតាមសហករណ៍នានា បានកោះអញ្ជើញគ្រប់កម្លាំងមិនថា ចាស់ ទុំ ឬ ឈឺគ្រុនសម្រាកនោះទេ គឺឲ្យមកចូលរួមក្នុងមីទ្ទីងទាំងអស់គ្នា ។ ខ្លឹមសារៈ

១) បំផុសចលនាសមរភូមិក្រោយឲ្យបានខ្លាំងក្លា ដើម្បីលើកទឹកចិត្ត និងឧបត្ថម្ភសមរភូមិមុខ ។

២) ជំរុញសកម្មភាពគ្រប់ផ្នែក គ្រប់កងផលិត កងដឹកជញ្ជូន កងបន្លែ ក្រុមមីងៗមើលកុមារ ក្រុមមីងៗដាំស្ល និងកម្លាំងខាងកងនេសាទ ក្រុមភស្តុភារ ក្រុមថែទាំគោក្របី ត្រូវទទួលខុសត្រូវតាមកងតាមក្រុម តាមផ្នែកនីមួយៗឲ្យបានខ្លាំងក្លា ដើម្បីលើកទឹកចិត្តដល់យុទ្ធជនសមរភូមិមុខ ដែលកំពុងជ្រោងទង់ប្រយុទ្ធយ៉ាងខ្លាំងក្លាស៊ិតស្វាញក្រាញនឿល ខាំកេរបណ្តាច់ឫសកែវខ្មាំង ហាលភ្លៀងផ្គរ ក្រាប លូន វាយខ្មាំងឈានទៅរំដោះភ្នំពេញជាសំបុកចុងក្រោយ

របស់រដ្ឋបាល លន់ នល់ ។

ការលើកឡើង ពន្យល់ អប់រំ ឃោសនា ដល់ម៉ោង១០ព្រឹក ទើបបើកសិទ្ធិឲ្យមីងៗផ្ទះបាយ ទៅរោងបាយដើម្បីដាំស្លសម្រាប់សមាជិកសហករណ៍ពេលចប់មីទ្ទីងពេលថ្ងៃត្រង់ ។ កម្មាភិបាលឃោសនា អប់រំ មានវោហាសាស្ត្រហូររអឺក ប្រៀបដូចទឹកធ្លាក់ពីលើភ្នំ ប៉ុន្តែមិនចេះអក្សរ ឬមានវប្បធម៌ជ្រៅជ្រះនោះទេ ប៉ុន្តែមិនអាចមានអ្នកណារិះគន់ ឬទិតៀនបានឡើយ ព្រោះថាទ្រឹស្តីរបស់អង្គការដែលជាវណ្ណៈស្នូលរបស់បក្ស ពោលគឺ កម្មករ កសិករ ជាសម្ព័ន្ធភាពជិតស្និទ្ធ និងជាស្នូលដឹកនាំក្នុងជួរបក្សប្រជាជនបដិវត្តន៍កម្ពុជា ។

កម្មាភិបាលឃោសនាអប់រំ លើកឡើងពីវីរភាពដ៏អស្ចារ្យនៃវីរយុទ្ធជន វីរយុទ្ធនារី យ៉ាងអង់អាចក្លាហានឈ្នះខ្មាំងសត្រូវ និងកាន់កាប់តំបន់រំដោះជាច្រើននៅកៀក និងខាងលិចភ្នំពេញពិសេស ចូលកាន់កាប់នៅអរិយក្សត្រមុខភ្នំពេញតែម្តង ។ វិទ្យុសំឡេងរំដោះកាន់តែរន្ថើនផ្សាយពីជោគជ័យវាយខ្មាំងខ្លាំងឡើងៗ រាល់ព្រឹកល្ងាច និងទទួលបានជោគជ័យគ្រប់ពេលទាំងអស់ ។

ក្រោយថ្ងៃ ១៧ មេសា ១៩៧៥ បានលេចឮតាមវិទ្យុសំឡេងកងទ័ពរំដោះជាតិកម្ពុជាបញ្ជាក់ថា កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា បានវាយរំដោះយកបាននៅម៉ោង៩ព្រឹក រំដោះភ្នំពេញបានទាំងស្រុងពីពួកប្រតិកិរិយា លន់ នល់, សិរិ មតៈ និងចូលកាន់កាប់ទីបញ្ជាការដ្ឋានសេនាធិការធំរបស់ លន់ នល់ និងបានអំពាវនាវឲ្យពលទាហានទាំងអស់ទម្លាក់អាវុធ ដើម្បីឈប់ប្រយុទ្ធបង្ហូរឈាមតាមមាគ៌ានយោបាយរណសិរ្សរួបរួមជាតិកម្ពុជាដែលមានសម្តេចព្រះនរោត្តម សីហនុ ជាព្រះប្រធាន ។

ព័ត៌មានស្តីពីភ្នំពេញបានរំដោះថ្ងៃ ១៧ មេសា បានទាំងស្រុង ត្រូវបានកម្មាភិបាលបដិវត្តន៍ផ្សព្វផ្សាយដល់សហករណ៍នានានៅទូទាំងប្រទេសដោយផ្ទាល់ ព្រោះពុំមានអ្នកណាម្នាក់មានវិទ្យុ ម៉ាញ៉េ ស្តាប់សោះឡើយ ម្នាក់ៗមានកម្មសិទ្ធិសមរម្យគឺស្លាបព្រាមួយតូចតែប៉ុណ្ណោះ ។

នៅពេលនោះ សំឡេងទះដៃអបអរសាទរជោគជ័យ ១៧ មេសា កម្ពុជារំដោះទាំងស្រុងពីពួកចក្រពត្តិ និងពួកបរិវារត្រូវបានបន្លឺឡើងព្រមៗគ្នា តាមការបំផុសពីកម្មាភិបាលឃោសនាអប់រំ ។

បន្ទាប់មក ប្រធានក្រុមយុវជន បានហៅឈ្មោះយុវជននៅតាមសហករណ៍មកឈរតម្រង់ជួរជាពីរ គឺក្រុមយុវជនមួយជួរ យុវនារីមួយជួរ មានគ្នាសរុបប្រមាណ៣០នាក់ ការហៅឡើងមកឈរជាជួរពីមុខទៅក្រោយ យ៉ាងលឿនដូចជាបានហាត់សមទុកជាមុន ដើម្បីហាត់រៀនច្រៀងចម្រៀង ១៧ មេសា កម្ពុជារំដោះ ។

ចម្រៀងនេះ ប្រជាជនទូទាំងសហករណ៍ ត្រូវចេះចាំហើយ និងអាចច្រៀងបានគ្រប់កាលៈទេសៈ ទោះពេលភ្ជួររាស់ដកស្ទូងដាំបន្លែ មិនថាយប់ថ្ងៃបានទាំងអស់ ។

## ១១) ការបែងចែកប្រជាជនជា៣ប្រភេទ

ចាប់ពីក្រោយថ្ងៃ ១៧ មេសា ១៩៧៥ តាមសហករណ៍នានាមានត្រៀមលក្ខណៈចាំទទួលបងប្អូនអ្នកជម្លៀសទាំងអស់ដែលអង្គការហៅថា អ្នក១៧មេសា ។ បងប្អូនអ្នក១៧មេសា ឬបងប្អូនថ្មីនេះ នឹងត្រូវមករស់នៅតាមសហករណ៍ជាមួយយើងគ្រប់ៗគ្នា ដោយសហករណ៍នីមួយៗ នឹងត្រូវទទួលប្រមាណ១៥គ្រួសារទៅ២០គ្រួសារតាមការជាក់ស្តែង ។ ដូច្នេះ ណែនាំឲ្យប្រជាជនចាស់ ដែលរស់នៅយូរ ហើយត្រូវមានសាមគ្គីល្អ ជួយអប់រំណែនាំប្រជាជនថ្មីទាំងអស់នេះទៅតាមមាគ៌ាបដិវត្តន៍យើង និងជួយឧបត្ថម្ភគាំទ្របងប្អូនទាំងនេះ តាមគោលនយោបាយ ដោយធ្វើផ្ទះសម្បែងមួយគ្រួសារផ្ទះមួយខ្នង មានដីដាំដំណាំនៅជុំវិញផ្ទះ និងរស់នៅក្នុងសហករណ៍ ។ ចំពោះមុខប្រជាជនចាស់ អង្គការឲ្យរស់នៅមានផ្ទះដំបូលប្រក់ស្លឹកមួយខ្នង មានដីដាំដំណាំជុំវិញផ្ទះ បើគ្រួសារនេះ ជាកម្លាំងទី១ នោះត្រូវថែទាំគោមួយនឹមផង ជាកម្លាំងអូសទាញសំខាន់បំផុត ។

ចំពោះរូបខ្ញុំផ្ទាល់ ដែលមានអតីតភាពជាគ្រូបង្រៀន អង្គការចាត់ចូលជាអនុធន ព្រោះថា ជិះជាន់គេផង និងត្រូវគេជិះជាន់ផងត្រូវចាត់ចូលជាប្រជាជនប្រភេទទី២ ឬជាប្រជាជនត្រៀម ។ រីឯប្រជាជនប្រភេទទី១វិញ គឺពួកអ្នកចាស់ដែលរស់នៅមូលដ្ឋាននោះរាប់ឆ្នាំមកហើយ ឬក៏មានវណ្ណភាពដើមជាកសិករក្រកណ្តាលថ្នាក់កណ្តាល ឬកសិករកណ្តាលថ្នាក់ក្រោម ដែលធ្លាប់ទទួលរងនូវការជិះជាន់ ឬកេងប្រវ័ញ្ច និងរស់នៅក្រីក្រតោកយ៉ាកខ្លាំងក្លាពេកកាលពីសង្គមចាស់ អង្គការចាត់ចូលជាប្រជាជនប្រភេទទីមួយ ។

## ១៣) ផែនការទក្រិដ្ឋ

ក្នុងចំណោមផែនការខ្រក្រិដ្ឋរបស់ពួកប្រតិកិរិយាបាន និង កំពុងមានសកម្មភាពពុះកញ្ជ្រោលនៅលើទឹកដីកម្ពុជាមាតុភូមិជាទីស្នេហានៃយើងនោះគឺ៖

- ◆ ផែនការបណ្តេញមនុស្សចេញពីទីក្រុង ទីប្រជុំជន
- ◆ ផែនការបោសសម្អាតបដិវត្តន៍ឲ្យស្អាតស្អំ (វិសុទ្ធកម្ម)
- ◆ ផែនការបំបាត់លុយកាក់ ផ្សារផ្សោ រូបិយវត្ថុ ធនាគារ
- ◆ ផែនការបិទសាសនា ជំនឿទាំងអស់
- ◆ ផែនការបិទសាលារៀន មណ្ឌលសិក្សា សកលវិទ្យាល័យ
- ◆ ផែនការចូលសហករណ៍ទាំងអស់
- ◆ ផែនការបណ្តេញអាណិកជនវៀតណាម
- ◆ ផែនការផ្តាច់ការទាក់ទងការទូតជាមួយបណ្តាប្រទេសមួយចំនួន ។

ប្រការដែល ប៉ុល ពត លើកផែនការខ្រក្រិដ្ឋទាំង៨នេះ មានតាំងពីពេលចាប់ផ្តើមមកម្ល៉េះ គឺចាប់ផ្តើមជម្លៀសប្រជាជន ទន្ទឹមគ្នា និងការបិទសាសនា ជំនឿ គ្រប់បែបយ៉ាង បំបាត់លុយកាក់ផ្សារផ្សោ រតនាគារជាតិទាំងអស់ ។ ការចាត់តាំងរៀបចំក្រុមសាមគ្គីបង្កើនផល ក្រុមប្រវាស់ដៃ និងឈានទៅបញ្ចូលក្នុងសហករណ៍ ងាយស្រួលក្តាប់ជាប់ ងាយស្រួលបោសសម្អាតបដិវត្តន៍ឲ្យស្អាតស្អំ ។

ប្រការដែលមានកម្មាភិបាលពីភាគខាងជើងវៀតណាមរាប់សិបនាក់ ក៏ត្រូវបន ប៉ុល ពត ធ្វើការបោសសម្អាត ដើម្បីធ្វើវិសុទ្ធកម្មឲ្យបដិវត្តន៍បានស្អាតស្អំ និងបរិសុទ្ធ ។ នោះគឺមានការអនុវត្តផែនការទាំងអស់នោះ ប្រទាក់ក្រឡាគ្នាទាំងអស់ បើនៅតែអាឡោះអាល័យលើរបៀបចាស់នោះ នឹងមានប្រជាជនចាស់ទិតៀនភ្លាមថា ឲ្យកម្ទេចលោកទស្សនៈចាស់ចោលចេញ ហើយកសាងលោកទស្សនៈថ្មី កុំនៅអាឡោះអាល័យ ឬនឹកស្រមៃរបបចាស់ទៀត គ្មានអាចបានគ្រប់គ្រាន់ ពេញលេញបានទេ ព្រោះថ្មីទាំងអស់ ថ្មីទាំងលោកទស្សនៈ ថ្មីទាំងការនិយាយ និងធ្វើការងារ ។

## ១៨) ផែនការបណ្តេញជនជាតិវៀតណាម

ផែនការនេះ ជាផែនការក្តៅគគុកបំផុត ។ គឺជាការលាក់ការសម្ងាត់បំផុត ដែលគណបក្ស ប៉ុល ពត មិនមែនធ្វើដោយគ្មានការទទួលខុសត្រូវ ឬលំៗ សើៗ សោះឡើយ ។

លុះត្រាតែមនុស្សដែលអង្គការ មានការជឿទុកចិត្ត និងជាស្នូល ឬបក្ខជនរបស់បក្សទើបបានចាត់តាំងឲ្យចុះស៊ើបអង្កេត និងស្រាវជ្រាវនៅតាមសហករណ៍នានា ដែលកំពុងធ្វើពលកម្មរៀងរាល់ថ្ងៃ ។ បណ្តាជនជាតិវៀតណាម ឬវៀតណាមយកប្តីខ្មែរ ឬខ្មែរយកប្តីវៀតណាម រហូតដល់មនុស្សខ្មែរដែលចេះវៀតណាម ឬមានរាងរៅរបៀបដូចជនជាតិវៀតណាមក៏ដោយ ក៏អង្គការបោសសម្អាតឲ្យអស់ដែរ ។

ពាក្យបោសសម្អាតនេះ មិនមែនយកអំបោសដូចបោសសំរាម បោសប្រាសផ្ទះសម្បែងឲ្យស្អាត នេះទេពាក្យបោសសម្អាតគឺជាន័យអត្ថាន្តរូបសំដៅទៅលើការចាប់ខ្លួនយកទៅសម្លាប់បំបាត់ពូជសាសន៍ ។

ដោយសារ មានការស្អប់ និងគុំគួនទៅលើវៀតណាម រហូតមានជម្លោះតាមព្រំដែន តាមកោះនានា នៅមាត់សមុទ្រផងនោះ បក្ស ប៉ុល ពត បានបញ្ជាឲ្យកងទ័ពវាយចូលឈ្លានពានដល់ដីវៀតណាម នៅខេត្តអានយ៉ាង ខេត្តតៃនិញ ជាដើម ដុតបំផ្លាញបាញ់រះយ៉ាងព្រៃផ្សៃទៅលើកម្មករ ស្ត្រី ប្រជាជនវៀតណាម ដុតបំផ្លាញផ្ទះសម្បែង សាលារៀន ចម្ការអំពៅខូចខាតអស់ជាច្រើន ទាំងជីវិតមនុស្ស ទាំងទ្រព្យសម្បត្តិប្រជាជន ។ នៅសហករណ៍ ក១, ក២, ក៣, ក៤ និង ក៥ គណៈសហករណ៍បានជ្រើសរើសក្រុមយុវជន ដែលអង់អាចក្លាហាន ដើម្បីបំពេញកម្លាំងកងទ័ពទៅវាយនៅវៀតណាម ។

នោះគឺជាផែនការរបស់បក្ស ចាត់តាំងកម្លាំងសហករណ៍នីមួយៗ ត្រូវជ្រើសយុវជនកម្លាំងពេញ និងអង់អាចក្លាហាន ដើម្បីទៅហាត់ក្បាច់យុទ្ធសាស្ត្រ ត្រៀមចេញទៅព្រំដែន ស្នួល-តៃនិញ តាំងពីក្រោយថ្ងៃ ១៧ មេសា ១៩៧៥ ។

តាមពិត តាមកម្មាភិបាលសហករណ៍បាននិយាយក្នុងមីទ្ទីងថា គម្រោងត្រូវវាយរំដោះក្រុង ភ្នំពេញនៅចុងខែមេសា ឆ្នាំ១៩៧៥ តែខាងកម្ពុជាទាមទារឲ្យកម្លាំងប្រញាប់រំដោះកម្ពុជា នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ វៀតណាមរំដោះទាំងស្រុងថ្ងៃ៣០ ខែមេសា ឆ្នាំ១៩៧៥ ដោយឡែកនៅប្រទេសឡាវ ថ្ងៃ២ ខែធ្នូ ឆ្នាំ ១៩៧៥ ។

**(នៅមានត)**

**អ៊ិច ស៊ុនឡាយ**

# រកឃើញមិត្តភក្តិក្នុងចម្លើយសារភាព

កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៨ អ៊ីប្រុស តាំង ស៊ីម បាន ធ្វើដំណើរដ៏វែងឆ្ងាយពីក្រៅប្រទេសមកកាន់បន្ទប់ការិយាល័យ សាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងគោលបំណង ដើម្បីស្រាវជ្រាវរកអតីតមិត្តភក្តិរបស់គាត់ឈ្មោះ ញឹក វេង ហួរ, ម៉ី សាខន, និងឈ្មោះ វង់ សូផានូ ដែលបានស្លាប់នៅក្នុងសម័យ ខ្មែរក្រហម ។ តាំង ស៊ីម បានចូលមកបន្ទប់ការិយាល័យព័ត៌មាន សាធារណៈជាមួយសម្លៀកបំពាក់ខោពណ៌គគីរ អាវឆ្នូតសដៃខ្លី និងមានទឹកមុខស្រងូតស្រងាត់ អង្គុយនៅក្នុងការិយាល័យ ។ គាត់ បានជួបជាមួយខ្ញុំ និងបានស្រាវជ្រាវរកតាមប្រព័ន្ធទិន្នន័យរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែង គាត់ បានរកឃើញឈ្មោះមិត្តភក្តិរបស់គាត់ ញឹក វេង ហួរ ដែលមាននៅ ក្នុងឯកសារចម្លើយសារភាព លេខ D១៧០១៨ ។

អ៊ំ តាំង ស៊ីម បានរៀបរាប់ថា ៖ គាត់គឺជាអតីតទាហាន ជើងទឹកកាលពីសម័យសាធារណរដ្ឋខ្មែរ និងមានស្រុកកំណើតរស់ នៅសង្កាត់លេខ៧ ខណ្ឌជ្រោយចង្វារ ក្រុងភ្នំពេញ ។ សព្វថ្ងៃ គាត់ រស់នៅរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ។ មុនសម័យខ្មែរក្រហម គាត់បានចូលរៀននៅវិទ្យាល័យចៅពញាយ៉ាត ។

នៅឆ្នាំ១៩៧០ គាត់បានចូលបម្រើជាទាហានជើងទឹក ។ ចុងឆ្នាំ១៩៧៤ គាត់អាយុ២១ឆ្នាំ បានទៅបន្តការសិក្សារៀនសូត្រ នៅសហរដ្ឋអាមេរិក ដែលមានការគាំទ្រពីរដ្ឋាភិបាលសាធារណរដ្ឋ ខ្មែរ ។ មុនដំបូង គាត់សិក្សាផ្នែកភាសាអង់គ្លេស នៅរដ្ឋតិចសាស់ សហរដ្ឋអាមេរិក ជាមួយនឹងអតីតមិត្តភក្តិជិតស្និទ្ធ និងកម្សត់កម្រ ជាមួយគ្នាឈ្មោះ ញឹក វេង ហួរ ។ គាត់នៅចងចាំថា នៅឆ្នាំ១៩៧៥ នៅពេលខ្មែរក្រហមគ្រប់គ្រងអំណាច រដ្ឋាភិបាលអាមេរិកបាន ប្រកាសឲ្យនិស្សិតខ្មែរដែលចេញទៅរៀន ជំនាន់គាត់ ត្រឡប់មក ស្រុកកំណើតវិញ ជាមួយនិស្សិតចំនួន៣៦នាក់ផ្សេងទៀត ដែល នៅក្នុងចំណោមនោះ ក៏មាន ញឹក វេង ហួរ ដែរ ។ វេង ហួរ បាន ស្ម័គ្រចិត្តត្រឡប់ចូលមកប្រទេសវិញ ដោយសារតែគាត់មាន ប្រពន្ធ, កូន, ឪពុកម្តាយ, បងប្អូន និងសាច់ញាតិរស់នៅក្នុងប្រទេស កម្ពុជា ។ ដោយឡែក ស៊ីម មិនបានត្រឡប់មកទេ ព្រោះគ្រួសារ របស់គាត់បានមករស់នៅប្រទេសអាមេរិកហើយ ។

ស៊ីម បានបន្តថា “ពេលដែល វេង ហួរ ត្រឡប់មកស្រុកខ្មែរ វិញ វេង ហួរ បានធ្វើដំណើរតាមយន្តហោះឆ្ពោះទៅកាន់ស្រុក ចិនសិន ទើបបន្តទៅស្រុកខ្មែរ ដែលក្នុងដំណើរត្រឡប់មកវិញនោះ មានបញ្ញវន្តចំនួន៣៦នាក់ ។ គាត់មិនបានដឹងពីវាសនាមិត្តភក្តិ របស់យ៉ាងណានោះទេ ។ នៅចុងឆ្នាំ១៩៧៩ ស៊ីម ទទួលដំណឹង តាមរយៈឯកសារផ្សេងៗដែលបានផ្ញើមកពីក្រៅស្រុកថា អតីត មិត្តភក្តិរបស់គាត់បានស្លាប់នៅក្នុងសារមន្ទីរទួលស្លែង ។ ប៉ុន្តែគាត់ មិនដឹងថា វេង ហួរ ស្លាប់ដោយ សារមូលហេតុអ្វីនោះទេ ។

គាត់បានបន្តទៀតថា នៅពេលដែលគាត់ត្រឡប់ទៅសហរដ្ឋ អាមេរិកវិញ គាត់ពាំនាំនូវព័ត៌មានដែលទើបរកឃើញទាំងនេះ ទៅប្រាប់មិត្តភក្តិ បងប្អូន និងសាច់ញាតិ ព្រោះវាជាព័ត៌មានដ៏មាន តម្លៃ ដែលគាត់បានតាមរកអស់រយៈពេលជាង៣៦ឆ្នាំកន្លងមក ។ គាត់នឹងរៀបចំប្រារព្ធពិធីបុណ្យឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធមិត្ត ភក្តិរបស់គាត់ដែលបានស្លាប់ ។ ស៊ីម មានប្រសាសន៍ថា រឿងរ៉ាវ របស់មិត្តភក្តិគាត់ គឺហាក់ដូចជានៅថ្មីៗសម្រាប់គាត់ ទោះបីមាន រយៈពេលជាង៣០ហើយក៏ដោយ ។ រឿងរ៉ាវនេះ បានបន្សល់ទុក នូវការចងចាំសម្រាប់គាត់ ហើយជាឯកសារ និងភស្តុតាងដ៏មាន តម្លៃសម្រាប់ប្រជាជនខ្មែរដែរ ។ **ស៊ិន សុធីតា**

- **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការ ផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ *truthkokthay@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។










***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 178, 2014 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.